# មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយ ម៉ា ស៊ីវន ភេទស្រី អាយុ៦៣ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ“ប្រធានពេទ្យកងពល៥០២”**

**ម៉ា ស៊ីវន ត្រូវជាប្រពន្ធ ស៊ូ ម៉េត អតីតលេខាកងពល៥០២**

**ស្រុកកំណើតនៅភូមិស្រែអណ្តូង ឃុំពាម ស្រុកកំពង់ត្រឡាចលើ ខេត្តកំពង់ឆ្នាំង**

**សព្វថ្ងៃរស់នៅភូមិរំចេក៤ ឃុំរតនៈ ស្រុកបាត់ដំបង ខេត្តបាត់ដំបង,**

**ភូមិកញ្ចាំង ឃុំស៊ុង ស្រុកសំឡូត ខេត្តបាត់ដំបង និង ភូមិព្រៃរំចេក ឃុំតាសាញ**

**ស្រុកសំឡូត ខេត្តបាត់ដំបង**

**ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ ឡុង ដានី**

**០៣:០២:៤៦**

**៩៧ទំព័រ**

ដានីៈ  អឺអើ! ដំបូងខ្ញុំចង់ស្គាល់ឈ្មោះអ៊ំ អ៊ំឈ្មោះពេញឈ្មោះអីដែរ?

ស៊ីវនៈ  ម៉ា ស៊ីវន ។

ដានីៈ  ម៉ា ស៊ីវនហ៎?

ស៊ីវនៈ  ចា៎!

ដានីៈ  អ៊ំសព្វថ្ងៃអាយុប៉ុន្មានហើយ?

ស៊ីវនៈ  ៦០! ៦៣ ។

ដានីៈ  ៦៣ បាទ! កើតឆ្នាំខ្មែរឆ្នាំអីទៅ ឆ្នាំសត្វអីទៅ?

ស៊ីវនៈ  សត្វគោ ។

ដានីៈ  សត្វគោ ឆ្នាំឆ្លូវណ៎អ៊ំណ៎! ឆ្នាំឆ្លូវទើបអាយុ៦៣ទេ?

ស៊ីវនៈ  ការពិត វាលើសហើយឆ្នាំដែលខ្ញុំដាក់ជាប់តែម្តង ១៩៥០ ។

ដានីៈ  ១៩៥០ណ៎អ៊ំ?

ស៊ីវនៈ  ១៩៥០ហ្នឹង ត្រូវអត្តសញ្ញាណប័ណ្ណ ត្រូវអីទាំងអស់ ។

ដានីៈ  បាទៗ! ប៉ុន្តែឆ្នាំឆ្លូវជាឆ្នាំអ៊ំពិតប្រាកដដែរអ៊ំកើត?

ស៊ីវនៈ  ចា៎! ៦៥ហើយ ។

ដានីៈ  ៦៥ហើយអ៊ំណ៎ ។

ស៊ីវនៈ ការពិតទៅធ្វើការយើងបន្ថយតិច ។

ដានីៈ កំណើតកើតជាអី?

ស៊ីវនៈ នៅភូមិស្រែអណ្តូង ឃុំពាម ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។

ដានីៈ កំពង់ត្រឡាចលើ?

ស៊ីវនៈ ចា៎! ខាងលើថ្នល់ ។

ដានីៈ កំពង់ឆ្នាំង ។ ហើយស្រុកកំណើតរបស់អ៊ំប្រុស?

ស៊ីវនៈ ដូចគ្នា! ភូមិក៏នៅជាមួយគ្នា ខុសតែផ្ទះគ្នា ។

ដានីៈ នៅភូមិជាមួយគ្នាខុសតែឲ្យផ្ទះទេ?

ស៊ីវនៈ ចា៎!

ដានីៈ អ៊ំប្រុសឈ្មោះគាត់អេី!

ស៊ីវនៈ ស៊ូ សាម៉េត! តាំងពីដើមអត់មានផ្លាស់ប្តូរទេ ។

ដានីៈ ស៊ូ សាម៉េតហ៎! ខ្ញុំឮគេហៅគាត់ៗ ស៊ូ ម៉េតៗ ។

ស៊ីវនៈ អត់ទេ! ស៊ូ សាម៉េត ។ តាំងពីដើម គាត់រៀនតាំងពីដើមដាក់តែចិន តែហើយមកដល់សម័យ ៣ឆ្នាំគេដាក់តែស៊ូ ម៉េត ។

ដានីៈ អូ! ចិន ។

ស៊ីវនៈ តែឈ្មោះតែមួង ស៊ូ សាម៉េត ។

ដានីៈ បាទ! ហើយគាត់អាយុប៉ុន្មានដែរកាលគាត់ខូច?

ស៊ីវនៈ អាយុ៦៨ ។

ដានីៈ អាយុ៦៨ឆ្នាំ ។

ស៊ីវនៈ ១៩៤៨ ។

ដានីៈ កើតឆ្នាំ១៩៤៨ គាត់កើតឆ្នាំសត្វអីដែរ?

ស៊ីវនៈ គាត់ថាដូចកើតឆ្នាំកុរ ម៉េចទេឮចាស់និយាយតែខ្ញុំពុំសូវច្បាស់ដែរ តែថាដូចឆ្នាំកុរ ជ្រូក ។

ដានីៈ បាទ! ឆ្នាំកុរឆ្នាំជ្រូក ។ គាត់ឆ្នាំជ្រូកចិនទេ ។

ស៊ីវនៈ កុរជ្រូក!

ដានីៈ កំណើតរបស់គាត់នៅជាមួយអីដែរ?

ស៊ីវនៈ នៅភូមិ ឃុំដូចគ្នា ។

ដានីៈ ចុះអ៊ំប្រុសអ៊ំប្រុស ឪពុកគាត់ឈ្មោះអីដែរ?

ស៊ីវន: ឪពុកគាត់ឈ្មោះ ម៉ា ម៉ន់! ប្រាប់ត្រង់ស្លាប់បាត់ហើយ ។

ដានី: ហើយ ម៉ា មន់ ហ្នឹងឪពុកក្មេកអ៊ី ហើយស្លាប់ទាំងពីឆ្នាំណាទៅ?

ស៊ីវន: ឆ្នាំ១៩៦៨ ។

ដានី: ឆ្នាំ១៩៦៨! គាត់ស្លាប់ដោយសារអី?

ស៊ីវន: ឈឺ!

ដានី: គាត់ស្លាប់នៅឯណាទៅ?

ស៊ីវន: តាមគេនិយាយគណាក្អួយ អ៊ំអត់បានឃើញផ្ទាល់ទេ នៅភ្នំដីរីរមៀល អត់ដឹងនៅភូមិអីច្បាស់ទេ ព្មតែគេថាទេ ។

ដានី: នៅភូមិដីរីរមៀល ខាងតាកែវនោះវិញ?

ស៊ីវន: ដឹងដែរ! កំពង់ស្ពឺ ឬក៏តាកែវ ពុំដឹងច្បាស់ទេ ។

ដានី: ចុះម្តាយគាត់ឈ្មោះអីដែរ?

ស៊ីវន: សុខ យ៉េន ។

ដានី: សុខ យ៉េន! គាត់ស្លាប់ឆ្នាំណាដែរ?

ស៊ីវន: ឆ្នាំ៧៩ ។

ដានី: ឆ្នាំ៧៩ ពេលរត់យួនហើយ ។

ស៊ីវន: ពេលរត់ហ្នឹង!

ដានី: គាត់ស្លាប់នៅណាវិញ?

ស៊ីវន: ស្លាប់ក្នុងព្រៃ តែពុំដឹងថានៅត្រង់ណា ។

ដានី: ក្នុងព្រៃបាទ! អ៊ំប្រុស គាត់បងប្អូនប៉ុន្មាននាក់ទៅ?

ស៊ីវន: ៨នាក់ ។

ដានី: ស្រីប៉ុន្មាន ប្រុសប៉ុន្មានទៅ?

ស៊ីវន: ស្រី៤ ប្រុស៤ ។

ដានី: អូ! ស្មើគ្នាល្អណាស់ណ៎! ស្រី៤ ប្រុស៤ ។ អ៊ំប្រុស គាត់ទីប៉ុន្មាន?

ស៊ីវន: ទី២!

ដានី: កូនទី២ ចុះទី១?

ស៊ីវន: ទី១ស្រី ។

ដានី: ទី១ស្រី! គាត់នៅណាដែរ?

ស៊ីវនៈ សព្វថ្ងៃនៅភូមិកញ្ចាំង។

ដានីៈ ភូមិអី?

ស៊ីវនៈ ភូមិកញ្ចាំង! គេហៅភូមិខ្លាឃ្មុំនោះ។

ដានីៈ អូ! កញ្ចាំងហ៎?

ស៊ីវនៈ ចា៎!

ដានីៈ ខ្លាឃ្មុំស្រុកគាសាញ់ អូ៎! ឃុំគាសាញ់។

ស៊ីវនៈ មិនមែនទេ! ឃុំស៊ុង។

ដានីៈ ស្រុកសំឡូតយើង។ គាត់ឈ្មោះអីដែរ?

ស៊ីវនៈ គាត់ឈ្មោះ ស៊ូ ណាំ។

ដានីៈ ស៊ូ ណាំ។ គាត់គ្រកូលអត់មាននេះទេណ៎?

ស៊ីវនៈ ចា៎!

ដានីៈ ទី២អីប្រុស! ទី៣?

ស៊ីវនៈ ទី៣ឈ្មោះស៊ូ យ៉ន តែស្លាប់។

ដានីៈ ស៊ូ យ៉ន! គាត់ស្លាប់ពីអន្កាល?

ស៊ីវនៈ ប៉ុន្មានទេ២០០០ អើ១៨។

ដានីៈ ១៩៦៨?

ស៊ីវនៈ មិនមែនទេ! ៩៧, ៩៨។

ដានីៈ ៩៧, ៩៨ ហ៎?

ស៊ីវនៈ ឈឺ!

ដានីៈ ឈឺហ៎?

ស៊ីវនៈ ចា៎!

ដានីៈ ស្លាប់នៅកំពង់ឆ្នាំង គាត់នៅស្រុកកំណើត?

ស៊ីវនៈ មិនមែនស្រុកកំណើតទេ គឺនៅស្រុកប្រពន្ធ។

ដានីៈ បាទ! ទី៤?

ស៊ីវនៈ ទី៤ ស៊ូ ម៉ាន ស្លាប់ដែរ។

ដានីៈ ស៊ូ ម៉ាន?

ស៊ីវនៈ ចា៎! ស្លាប់យូរហើយអាហ្នឹង តាំងពីឆ្នាំ៧០,៧១,៧២ហ្នឹង ធ្វើទាហានស្លាប់។

ដានី៖ ទី៥អី?

ស៊ីវន៖ ស៊ូ ហឿន! រាល់ថ្ងៃធ្វើមេភូមិកញ្ចាំង ។

ដានី៖ ស៊ូ ហឿនធ្វើមេភូមិកញ្ចំង ឃុំស៊ុង ។

ស៊ីវន៖ មួយទៀតស្រី ។

ដានី៖ ស៊ូ ហឿនហ្នឹងស្រី?

ស៊ីវន៖ ស្រី! មួយទៀត ស្រីទៀត ស៊ូ ណាត ។

ដានី៖ គាត់នៅឯណាដែរ?

ស៊ីវន៖ បាត់ខ្លួនឆ្នាំណា៧៩ដូចគ្នា ស្លាប់! តាមមើលទៅ ។

ដានី៖ បើនៅឃើញហើយណុំអីណុំ ។

ស៊ីវន៖ ទី៧ ស៊ូ ទូច! ដាក់ឈ្មោះ វណ្ណាទេឈ្មោះគេវណ្ណា ។

ដានី៖ វណ្ណាហៅទូចហ៎?

ស៊ីវន៖ ហៅទូច ចេះតែនាំគ្នាហៅទូច ។

ដានី៖ ស្រី ឬក៏ប្រុស?

ស៊ីវន៖ ស្រី ។

ដានី៖ គាត់នៅឯណាដែរ?

ស៊ីវន៖ នៅភូមិនេះដែរ ។

ដានី៖ នៅភូមិកញ្ចាំងហ៎?

ស៊ីវន៖ ចា៎!

ដានី៖ មួយទៀតប្រុស! ទី៨ ពៅគេ?

ស៊ីវន៖ ចា៎! ពៅគេប្រុស! ឈ្មោះ ស៊ូ ចាន់ធូ ។ គាត់ស្លាប់អត់ហើយ ស្លាប់ឆ្នាំ ប៉ុន្មានឆ្នាំហើយ ៣,៤ឆ្នាំហើយ ។ ជិត៩៨,៩៩ ស្លាប់៩៩ ។

ដានី៖ ៩៩!

ស៊ីវន៖ ស្លាប់អស់ហើយ ។

ដានី៖ ថាប្រពន្ធគាត់កូនរបស់ តាជនហ្នឹង?

ស៊ីវន៖ ហ្នឹងហើយ កូនតាជនហ្នឹង ត្រូវហើយនៅសល់កូនពីររាល់ថ្ងៃ កំព្រាក្មួយស្គាល់តាជនដែរ ។ ស្លាប់បាត់ហើយតាជន ។

ដានី៖ បាទ! គាត់ស្លាប់នៅបាត់ដំបង ។

ស៊ីវ៉ន: ស្លាប់មុនតាខ្ញុំទៀត។ មិនយូរទេក្មួយស្លាប់ទាំងអស់ហ្នឹង កុំភ័យ។

ដានី: ហើយចុះអ៊ំម្ដង ឪពុកឈ្មោះអីដែរ?

ស៊ីវ៉ន: ម៉ា ឈុំ។

ដានី: ឈ្មោះ ម៉ា ឈុំ?

ស៊ីវ៉ន: ម៉ា ឈុំ។

ដានី: ហើយចឹង គាត់បងប្អូនឈ្មោះ ជាមួយម៉ា ម៉ង់ដែរ?

ស៊ីវ៉ន: អត់ទេ!

ដានី: គាត់ខូចឆ្នាំណាទៅ?

ស៊ីវ៉ន: ៧៩! តែអត់បាយ រត់ឡើងភ្នំ។

ដានី: ពេលឡើងភ្នំហេ៎?

ស៊ីវ៉ន: សុទ្ធតែអត់បាយ។

ដានី: ចុះម្ដាយអ៊ំ ទេព ឈិន។

ស៊ីវ៉ន: ឈិន! ស្លាប់ហើយ គាត់ស្លាប់នៅផ្ទះ។

ដានី: ស្លាប់នៅឆ្នាំណា?

ស៊ីវ៉ន: មិនដឹងប៉ុន្មានទេ! ដូចជា២០០១។

ដានី: ២០០១ ហេ៎?

ស៊ីវ៉ន: ចា៎!

ដានី: ស្លាប់នោឯស្រុកកំណើតនៅឯស្រែអណ្ដូងហេ៎?

ស៊ីវ៉ន: ចា៎! ស្រុកកំណើតនៅឯស្រែអណ្ដូង។ គាត់បានយួនយកគាត់មករស់នៅណា យួនដូចថាទៅធ្វើការឃើញគាត់យកមក។

ដានី: ឃើញគាត់នៅក្នុងណា?

ស៊ីវ៉ន: នៅក្នុងព្រៃនោះ។ ការពិតរត់ទៅទាំងអស់គ្នាចឹង ដល់ពេលឃើញគេរត់ចោលគាត់ នៅសល់តែគាត់ម្នាក់ យួនឃើញយកគាត់មក គាត់នឹកគុណយួនណាស់។

ដានី: គាត់នឹកគុណយួន?

ស៊ីវ៉ន: គាត់អរគុណយួនណា៎! កុំតែយួនមកគាត់អត់រស់ទេ គាត់ថាចឹង ម៉ែខ្ញុំគាត់ក៏ស្រលាញ់។

ដានី: ហើយអ៊ំបងប្អូនប៉ុន្មាន?

ស៊ីវ៉ន: ៨នាក់ ទាំងខ្ញុំ។

ដានីៈ បងប្អូនស្ទើរគ្នាល្អណាស់ ។

ស៊ីវនៈ ចា៎! ច្រើនណាស់ ។

ដានីៈ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ស៊ីវនៈ ស្រី៣ ប្រុស៥ ។ ស្លាប់ហើយប្រុស នៅសល់តែស្រី៣នាក់ ។

ដានីៈ នៅសល់តែស្រី៣នាក់ ប្រុសស្លាប់អស់ហើយ?

ស៊ីវនៈ ស្លាប់អស់ហើយ ។

ដានីៈ អ៊ីកូនទីប៉ុន្មាន?

ស៊ីវនៈ ខ្ញុំកូនទី២ ។

ដានីៈ ទី២ ដូចគាត់ដែរ, ចុះទី១?

ស៊ីវនៈ ទី១ បងនៅឯស្រុក ។

ដានីៈ បងនៅស្រុក បងស្រី ឬក៏ប្រុស?

ស៊ីវនៈ បងស្រី ។

ដានីៈ គាត់ឈ្មោះអីដែរ?

ស៊ីវនៈ ម៉ា ឈន ។

ដានីៈ ម៉ា ឈន ។ ហើយទី២អ៊ី?

ស៊ីវនៈ ចា៎!

ដានីៈ ហើយទី៣?

ស៊ីវនៈ ទី៣ឈ្មោះ ម៉ា ឈៀង ស្លាប់ ។

ដានីៈ ម៉ា ឈៀង ស្លាប់ ។ គាត់ស្លាប់ដោយសារអីទៅ?

ស៊ីវនៈ សង្គ្រាម៧០ហ្នឹង ៧១, ៧២ហ្នឹង ធ្វើទាហាន ។

ដានីៈ ហើយទី៤?

ស៊ីវនៈ ម៉ា ឆឹង ។

ដានីៈ ម៉ា ឆឹង, ស្រី ឬក៏ប្រុស ។

ស៊ីវនៈ ហ្នឹងក៏ស្លាប់, ប្រុស ។ ធ្វើទាហាន៧០, ៧៣ស្លាប់ ។

ដានីៈ ទី៥?

ស៊ីវនៈ ទី៥ ស្រី ម៉ា ឈីន នៅរស់ ស្រី ។

ដានីៈ គាត់នៅណាទៅ, នៅជិតភ្នំពេញ ។

ស៊ីវន៖  នៅជិតភ្នំពេញ។

ដានី៖  នៅជិតភ្នំពេញ?

ស៊ីវន៖  ចាំ!

ដានី៖  ខាងណា?

ស៊ីវន៖  គេថានៅទួលលាភ។

ដានី៖  អូ! ខាងទួលលាភ។

ស៊ីវន៖  បាទ! ទី៦ ម៉ា ឈីង។

ដានី៖  ម៉ា ឈីង។

ស៊ីវន៖  ម៉ា ឈីង គាត់ចូលចិត្តឈ្មោះដូនគ្នា។

ដានី៖  ស្រី ឬក៏ប្រុស?

ស៊ីវន៖  ប្រុស ស្លាប់។

ដានី៖  គាត់ស្លាប់ពីអង្កាលទៅ?

ស៊ីវន៖  ស្លាប់២០០០ ដូចជា២០០១ទេដឹង។

ដានី៖  ២០០១ ដែរ, ទី៧?

ស៊ីវន៖  ម៉ា ឆាយ។ ឆាយក៏ស្លាប់ដែរ បាត់អស់ហើយ មិនដឹងទៅណាទៅណើទេ។

ដានី៖  ប្រុស ឬក៏ស្រី?

ស៊ីវន៖  ប្រុស អាហ្នឹង៩៣បាត់។

ដានី៖  បាទ! ទី៨ពៅគេ?

ស៊ីវន៖  ម៉ា ឈៀ។

ដានី៖  គាត់នៅឯណាទៅ?

ស៊ីវន៖  ស្លាប់អស់ហើយ។

ដានី៖  ស្រី ឬប្រុសហ្នឹង?

ស៊ីវន៖  ប្រុស។ ស្លាប់នៅឯភ្នំដែរ?

ដានី៖  ៧៩ ហើយហ្នឹង?

ស៊ីវន៖  ៧៩។

ដានី៖  បាទ! ចុះអ៊ី អ៊ីបានជួបអ៊ីប្រុស អ៊ីស៊ូ ម៉េត តាំងពីឆ្នាំណាទៅ?

ស៊ីវន៖  ឆ្នាំ១៩៦៧។

ដានី៖ អឺការ?

ស៊ីវ៉ន៖ ចាំ! ការឆ្នាំ ១៩៦៧ ។

ដានី៖ រៀបការឆ្នាំ១៩៦៧ ។ អឺ មានកូនចៅប៉ុន្មាននាក់ដែរ?

ស៊ីវ៉ន៖ ៩, ៦នាក់ ស្លាប់មួយនៅសល់៥ ។

ដានី៖ កូន៦នាក់ ស្លាប់ម្នាក់ ។

ស៊ីវ៉ន៖ នៅសល់៥នាក់ ។

ដានី៖ ទី១ កូនឈ្មោះអីទៅអឺ?

ស៊ីវ៉ន៖ ឈ្មោះ ស៊ូ ស៊ីវត្ថា ស្លាប់ហ្នឹង ស្រី ។

ដានី៖ ទី២?

ស៊ីវ៉ន៖ ទី២ ស៊ូ សាម៉ានី ។

ដានី៖ ស្រី ឬក៏ប្រុស?

ស៊ីវ៉ន៖ សុទ្ធតែស្រី! កូនខ្ញុំប្រុសតែមួយ ។

ដានី៖ ស្រី, គាត់នៅទេ ។ គាត់មានគ្រួសារហើយ, ទី៣?

ស៊ីវ៉ន៖ ទី៣ ស៊ូ វណ្ណៈ ។

ដានី៖ ស្រី ឬក៏ប្រុស?

ស៊ីវ៉ន៖ ស្រី ។

ដានី៖ ស្រីដែរ? ទី៤?

ស៊ីវ៉ន៖ ទី៤ ស៊ូ សុវណ្ណនឿន ។

ដានី៖ ស៊ូ សុវណ្ណនឿន! ស្រី ឬក៏ប្រុស?

ស៊ីវ៉ន៖ ស្រី សុទ្ធតែស្រី ។

ដានី៖ ទី៥?

ស៊ីវ៉ន៖ ទី៥ ស៊ូ ម៉េងយី ។

ដានី៖ ស៊ូ ម៉េងយី ។ ស្រី ឬប្រុស?

ស៊ីវ៉ន៖ ស្រីដែរ ។

ដានី៖ ទី៦ ស៊ូ សុវណ្ណមុនី ។

ស៊ីវ៉ន៖ ដាក់ មុនី ។

ដានី៖ មុនី!

ស៊ីវ៉ន: “ម” ស្រះ“ ុ”, “ន” ស្រះ“ ី” ។

ដានី: បាទ! អាហ្នឹងប្រុស?

ស៊ីវ៉ន: អាហ្នឹងប្រុស! មានតែប្រុសមួយទេពៅ ។

ដានី: ពៅគេ?

ស៊ីវ៉ន: ចា៎!

ដានី: មានគ្រួសារនៅពៅគេ?

ស៊ីវ៉ន: នៅ! នៅទាំងអស់ នៅពីរនាក់ទៀតអត់ទាន់មាន ។

ដានី: ទី៥ ទី៦អត់ទាន់មានទេ ។ ចុះពៅគេប្រុស អាយុប៉ុន្មានឆ្នាំហើយ?

ស៊ីវ៉ន: ហ៎! ឆ្នាំរោងច្រើនហើយកើតឆ្នាំ ១៩៨៩ ។

ដានី: បាទ! ឆ្នាំរោង១៩៨៩ ។ បើឆ្នាំរោង ៨៩ វា?

ស៊ីវ៉ន: ២៥, ២៦ ហើយទេដឹង ។

ដានី: ២៨, ២៥ យើងរាប់ខ្មែរ២៥ បើសិនជារាប់តាមបារាំង២៤ ។ ហើយអ៊ឹ កាលពីមុនរៀបការ អ៊ឹស្គាល់គ្នាទេ កាលពីក្មេងៗ?

ស៊ីវ៉ន: ស្គាល់! នៅផ្ទះជិតគ្នាដែរហ្នឹង ។

ដានី: នៅផ្ទះជិតគ្នា?

ស៊ីវ៉ន: រំលងបាន៤ ទៅ១០ផ្ទះ ។

ដានី: ចុះមានជាប់សាច់ឈាមគ្នាអត់?

ស៊ីវ៉ន: ដូចមិនជាប់អីច្រើនទេ ។

ដានី: នៅផ្ទះជិតៗគ្នា ។

ស៊ីវ៉ន: តែគ្រាន់ថាពីជីដូន ជីតាអាចជាប់ខ្លះ តាទួត យាយទួតអី ។

ដានី: ចុះអ៊ឹប្រុស គាត់រៀនសូត្រអីដល់ណាដែរ?

ស៊ីវ៉ន: រៀនថ្នាក់ទី៣ ទី៣ ពីសង្គមចាស់ ។

ដានី: ថ្នាក់ទី៣សង្គមចាស់ណ៎! នៅសាលាណាទៅ?

ស៊ីវ៉ន: សាលាទេពប្រណម ។

ដានី: អូ! មកខាងនេះវិញ មកខត្តុឝ្គវិញ ។

ស៊ីវ៉ន: ចា៎!

ដានី: គាត់ឈប់រៀបឆ្នាំណាទៅ?

ស៊ីវនៈ ឈប់នៅឆ្នាំ៦៨ ។

ដានីៈ ការហើយនៅរៀនទៀត?

ស៊ីវនៈ អូ! មិនទេ ៦៦ ។

ដានីៈ ឈប់មុនមួយឆ្នាំ?

ស៊ីវនៈ ឈប់មុន១ឆ្នាំ ហើយបានការ ។

ដានីៈ ដល់ថ្នាក់ទី៣ហ្នឹង បានឈប់តែម្តង គាត់បានមានប្រាប់ពីមូលហេតុគាត់ឈប់រៀនទេ ។

ស៊ីវនៈ តាមដឹងថាឪពុកគាត់ឲ្យឈប់ ហើយឲ្យរកប្រពន្ធ ។

ដានីៈ ឪពុកឲ្យឈប់ ។ ឪពុកគាត់កាលហ្នឹង អ៊ីដឹងឲ្យធ្វើអីដែរ?

ស៊ីវនៈ អត់ដឹង!

ដានីៈ ហើយក្រោយមកមានដឹងទេ?

ស៊ីវនៈ អត់ដឹងថាគាត់ធ្វើការ ធ្វើស្អី តែគ្រាន់តែក្រោយមកដឹងថាគាត់ចូលមកក្នុងព្រៃដែរ ឆ្នាំ៦៨ហ្នឹង ដឹងថាគាត់នៅក្នុងព្រៃ ដឹងតែប៉ុណ្ណឹង ។

ដានីៈ ឆ្នាំ៦៨ ដឹងថាគាត់នៅក្នុងព្រៃ ដឹងថាគាត់នៅណាទៅ?

ស៊ីវនៈ ពួគេស្លាប់ឯហ្នឹងបណ្តោយ ។ ប៉ុន្តែកាលពីនៅស្រុកអត់ដែរឃើញទេ ។

ដានីៈ អត់ដែលឃើញគាត់ទេ?

ស៊ីវនៈ អត់! អត់ស្គាល់ទៀត ។

ដានីៈ ចុះកាលពី! អត់ស្គាល់គាត់ទេ?

ស៊ីវនៈ អត់ចាំមុខអត់ដែលឃើញមុខ ។

ដានីៈ ដល់ពេលណាបានឃើញមុខគាត់?

ស៊ីវនៈ អត់ឃើញមុខគាត់រហូត ។

ដានីៈ ចុះពេលការ?

ស៊ីវនៈ ពេលការក៏អត់ឃើញគាត់ដែរ ។

ដានីៈ ពេលការហ្នឹងអត់ឃើញគាត់ទេ?

ស៊ីវនៈ ការតែម្តាយទេ ។

ដានីៈ ការតែម្តាយ ប៉ុនកាលហ្នឹងឪពុកគាត់នៅរស់តើ?

ស៊ីវនៈ នៅរស់! ប៉ុន្តែពួគេថាវរល់ ។

ដានីៈ វរល់ហ៉េ?

ស៊ីវនៈ ចា៎! យើងមិនច្បាស់ដែរ ។

ដានីៈ ចុះអ៊ីប្រុសឈប់៦៦ កាលហ្នឹងធ្វើអីដែរពេលឈប់រៀនហើយ អត់មានធ្វើអីដែរ?

ស៊ីវនៈ អត់មានធ្វើអីទេ ។

ដានីៈ នៅស្រុក?

ស៊ីវនៈ ចា៎! មកពីរៀន ឈប់រៀនទៅការ ដល់ការហើយបានគេជ្រើសរើសគ្រូ បានធ្វើគ្រូបង្រៀនសាលាបឋមសិក្សាស្រែអណ្តូង ។

ដានីៈ គ្រូបឋមសិក្សានៅស្រែអណ្តូង?

ស៊ីវនៈ ចា៎!

ដានីៈ ចុះអ៊ីបានរៀនដល់ថ្នាក់ណាដែរ?

ស៊ីវនៈ ថ្នាក់ទី៧ ។

ដានីៈ រៀនបានថ្នាក់ទី៧ដែរ! អ៊ីរៀនបានថ្នាក់ទី៧ រៀននៅស្រុកណាគេ?

ស៊ីវនៈ ស្រុកកំណើតទេ ។

ដានីៈ នៅខាង?

ស៊ីវនៈ អត់ទាន់បានប្រលងចូលអនុវិទ្យាល័យផង ។

ដានីៈ នៅស្រែអណ្តូង ឬក៏នៅពាម?

ស៊ីវនៈ ស្រែអណ្តូង ។

ដានីៈ ស្រែអណ្តូង ។

ស៊ីវនៈ ស្រែអណ្តូង រៀនដល់ថ្នាក់ទី៧ ។

ដានីៈ ដល់ពេលថ្នាក់ទី៧ អ៊ីឈប់រៀនឆ្នាំណា?

ស៊ីវនៈ ឈប់! តាំងពី៦៥ ។

ដានីៈ មុនគាត់ទៀត?

ស៊ីវនៈ រៀនត្រូវទៅប្រលងហើយ អត់បាន! យើងក្រពេក គ្មានលុយប្រឡង ។

ដានីៈ ហើយអ៊ីការហើយ អ៊ីធ្វើអីទៅ?

ស៊ីវនៈ ខ្ញុំ ធ្វើស្រែ ។

ដានីៈ អ៊ីធ្វើស្រែណា៎?

ស៊ីវនៈ ចា៎!

ដានីៈ ដល់ពេលអ៊ីប្រុសគាត់ធ្វើគ្រូ?

ស៊ីវនៈ ធ្វើគ្រូ ។

ដានីៈ បង្រៀននៅសាលាបឋមសិក្សាស្រែអណ្ដូងហ្នឹងបណ្ដោយ ។ ហើយគាត់បង្រៀនបានប៉ុន្មានឆ្នាំដែរ?

ស៊ីវនៈ គាត់បង្រៀនប្រហែលជា២ឆ្នាំ ។

ដានីៈ បានពីរឆ្នាំ គាត់ឈប់ឆ្នាំណាទៅចឹង?

ស៊ីវនៈ ៦៩គាត់ចេញមកព្រៃ ចុងឆ្នាំ ៧០ចេញមកព្រៃ ព្រៃម៉ាកគីហ្នឹងបណ្ដោយ ។

ដានីៈ កាលហ្នឹងអ៊ំទៅជាមួយគាត់ដែរអត់ទេ?

ស៊ីវនៈ អត់ទេ! គាត់ទៅមុន ។

ដានីៈ ចឹងអ៊ំប្រុសគាត់ឆ្នាំ៦៩ គាត់ចេញទៅព្រៃ ចេញទៅម្នាក់ឯងទេ?

ស៊ីវនៈ ទៅតែឯង ។

ដានីៈ កាលហ្នឹងអ៊ំមានកូនប៉ុន្មានហើយ?

ស៊ីវនៈ អត់ទាន់មានទេ ។

ដានីៈ ដល់ពេលអ៊ំប្រុស គាត់ទៅនៅព្រៃទៅនៅម្ដុំណាទៅ?

ស៊ីវនៈ មិនដឹងថាទៅណាផងអត់ច្បាស់ទេ ។

ដានីៈ គាត់អត់ដែរ មកលេងផ្ទះទេ?

ស៊ីវនៈ អត់ទេ! អត់ដែរជួបគ្នាទេ ។

ដានីៈ អត់ដែរបានជួបគ្នាទេ?

ស៊ីវនៈ អត់ដែរជួបគ្នាទេ ។

ដានីៈ ហើយដល់ឆ្នាំណាទៅបានអ៊ំជួប ។

ស៊ីវនៈ ៧២ ហ៎?

ដានីៈ ហើយ កាលគាត់ចេញទៅជាមួយអ្នកណាខ្លះ ទៅឆ្នាំណាខ្លះ?

ស៊ីវនៈ អត់សូវស្គាល់គេទេ ។ តែគ្រាន់តែដឹងថាគេចេញមកព្រៃ ។

ដានីៈ ព្រៃហ្នឹង ព្រៃនៅខាងកំពង់ឆ្នាំង?

ស៊ីវនៈ ព្រៃនៅខាងកំពង់ឆ្នាំង ម្ដុំភ្នំឱរ៉ាល់ ។

ដានីៈ ម្ដុំភ្នំឱរ៉ាល់!

ស៊ីវនៈ កាលចេញមកនៅលើភ្នំជរាយ ភ្នំឱរ៉ាល់ ។

ដានីៈ ខាងឱរ៉ាល់ ខាងនរាយណ៍ហ៎?

ស៊ីវនៈ ជរាយ ។

ដានីៈ ភ្នំជរាយ!

ស៊ីវនៈ នៅក្នុងខេត្តកំពង់ឆ្នាំង ។

ដានីៈ បាទ! ដល់ឆ្នាំ៧២ អ៊ីទៅជាមួយគាត់ដែរ?

ស៊ីវនៈ អត់ទេ! គេធ្វើកងទ័ព ។

ដានីៈ ឆ្នាំ៧២ ឃើញគាត់ធ្វើទ័ព?

ស៊ីវនៈ ឃើញគាត់ធ្វើទ័ពទៅហើយ ។

ដានីៈ ជួបគ្នានៅឯណាហ្នឹង?

ស៊ីវនៈ ជួបនៅ! គាត់មកជួបអ្នកជំងឺនៅពេទ្យ ខ្ញុំធ្វើពេទ្យដែរ ។

ដានីៈ ជួបពេលមកមើលអ្នកជំងឺនៅពេទ្យ ។ ពេទ្យណាទៅ?

ស៊ីវនៈ ពេទ្យហ្នឹងគេរៀបចំនៅព្រៃជំបូងគេហៅ ពីដើមគេហៅពេទ្យស្រុកកំពង់ត្រឡាច ។ ជំនាន់ខ្មែរក្រហមហើយហ្នឹងណា!

ដានីៈ បាទ! ឆ្នាំ៧២ហ្នឹង បានន័យថាមានពេទ្យអីហើយ?

ស៊ីវនៈ តែគ្រាន់តែថាពេទ្យយើងពុំសូវមានថ្នាំមានអី តែមើលអ្នកឈឺ អ្នករបួសបាន ។

ដានីៈ នៅក្នុងព្រៃ ឬក៏នៅឯស្រុក?

ស៊ីវនៈ នៅតាមភូមិគេ! តែយើងមិននៅក្នុងភូមិទេ ដូចថាមានភូមិគេចឹង មានព្រៃហើយ យើងទៅធ្វើនៅព្រៃទៅ ។

ដានីៈ ហើយកាលហ្នឹង អ៊ីចូលធ្វើពេទ្យតាំងពីឆ្នាំណា?

ស៊ីវនៈ ខ្ញុំធ្វើពេទ្យតាំងពីឆ្នាំ៧០ ។

ដានីៈ ចឹងពេលដែលលន់ នល់ ធ្វើរដ្ឋប្រហារហើយ នៅខាងកំពង់ត្រឡាចហ្នឹងនៅខាងហ្នឹង ត្រូវ?

ស៊ីវនៈ ត្រូវចេញតែម្តង ចេញទាំងអស់គ្នា ។

ដានីៈ ចឹងនៅខាងកំពង់ត្រឡាចហ្នឹង អត់មានលន់ នល់ទៅដល់ទេ?

ស៊ីវនៈ មាន! មានហើយដូចថាយើងចេះតែរត់ ទៅចូលសម្តេចអំពាវនាវនោះណា ចេញតាមសម្តេចអស់ទៅ ។ ចេះតែទៅ ចេះតែចេញដូច ខ្ញុំអីស្រីចឹងគេឲ្យធ្វើពេទ្យ ហើយប្រុសគេឲ្យធ្វើកងទ័ព ។

ដានីៈ អើ! ឆ្នាំ៧០តែម្តង ខែប៉ុន្មានដែរ?

ស៊ីវនៈ ខែ១ ខែរដ្ឋប្រហារភ្លាមហ្នឹង ។

ដានីៈ រដ្ឋប្រហារ អើ! ឆ្នាំ៧០ហ្នឹង ខែ៣ ។

ស៊ីវន: ហ្នឹងហើយខែ៣ តែខ្ញុំអាចទៅមុនហ្នឹងតិច ។

ដានី: មុនហ្នឹងតិច! មុនគេធ្វើរដ្ឋប្រហារ ។

ស៊ីវន: ព្រោះចេះ លន់ នល់ទៅដូចថាក្រឡុកនៅតាមភូមិ ទៅដល់ស្រាវជ្រាវខ្មែរក្រហម រកអ្នកអីចេះ ចុះចឹងណា ដល់ចឹងយើងពីបាកនៅក៏នាំគ្នារត់ចេញ ប៉ុន្តែខ្ញុំអត់មានលំបាកទេ មកពីទាហាន លន់ នល់ដណ្តឹងខ្ញុំ ។

ដានី: ដល់ពេលចឹងអ៊ីខ្លាច?

ស៊ីវន: ខ្លាច! ជិតដល់ថ្ងៃការហើយសន្យាមួយអាទិត្យទៀត រត់ព្រឹប!

ដានី: ឆ្នាំណា? មុនអ៊ីការជាមួយអ៊ីប្រុសទៀត?

ស៊ីវន: ក្រោយ! គាត់ចេញបាត់ហើយហ្នឹង, ទាហានមកស្រលាញ់ទៀត ។

ដានី: អូ! អ៊ីការជាមួយគាត់ហើយ ។

ស៊ីវន: ដល់ពេលគាត់ចេញបាត់មក ពួកលន់ នល់ គេដើររាគត្បាត ។ គេឃើញថានរណាមានប្តីរត់ គេឲ្យទៅប្តឹងចឹងទៅណា ដល់យើងទៅប្តឹង ទៅប្រាប់គេទៅ គេឲ្យទៅធ្វើសំបុត្រលែងគ្នា គេចូលដណ្តឹងយើងវិញ ហើយជិតដល់ថ្ងៃការមើលទៅអត់ស្រួល ខ្ញុំរត់បណ្តោយ អត់មានទំនាស់អីទេ ។

ដានី: កាលជំបូងអត់ប្រកែកទេ? ខ្លាច!

ស៊ីវន: មិនហានប្រកែក ។

ដានី: លន់ នល់ ហ្នឹងស្អីគេបានគេ?

ស៊ីវន: សក្ត៍៣ ។

ដានី: សក្ត៍៣! ជាអ្នកនៅឯនៅហ្នឹង ឬអ្នកមកពីចម្ងាយ?

ស៊ីវន: ពីចម្ងាយ ។ គេមកធ្វើការដូចថា ចុះមកធ្វើការតាមស្រុកភូមិចឹងណា អូ! សក្ត៍៣ជំនាន់នោះខ្លាំងដែរតើ ។

ដានី: ឈ្មោះអីទៅ?

ស៊ីវន: ឈ្មោះ អ៊ុក នាង ។

ដានី: អ៊ុក នាង ហេ៎?

ស៊ីវន: ចា៎!

ដានី: ដល់ចឹងឆ្នាំ៧០ អ៊ីរត់បណ្តោយ?

ស៊ីវន: ចា៎! រត់បណ្តោយ មើលតែមួយអាទិត្យទៀតការព្រឹប ។

ដានី៖ កាលហ្នឹង ដល់ពេលអ៊ំទៅពេទ្យ អ៊ំដូចថាអ៊ំមានបានរៀនសូត្រ ខាងវិជ្ជាពេទ្យម៉េចដែរ?

ស៊ីវន៖ បានរៀនដែរ! រៀនពីវេជ្ជបណ្ឌិត ដួន ជឿន។

ដានី៖ អូ! រៀនជាមួយ តា ដួន ជឿន?

ស៊ីវន៖ ចា៎! គាត់បង្រៀន។

ដានី៖ កាលហ្នឹង គាត់មកនៅពេទ្យ គាត់នៅណា?

ស៊ីវន៖ គាត់ចេញមកឆ្នាំ៧០ដែរ។

ដានី៖ ចេញពីណាមក?

ស៊ីវន៖ ចេញពីភ្នំពេញមក។

ដានី៖ ចេញពីភ្នំពេញមក គាត់ទៅនៅណា?

ស៊ីវន៖ នៅម្តុំស្រុកថ្ពង។

ដានី៖ ស្រុកថ្ពង។

ស៊ីវន៖ ថ្ពង កំពង់ស្ពឺ នៅឃុំ៨មុំ។

ដានី៖ បាទ! ឃុំ៨មុំ ខ្ញុំស្គាល់។

ស៊ីវន៖ នៅម្តុំត្រង់ហ្នឹង ក្បែរមាត់ស្ទឹង ដល់ចឹងគេធ្វើមន្ទីរពេទ្យតាមហ្នឹងចឹងទៅ គាត់នៅហ្នឹង។

ដានី៖ គាត់បង្រៀន?

ស៊ីវន៖ ដល់ចឹង គាត់ហៅអ្នកអត់ចេះអីមករៀនរហូត។

ដានី៖ អ៊ំរៀនបានរយៈពេលប៉ុន្មានជាមួយតា ដួន ជឿន?

ស៊ីវន៖ រៀនជាមួយគាត់?

ដានី៖ បាទ!

ស៊ីវន៖ រៀនជាប់ដែរ ដូនកាលបីខែរៀនម្តង មួយខែកន្លះរៀនម្តងតាមសភាពជំងឺដែលចូលច្រើនតិច ឬឆាប់អីចឹងណា៎ ហើយធូន់ស្រាល។

ដានី៖ ហើយកាលហ្នឹង ដូជថាអ្នកដែលទៅរៀនជាមួយគាត់ច្រើនហ៎?

ស៊ីវន៖ ច្រើន! មាន៥០នាក់,៣០នាក់,១០០នាក់ គាត់ចេះតែបើករៀនជាប់រហូត។

ដានី៖ កាលហ្នឹង គាត់បង្រៀនពីការព្យាបាលជំងឺទូទៅ ឬក៏បង្រៀនពីស្អី?

ស៊ីវន៖ ទី១បង្រៀនទូទៅ! ទី២គាត់បង្រៀនពីរបួស ទី៣បង្រៀនពីសង្គ្រោះ ទី៤ពីវះកាត់, វះកាត់តូចតាច។

ដានី៖ ដល់ពេលវះកាត់ធំៗ?

ស៊ីវ៉ន: អាហ្នឹងក៏ត្រូវរៀនដែរ តែគាត់រៀនដាក់ស្ដែង ពេលនេះគាត់ហៅទៅចូលវ៉ះ ។

ដានី: ពេលគាត់មានវ៉ះអី គាត់ហៅយើងចូលទៅដែរ?

ស៊ីវ៉ន: ហៅចូល ។

ដានី: ចឹងមន្ទីរពេទ្យដែល លោកតាដួន ជឿន ទៅដឹបូង អាកន្ទែងមាត់ស៊ឹង ខាង៨មុំហ្នឹង?

ស៊ីវ៉ន: ចា៎!

ដានី: មួយចំហៀង ខាងស្រុកកំពង់ត្រឡាច ហើយហ្នឹងកំពង់ឆ្នាំង មួយចំហៀងខាងកំពង់ស្ពឺ ។

ស៊ីវ៉ន: កំពង់ត្រលាច៨មុំជាប់គ្នាចឹង តែប្រលោះស៊ឹង ។

ដានី: អឺស្គាល់វត្តតាំងខ្មៅទេ?

ស៊ីវ៉ន: ស្គាល់ ។ តាំងខ្មៅទៅលើបន្តិចទៅ ស្រែអណ្ដូងហើយ ទៅលើបន្តិចទៅតាំងពោធិ៍ តាដួន ជឿន នៅម្ដុំហ្នឹង ។

ដានី: កាលហ្នឹងដូចជាអឹ១ ក៏គាត់មកនៅហ្នឹងច្រើនដែរ?

ស៊ីវ៉ន: មកច្រើន! អឹ១ធ្លាប់នៅស្រែអណ្ដូងនោះក៏ច្រើន ។

ដានី: ពីណាខ្លះ?

ស៊ីវ៉ន: តាមដឹង មានតា វ៉ន វ៉េត ។

ដានី: តាវ៉ន វ៉េតហ្នឹង មានស្រុកកំណើតនៅហ្នឹងតែម្ដង?

ស៊ីវ៉ន: មិនទេ! មិនដឹងគាត់នៅឯណា ប៉ុន្តែគាត់ចេញមកធ្វើការភាគច្រើននៅម្ដុំហ្នឹង ។

ដានី: អូ! តា វ៉ន វ៉េត ពីណាទៀត?

ស៊ីវ៉ន: តាខៀវ សំផន ក៏ធ្លាប់នៅហ្នឹងដែរ ។

ដានី: តាខៀវ សំផន ក៏នៅហ្នឹងដែរ, ចេង អន ក៏នៅនេះដែរ?

ស៊ីវ៉ន: ចេង អន ក៏នៅនេះដែរ អូ! ស្គាល់តាចេកហ្នឹងដែរ?

ដានី: ខ្ញុំស្គាល់តាមឯងសារ ។

ស៊ីវ៉ន: ហើយគាត់កាលហ្នឹង គេហៅ នង សួន ហៅចេង អន ហីក៏មិនមែនទេ! ចេង អន មួយទៀត ស ។ ហ្នឹងហើយតាចេង អន គាត់នៅឯហ្នឹង ។ តានង សួន ហ្នឹងពីមុន សម័យ៣ឆ្នាំ គាត់នៅកាន់ខេត្តកំពង់ឆ្នាំង ។

ដានី: កាន់ខេត្តកំពង់ឆ្នាំង?

ស៊ីវ៉ន: កាន់ខេត្តហ្នឹង គាត់គ្រប់គ្រងមួយខេត្ត តែគេមិនហៅខេត្តកំពង់ឆ្នាំងទេគេហៅតំបន់៣១ ។

ដានី: តំបន់៣១?

ស៊ីវន: ចា៎!

ដានី: ចុះតំបន់១៥ នៅឯណាទៅ?

ស៊ីវន: តំបន់១៥ហ្នឹងភ្នំពេញហ្នឹងហើយ ភូមិភាគពិសេសហ្នឹង នៅភ្នំពេញហ្នឹងហើយ ។

ដានី: បានន័យថាជុំវិញភ្នំពេញទាំងអស់ ។ ខត្តុគ្គអីគ្រែងនៅក្នុងអ៎!

ស៊ីវន: អត់ទេ! ចាប់ពីត្នាតពង ហ្នឹងហើយម្តុំអស់ហ្នឹង ទៅលើអីទន្លេនោះ ។

ដានី: កាលនោះអ៊ឹ វន វើត គាត់ធ្វើ?

ស៊ីវន: គាត់ទទួលដឹងស្អីទេ ខ្ញុំអត់ច្បាស់ទេណា! តែគ្រាន់តែដឹងគាត់ធ្វើធំណាស់ ។

ដានី: ចុះអ៊ឹប៉ុល ពតអីគាត់ធ្លាប់ទៅទេ?

ស៊ីវន: ប៉ុល ពត អត់ច្បាស់ទេ ព្រោះអ្នកធំចឹង ដូចយើងអ្នកក្រោមចឹងមិនសូវដឹង លាក់ការបានល្អណាស់ ទៅត្រង់ណាៗក៏មិនដឹង ។

ដានី: បាទ! អ៊ឹ កាលហ្នឹង អ៊ឹទៅរៀន រៀនហើយយើងមក?

ស៊ីវន: ធ្វើការវិញ ។

ដានី: មកធ្វើការនៅស្រុកកំពង់ត្រឡាច?

ស៊ីវន: ខ្ញុំធ្វើពេទ្យស្រុកកំពង់ត្រឡាច ។

ដានី: ពីណាគេធ្វើប្រធានពេទ្យ?

ស៊ីវន: ខ្ញុំហ្នឹងប្រធាន ។

ដានី: អូ! អ៊ឹប្រធានពេទ្យស្រុកហ្នឹងតែម្តង?

ស៊ីវន: ចា៎! គេហៅប្រធានៗទៅរៀន ។

ដានី: ប្រធាននារីហេ៎?

ស៊ីវន: ប្រធានពេទ្យហ្នឹង គឺទទួលទាំងស្រី ទាំងប្រុស ។

ដានី: នៅកំពង់ត្រលាច! ចុះ គណៈស្រុក?

ស៊ីវន: គណៈស្រុក កាលហ្នឹងឈ្មោះ តាសារុន ។

ដានី: អូ! តា សារុន ក្រោយមកគាត់ឡើងជាគណៈតំបន់៣១ហ្នឹងហេ៎?

ស៊ីវន: ចា៎!

ដានី: ចុះយាយមែន ស្គាល់គាត់ដែរ?

ស៊ីវន: ស្គាល់! ស្លាប់ហើយ គេយកគាត់ទៅវាយចោលដែរហ្នឹង ។

ដានី: ឮល្បីថាគាត់ពេលតស៊ូ គាត់ពូកែ ឡើងសមរភូមិអីពូកែ ។

ស៊ីវ៉ន: គាត់ហ្នឹងហើយ គាត់រហ័ស ហើយគាត់ពូកែនិយាយ រហ័សទាំងអស់ ចាត់ចែងក៏រហ័ស ស្រុករខ្ញុំ ដែលតា៎ បងខ្ញុំ១ឆ្នាំ ។

ដានី: ហ៊ូចឹង!ខ្ញុំ អើ ។

ស៊ីវ៉ន: តែស្លាប់យូរហើយគ្នា តាំងពី៧៧ ។

ដានី: តាំងពី៧៧មក! គេយកគាត់ទៅ?

ស៊ីវ៉ន: គេយកគាត់ទៅ!

ដានី: យកទៅណា?

ស៊ីវ៉ន: យកទៅព្រៃសកន្លែង តា ឌុច ។

ដានី: កន្លែងតា ឌុច អើ!

ស៊ីវ៉ន: កន្លែងទួលស្លែង ខ្ញុំឮតែគេថាទេ ខ្ញុំអត់ដឹងទេ ។

ដានី: បាទៗ! ស-២១ ។

ស៊ីវ៉ន: ព្រោះកាលហ្នឹងធ្វើអីក៏ដោយគេលាក់ការមិនឲ្យយើងដឹងទេ ។

ដានី: តា សារុន គេយកទៅដែរ?

ស៊ីវ៉ន: តា សារុន មិនដឹងទៅណាទេ! អូ! តែស្លាប់នៅក្នុងព្រៃ ។

ដានី: តា សារុន ស្លាប់ក្នុងព្រៃ?

ស៊ីវ៉ន: ស្លាប់ក្នុងព្រៃ ពេលរត់មក៧៩នោះ ។

ដានី: ចុះមួយទៀត ដែលគណៈតំបន់ដែរ?

ស៊ីវ៉ន: ឈ្មោះអីដែរ?

ដានី: ឈ្មោះ យីមចឹងហ៎?

ស៊ីវ៉ន: អូ! តាយីមហ៎?

ដានី: បាទ!

ស៊ីវ៉ន: តាយីមហ្នឹង គាត់ធ្វើប្រធានកងទ័ពតាដំបូង

ដានី: នៅតំបន់៣១ដែរ?

ស៊ីវ៉ន: នៅ៣១ដែរតាយីម ។

ដានី: ហើយម៉េចដែរគាត់?

ស៊ីវ៉ន: គាត់ហ្នឹងយើងធ្លាប់នៅចឹងអត់អីទេ! ប៉ុន្តែធ្លាប់ឮគេថាគាត់ខូចសីលធម៌ ។

ដានី: ហើយគេយកគាត់ទៅដែរទៅ?

ស៊ីវន: យកទៅដែរទៅ ។

ដានី: ជីនាន់យាយម៉ែនដែរ?

ស៊ីវន: ហ្នឹងហើយ ជីនាន់គ្នាហ្នឹង ។

ដានី: យាយម៉ែន ឈ្មោះគាត់ពេញឈ្មោះអីដែរ?

ស៊ីវន: ម៉ែន ហ្នឹងតែម្តង ។

ដានី: ឈ្មោះម៉ែន ហ្នឹងតែម្តង?

ស៊ីវន: ចា៎! តាគាត់ឈ្មោះស្អីទេ ។

ដានី: អ្នកស្រុកណាគេ តាគាត់?

ស៊ីវន: នៅជិតស្រុកខ្ញុំដែរហ្នឹង នៅជិតវត្តតាខ្មៅហ្នឹង គេហៅភូមិចន្ទារៀល ។

ដានី: ចន្ទារៀល ឃុំពាមដែរ?

ស៊ីវន: ហ្នឹងជិតៗគ្នា ។

ដានី: ចុះតាសារុន?

ស៊ីវន: តាសារុនក៏នៅភូមិខ្ញុំដែរ ។

ដានី: នៅភូមិស្រែអណ្តូង?

ស៊ីវន: ភូមិស្រែអណ្តូង ។

ដានី: តា យឹម?

ស៊ីវន: តា យឹម គាត់នៅត្បែងខ្ពស់ ។

ដានី: ត្បែងខ្ពស់នៅឯណាទៅ?

ស៊ីវន: ចុះពីដើមរាំត្បែងខ្ពស់ មកពីដំណាក់ស្នាច់ ។

ដានី: ក្នុងហ្នឹងគេហៅស្រុកខត្តក្តហ៎?

ស៊ីវន: បាទ! អាហ្នឹងមិនមែនទេ ស្រុកត្បែងខ្ពស់ដូចជានៅឃុំពានា ទេដូចជាឃុំត្បែងខ្ពស់ហ្នឹងតែម្តង ។

ដានី: ខេត្តកំពង់ឆ្នាំង?

ស៊ីវន: ហ្នឹងហើយកំពង់ឆ្នាំង! នៅខាងជើងស្ពានស្ទឹងត្រាចលិច ទៅពីផ្សារត្រាចតិចទៅត្រង់ដល់ត្បែងខ្ពស់ ។

ដានី: ចឹងអឺដល់ពេល ពេលហ្នឹងឆ្នាំ៧២ បានជួបអឺប្រុស គាត់មកមើល?

ស៊ីវន: គាត់មកមើលកន្ទ័ពដេកឈឺនៅពេទ្យ កាលហ្នឹងវាយមួយផ្លូវលេខ៥ ។

ដានី: កាលហ្នឹង មួយជួរផ្លូវលេខ៥ហ្នឹងវាយខ្លាំងដែរ?

ស៊ីវន: វាយខ្លាំង ។ ចាប់ពីព្រំប្រទល់ពោធិ៍សាត់មកទៅដល់ខត្តុគ្គ

ដានី: យើងវាយរំដោះខត្តុគ្គបាននៅឆ្នាំណាទៅ?

ស៊ីវន: ទេ! អត់ចាំទេ ។

ដានី: ចាំថាពេលឆ្នាំ៧២ ហ្នឹងវាយបាននៅ?

ស៊ីវន: នៅទេអត់ទាន់បាន ។ ដូចទំនង ជា៧៤បានវាយខត្តុគ្គ ។

ដានី: ឆ្នាំ៧៤ ហេ៎?

ស៊ីវន: ឈ្នះក៏ចូលនៅពុំបានដែរ ។ យើងនៅប្រទង់ប្រទាញឡើយ ទាល់តែវាយឈ្នះភ្នំពេញបានចូល
បាន ៧៤វាយសម្រុកចូលភ្នំពេញ ។

ដានី: ៧៤ បានវាយសម្រុកចូលភ្នំពេញ ចឹងយើងវាយបានខត្តុគ្គមុន បានយើងវាយចូលភ្នំពេញ?

ស៊ីវន: ចា៎! យើងវាយពីខាងៗទៅ បានសម្រុកទៅ ។

ដានី: ចុះអ៊ីប្រុសកាលឆ្នាំ៧២ មកជួបអ៊ី កាលហ្នឹង គាត់មានតួនាទីអីហើយ?

ស៊ីវន: គាត់វរសេនាតូច ។

ដានី: វរសេនាតូចហេ៎?

ស៊ីវន: ចា៎! តែគាត់ឡើងលឿនណា! ៧២ហ្នឹង វរសេនាតូច, ៧២ ខែប៉ុន្មានទៀតទេឡើងវរ
សេនាធំ ។

ដានី: ៧២ខែប៉ុន្មានទៅ?

ស៊ីវន: កាលហ្នឹងដូចជាខែ៦មិនដឹង ខែ៧មិនដឹង ខ្ញុំអត់សូវច្បាស់ទេណា គ្រាន់ថាស្មានៗមើលដឹងថា
ឡើង៧២ ហ្នឹងដើមឆ្នាំវរសេនាតូច ចុងឆ្នាំវរសេនាធំ ។

ដានី: បាទ! នៅក្នុងភូមិភាគពិសេស ឬក៏ភូមិភាគនិរតី?

ស៊ីវន: អត់ទេ! និរតី នៅកងពលទី១ គាត់ហ្នឹងទាបញ្ញាការ ស្នងការ ។

ដានី: បាទៗ! ដំបូងកាលនៅវរសេនាតូច វរសេនាធំ អត់ទាន់មានកងពលទេ?

ស៊ីវន: នៅ! អត់ទាន់មានទេ នៅវាយៗរៀងៗខ្លួន ។

ដានី: នៅវាយរៀងៗខ្លួនខាងកំពង់ឆ្នាំង?

ស៊ីវន: ចា៎! តែគាត់ប្រធានកងពល វរសេនាតូច ។

ដានី: អនុគាត់ពីណាគេ?

ស៊ីវន: ស្លាប់អស់ដឹងពីណាទេ ខ្ញុំអត់សូវស្គាល់ទេ ព្រោះកាលហ្នឹងរឿងកងទ័ព រឿងគាត់ពុំសូវស្គាល់ទេ
អ្នកនៅជាមួយក៏មិនស្គាល់ដែរ ។

ដានី៖ ចុះតាល្វៃនោះអី?

ស៊ីវន៖ តាល្វៃនោះក្រោយមកទេ ។

ដានី៖ មិនមែននៅជាមួយគ្នាតាមរហូតទេ?

ស៊ីវន៖ មិនមែនទេ!

ដានី៖ តាធួក?

ស៊ីវន៖ តាធួកហ្នឹងក៏ចឹងដែរ ។

ដានី៖ ក្រោយមកទេ!

ស៊ីវន៖ ក៏ផ្សេងៗគ្នា! គាត់នៅកងទ័ពស្រុកកងទ័ពអីចឹង ។

ដានី៖ ហើចុះអ៊ឹ កាលនៅកំពង់ត្រឡាចនៅក្នុងតំបន់៣១ទេកាលហ្នឹងណ៎?

ស៊ីវន៖ ចា៎! ខេត្តកំពង់ឆ្នាំង ។

ដានី៖ ចុះអ៊ឹដែលឮឈ្មោះហំទេ?

ស៊ីវន៖ ហំ?

ដានី៖ បាទ!

ស៊ីវន៖ ហំរាល់ថ្ងៃហើយហ្នឹង?

ដានី៖ ហំកាលហ្នឹង គាត់ធ្វើក្នុងគណៈតំបន់ ។

ស៊ីវន៖ អូ! អត់សូវស្គាល់ទៅនៅក្នុងភូមិភាពពិសេស ។

ដានី៖ នៅភូមិភាពពិសេស ធ្លាប់ឮឈ្មោះគាត់ដែរ?

ស៊ីវន៖ ឮតែអត់សូវស្គាល់ យើងធ្វើការតូចតាចចឹងពុំសូវស្គាល់ទេ ។

ដានី៖ បាទ! ចឹងអ៊ឹប្រុសដល់ពេលខែ៦ ខែ៧ គាត់ឡើងវរសេនាធំ ហើយកងពល ឡើងជាកងពលឆ្នាំណាទៅ?

ស៊ីវន៖ ៧៤ ។

ដានី៖ ៧៤ ហ៎?

ស៊ីវន៖ ៧៣, ៧៤ គាត់ឡើងកងពល ។

ដានី៖ ៧៣, ៧៤ គាត់ឡើងកងពល ។

ស៊ីវន៖ នៅក្នុងគណៈកងពលគាត់ កងពលទីមួយ ។

ដានី៖ ចឹងបានន័យថាមិនមែនតែគាត់ម្នាក់ទេ?

ស៊ីវនៈ  មិនមែនទេ មានគេមានឯងទៀត ប៉ុន្តែមិនដឹងនរណាប្រធានទេខ្ញុំអត់ច្បាស់ទេណា៎ ។

ដានីៈ  ហើយគាត់បញ្ជាការ?

ស៊ីវនៈ  ប៉ុន្តែ គាត់ទទួលបង្រៀនអប់រំគេនៅក្រោយដែរ បញ្ជាការមិនទាន់សួរចេះណា ។

ដានីៈ  បង្រៀនគេនៅខាងក្រោយទៀតហ៎! បើតាមខ្ញុំធ្លាប់ជួប ធ្លាប់សម្ភាសន៍ផ្សេងៗមកគេថាក្នុង គណៈបញ្ជា ការកងពលទី១ហ្នឹង មានឈ្មោះ តា សឿង?

ស៊ីវនៈ  ត្រូវហើយ តាសឿង គាត់ប្រធាន ។

ដានីៈ  តាសឿង ហ៎?

ស៊ីវនៈ  គាត់ធ្វើពេទ្យស្រុក ប៉ុនកាលហ្នឹង!

ដានីៈ  កាលហ្នឹង គេហៅគាត់ពេទ្យសឿងៗ?

ស៊ីវនៈ  គាត់ធ្វើពេទ្យតាំងពីយូរចឹងមក ពេទ្យហ្នឹង ដូចថាគាត់ចេះចាក់ថ្នាំ ចេះមើលចឹងណា ដល់មក ក្រោយ មកគាត់ឡើងប្រធាន ស្រុកគាត់នៅតាកែវ ។

ដានីៈ  អ្នកតាកែវ?

ស៊ីវនៈ  អ្នកតាកែវ!

ដានីៈ  អ្នកស្រុកណា ស្រុកគាត់?

ស៊ីវនៈ  ដឹងនៅស្រុកណាអត់ច្បាស់ទេ! អត់ដឹងទេ គ្រាន់តែដឹងថានៅខេត្តតាកែវ ឥឡូវកូនគាត់នៅ ប៉ៃលិន ។

ដានីៈ  កូនគាត់នៅប៉ៃលិន? កូនគាត់ឈ្មោះអីទៅ?

ស៊ីវនៈ  កូនប្រុសឈ្មោះ គេហៅអាមុះៗ! មិនដឹងស្អីមុះទេ ខ្ញុំមិនច្បាស់ទេ មានប្រពន្ធនៅប៉ៃលិនហ្នឹង អូ! រកស៊ីធូរធារបស់វា ។

ដានីៈ  នៅប៉ៃលិន?

ស៊ីវនៈ  រាល់ថ្ងៃនៅប៉ៃលិន ។ ស្រីមួយទៀតឈ្មោះឡេនទៅប៉ៃលិនដែរ ហើយអាមួយទៀតអត់ដឹង នៅឯណាទេ ។

ដានីៈ  បាទ! ឈ្មោះឡេនស្រីនៅប៉ៃលិន ។

ស៊ីវនៈ  តែគាត់ស្លាប់ហើយ ។

ដានីៈ  គាត់ស្លាប់ឆ្នាំណាហើយ?

ស៊ីវនៈ  ស្លាប់ឆ្នាំ៧៩ ។

ដានីៈ  ៧៩ហ្នឹងស្លាប់?

ស៊ីវន: មិនដឹង យ៉ាងម៉េចដែរ ។

ដានី: គាត់ចាស់ហើយពីជំនាន់នោះ?

ស៊ីវន: មិនចាស់ប៉ុន្មានទេ! ប្រហែលអាយុថា៦០ចុះ ហ៎តែពុំដល់ទេប្រហែលជា៥០ ។

ដានី: អូ! ៥០ ។ បាទ! ចឹងពេទ្យសៀង១ដោយសារគាត់ធ្វើពេទ្យចេះពេទ្យចិន គេហៅគាត់ពេទ្យសៀង១, ដំបូងខ្ញុំស្មានតែត្រកូលគាត់ពេទ្យ ។

ស៊ីវន: អត់ទេ! នរណាឈឺល្មម១អីគាត់ចាក់ថ្នាំចាក់អីឲ្យ ។

ដានី: អូ! គាត់ចេះចាក់ខ្លួនឯងទៀត ស្រុកកំណើតគាត់នៅតាកែវ?

ស៊ីវន: នៅតាកែវ ។

ដានី: ស្រុកនៅជាមួយ តាម៉ុកអីដែរ?

ស៊ីវន: ហ្នឹងហើយ ប្រហែលជាហ្នឹង ខ្ញុំអត់ច្បាស់ទេ ។

ដានី: ហើយចុះតាសៀង អ៊ំប្រុស ពីណាទៀតបន្ទាប់ពី?

ស៊ីវន: តា សារី! ឈ្មោះ តាសារី ពីដើមគេកម្រដាក់នាមត្រកូលណាស់ គេអត់ស្គាល់ ។

ដានី: គេហៅតាសារី?

ស៊ីវន: ចា៎! គេហៅតាចឹងតែម្ដង ។

ដានី: ចុះអ៊ំស្គាល់តាសាន គាត់នៅវាលវែង?

ស៊ីវន: តាសាន?

ដានី: តាសាន គាត់នៅក្នុងកងពលហ្នឹងដែរអត់ទេ?

ស៊ីវន: ដូចអត់ទេ! គាត់នៅភូមិភាគពិសេស ។

ដានី: កែវ សាន ។

ស៊ីវន: កែវ? អត់ស្គាល់ជីតាទេ តែស្រុកគាត់នៅឯណា?

ដានី: ស្រុកគាត់អ្នកកំពង់ស្ពឺ ។

ស៊ីវន: អូ! តាសានហ្នឹង គាត់វៀងថ្ងាសធំតិច ។

ដានី: បាទ១!

ស៊ីវន: ហ្នឹងស្គាល់ ។

ដានី: គាត់នៅក្នុងដែរអត់ទេ?

ស៊ីវន: គាត់ដឹងនៅកងណាអីណាទេ អត់សួរច្បាស់ទេ កាលហ្នុង ។

ដានី: គាត់នៅ៨មុំ?

ស៊ីវនៈ ចា៎! ដូចនៅភូមិភាគពិសេស តាហ្នឹង ។

ដានីៈ ចុះតាវឿន?

ស៊ីវនៈ តាវឿន ស្លាប់ហើយហ្នឹង ។

ដានីៈ តាវឿន?

ស៊ីវនៈ ឥឡូវនៅ?

ដានីៈ គាត់នៅខាងថ្មដែកកេះ នៅខាងបន្ទាយឆ្មារ ។

ស៊ីវនៈ អត់ស្គាល់ទេ ។

ដានីៈ ចុះអ៊ីនៅកំពង់ត្រឡាចដល់ឆ្នាំណាទៅ?

ស៊ីវនៈ នៅកំពង់ត្រឡាចដល់ឆ្នាំ៧២ ៧៣ខ្ញុំទៅនៅតំបន់៣១ គេឲ្យធ្វើប្រធានពេទ្យនៅតំបន់៣១ ។

ដានីៈ ធ្វើប្រធានពេទ្យនៅតំបន់៣១វិញ ។ ចឹងអ៊ីឆ្នាំ៧៣ អ៊ីផ្លាស់ទៅប្រធានពេទ្យនៅតំបន់៣១នៅឯណា?

ស៊ីវនៈ នៅម្តុំ កាលហ្នឹងគេដាក់នៅជិទាវជ្រែងក្រាំងល្វា ។

ដានីៈ នៅឯណាទៅ?

ស៊ីវនៈ នៅភូមិក្រាំងល្វា, ជិទាវជ្រែង!

ដានីៈ ជិទាវជ្រែង ក្រាំងល្វា ។

ស៊ីវនៈ ចា៎! ម្តុំហ្នឹង ។

ដានីៈ នៅហ្នឹង! ក្នុងស្រុកអីគេទៅ?

ស៊ីវនៈ ស្រុកកំពង់ត្រឡាច ហា៎ទឹកផុស ឬក៏ស្អីត្រង់ហ្នឹងភ្លេចហើយ ហា៎មើលស្រុកស្អីទេ ឬក៏កំពង់ឆ្នាំង មិនដឹងស្អីទេ ។

ដានីៈ បាទៗ!

ស៊ីវនៈ ឥឡូវៗ មិនដាក់ចូលទៅក្នុងស្អី ។

ដានីៈ ចឹងអ៊ីអត់ដែលនៅជុំជាមួយអ៊ីប្រុសទេ?

ស៊ីវនៈ អត់បែកគ្នារហូត! សម័យហ្នឹងគេគ្មាននៅជុំគ្នា ។

ដានីៈ ប៉ុន្តែអ៊ីអត់ទាន់ មានកូនទៅទេកាលហ្នឹង?

ស៊ីវនៈ ៧២ បានមាន, នៅជុំគ្នាម្តង បានមានកូន១ អាមួយឈ្មោះស៊ីវត្ថាហ្នឹង ៧៣បានសម្រាល បេ-៩២ ទម្លាក់ ។

ដានីៈ ចឹងដល់ឆ្នាំ៧៣ បាន បានកូន១?

ស៊ីវន: ចាំ! បានកូន១ ។

ដានី: ឈ្មោះ ស៊ីវុត្ថា, គាត់ស្លាប់ឆ្នាំណាទៅ?

ស៊ីវន: ស្លាប់ឆ្នាំ៧៨, តូចហ្នឹង ស្លាប់នៅតូច ។

ដានី: អូ! ស្លាប់តាំងពីតូច ។

ស៊ីវន: យើងអត់បានមើលគាត់យកទៅផ្ញើរម្តាយគាត់ ។

ដានី: ចឹងដល់ពេលអ៊ំចេញទៅពេទ្យទៅ គាត់ធ្វើកងទ័ព កូនយកទៅផ្ញើរ?

ស៊ីវន: កូនយកទៅផ្ញើរម្តាយនៅផ្ទះ ។

ដានី: ម្តាយគាត់ ឬក៏ម្តាយអ៊ំ?

ស៊ីវន: ម្តាយគាត់ ។

ដានី: ម្តាយគាត់ហ៎?

ស៊ីវន: ចាំ! ឃើញខ្ញុំពិបាក កប៉ាល់ហោះវាយពេក ។

ដានី: អ៊ំដល់ពេល អ៊ំបានរៀនពីលោកតា ជួន ជឿនអ៊ី ចឹងអ៊ំចេះច្រើនទេ ខាងជំងឺអី?

ស៊ីវន: មិនច្រើនប៉ុន្មាន! ប៉ុន្តែគ្រាន់ថាយើងអាចទទួលខុសត្រូវមើលមួយកន្លែងៗហ្នឹងបាន ។

ដានី: បាទ! ហើយកាលពី ដូចថាតាំងពី៧២,៧៣អីការងារពេទ្យយ៉ាងម៉េចដែរ ដូចថាសម្បូរអ្នកជំងឺភាគច្រើនអ្នកជំងឺយ៉ាងម៉េច?

ស៊ីវន: នៅពេទ្យ ខ្ញុំអត់និយាយកុហកទេ និយាយឲ្យត្រង់តែម្តង គេដូចថាយើងខំធ្វើល្អត្រឹមត្រូវអត់ធ្វើបាបអ្នកជំងឺអីទេណា ដល់ចឹងអ្នកជំងឺទាំងអស់គឺចូលចិត្ត ហើយគេស្រលាញ់គោរពយើង ព្រោះមានថ្ងៃប្រជុំ ១០ថ្ងៃម្តងៗ ដល់ចឹងក្នុងកងទ័ពមានរបៀបរៀបរយអីចឹង ហើយកងទ័ពទាំងអស់ដល់អីចឹងបានមេបញ្ជាការគេចុះមកមើល ហើយមើល ស្តាប់កូនទាហានរាយការណ៍ បើរាយការណ៍មិនល្អ យើងហ្នឹងធ្វើការមិនល្អ ប៉ុន្តែភាគច្រើនគេរាយការណ៍ល្អ ។

ដានី: ប៉ុន្តែ៧៣អីអ៊ំប្រុសគាត់នៅសមរភូមិក្បែរៗហ្នឹងដែរ?

ស៊ីវន: ចាំ! គាត់ទៅមកៗ បានមួយខែអី ឃើញមកអើតកងទ័ពមួយភ្លែតចឹងទៅពេលវាយខ្លាំងណាំវាយធំគេមកហើយ មេៗគេឡើងមក ។

ដានី: អ៊ំជាប្រធានពេទ្យនៅតំបន់៣១ហ្នឹងដល់ឆ្នាំណា?

ស៊ីវន: ឆ្នាំ៧៨!

ដានី: ដល់៧៨ទៅណាវិញទៅ?

ស៊ីវន: ៧៤ទៅនៅពេទ្យប្រចាំកងពលគាត់វិញ ពេទ្យភូមិភាគ, ពេទ្យភូមិភាគប្រចាំកងពលទី១ អ្នករបួសច្រើនកាលហ្នឹង ។

ដានី: អាហ្នឹងភូមិភាគអីគេ?

ស៊ីវន: ភូមិភាគនិរតី ប្រចាំកងពលទី១ ។

ដានី: កងពលទី១ អាហ្នឹងអ្នករបួស ដល់ពេលចាប់ផ្តើមវាយខ្លាំងហើយណ៎?

ស៊ីវន: វាយខ្លាំង! វាយចូលភ្នំពេញ ។

ដានី: កាលហ្នឹងអីប្រធានពេទ្យកងពល?

ស៊ីវន: ខ្ញុំធ្វើប្រធានពេទ្យ ។

ដានី: ចុះអនុអីវិញ?

ស៊ីវន: អនុ ទៅណាអស់ទេ! ប្រុសស្លាប់បាត់ហើយដឹង ។

ដានី: ពីណាគេ?

ស៊ីវន: ឈ្មោះឡេន ហើយអត់ស្គាល់ជីតាទេ ឡេនហឹងគាត់ធ្វើកងទ័ពដែរ ដល់!

ដានី: មិនមែនឡេនកូន តា សឿង ទេ?

ស៊ីវន: មិនមែនទេ! ឡេនផ្សេងទៀត ឡេនប្រុស ។

ដានី: បាទ! ហើយដល់ពេលហ្នឹងធ្វើពេទ្យប្រចាំកងពលអីចឹង កងពលទៅណា អីទៅហ្នឹងដែរ?

ស៊ីវន: យើងធ្វើមន្ទីរពេទ្យធំ អត់ទៅណាទេ ។

ដានី: មន្ទីរពេទ្យប្រចាំកងពលទី១នៅណាទៅ?

ស៊ីវន: មន្ទីរពេទ្យធំ កាលហ្នឹងដាក់នៅច្រកស្តេច ជិតស្រែអណ្តូងដែរតើ ។

ដានី: ជិតស្រែអណ្តូងហ្នឹងដែរ?

ស៊ីវន: ចាំ! មន្ទីរពេទ្យគេចែកអីចេះ ទី១គេវះកាត់នៅខាងមុខធ្វើនៅអន្លង់ចំណា ពីមុនត្រង់ហ្នឹងវះកាត់មួយអ្នកជំងឺប្រហែលជា ២០០, ៣០០ទេ ។ បន្ទាប់មកទៀត មានមួយទៀតសម្រាប់ប្រជាជន សម្រាប់ជំងឺទូទៅប្រហែលជា១០០០អីហ្នឹង ។ មួយចំហៀងទៀតរបួសប្រហែលជា ២០០០ ។

ដានី: ប៉ុន្តែ នៅពេលដែលយើងរបួសខ្លាំងអី មន្ទីរពេទ្យអីអ្នកមើល ឬក៏យើងបញ្ជូនទៅខាងណាទៀត?

ស៊ីវន: ដល់មកនៅភូមិភាគហ្នឹងអត់ទេ! កន្លែងវះកាត់ហ្នឹងតា ជួន ជឿន គាត់បង្រៀនបានអ្នកចេះវះអីអស់ហើយហ្នឹង គេវះ គេមើលនៅមុខ មើលរឿងអីគេបញ្ជូនមកកន្លែងខ្ញុំនៅ ការពិតយើង

នៅទទួលទាំងអស់ហ្នឹង ។ វះកាត់ហ្នឹងក៏យើងមើល យើងមើលអាកន្លែងហ្នឹងក៏យើងមើល មើលទាំងអស់ តែគ្រាន់តែមើលទេណា មើលទទួលខុសទទួលត្រូវ ។ ហើយ តា ជួន ជឿន គាត់នៅកន្លែងផ្សេងទេ គាត់ទៅភូមិភាគពិសេសវិញ ។

ដានី: តា ជួន ជឿន ចរិកគាត់យ៉ាងមេចដែរ បើតាមអ៊ីយល់?

ស៊ីវន: គាត់ត្រឹមត្រូវណាស់ ។

ដានី: គាត់ត្រឹមត្រូវហ៎?

ស៊ីវន: ចា៎! មនុស្សគាត់ហ្នឹង និយាយរួមមេទាំងអស់ខ្ញុំមិនចេះតែថាទេ គាត់ត្រឹមត្រូវទាំអស់ ។ គាត់អត់មាន ដូចថាប្រលឹសបឹសកោងកាចអីអត់ទេ ជាមួយយើងហ្នឹងរាបសារណាស់ ។

ដានី: សីលធម៌គាត់ល្អម៉ង?

ស៊ីវន: ល្អណាស់ចា៎ស! គាត់អត់ចេះនិយាយអញ អីឯញទេ បាទ ខ្ញុំហើយសំដីសំដៅគាត់ទន់ភ្លន់ណាស់ របៀបថាអ្នកចេះអ្នកដឹងតែម្តង ហើយយើងទាំងអស់គ្នាគោរពគាត់ណាស់ ។

ដានី: គាត់អត់ចេះនិយាយមើលមនុស្ស ឬក៏អ្នកអត់ចេះអត់អី អីអ្នកស្រែអ្នកអីអត់?

ស៊ីវន: មិនថាចឹងទេ! ឆ្ងល់បងប្អូនឆ្ងល់ច្រើនសួរ គាត់វែកញែក ហើយគាត់សួរថាយល់ឬនៅ! ហើយគាត់បង្រៀនទៀត ។

ដានី: គាត់អត់ខឹងយើងទេពេលដែលបង្រៀនយើងហើយ យើងអត់យល់អត់អី?

ស៊ីវន: អត់ខឹងទេ! ទាល់តែច្រើនសារ ១០, ២០ដងអី អាហ្នឹងបានគាត់សំឡុតតិចហើយ អាហ្នឹងវាល្មមគាត់សំឡុតហើយ វាហត់គាត់ហើយណា ។ ប៉ុន្តែអ្នកដែលយកចិត្តទុកដាក់ តែម្តងពីរដងគេចាំអស់ ។

ដានី: អ៊ឺបើតាមអ៊ីចាំ ឆ្នាំ៧/៨ហ្នឹងនៅភូមិភាគនិរតីមានប៉ុន្មានកងពលទៅ?

ស៊ីវន: កាលហ្នឹងមានកងពល ទី១,២,៣ ។

ដានី: ទី១,ទី២,ទី៣ទេ ។

ស៊ីវន: ផ្សេងទៀតអត់ច្បាស់ទេណា?

ដានី: បាទ! ទី១ តាសឿង, អ៊ឺប្រុស, ហើយសារី គាត់ធ្វើគណៈកងពល, ទី២?

ស៊ីវន: ទី២ដឹងតែតា ប៊ិត, សំ ប៊ិតនោះ ហើយហ្នឹងតាវ៉ែន ។

ដានី: តា ប៊ិត,!

ស៊ីវន: ដឹងតែ២ទេណា, ៣មិនដឹងណាទេ ។

ដានី: តាប៊ិត, តាវ៉ែន, តាវ៉ែន កូនប្រសារតាម៉ុកហ្នឹង?

ស៊ីវ៉ន: កូនប្រុសតាម៉ុកហ្នឹង ។

ដានី: អូ! បាទ! ដឹងតែ២នាក់?

ស៊ីវ៉ន: ចា៎! ដឹងតែ២ ។

ដានី: ទី៣?

ស៊ីវ៉ន: អត់ដឹង! អូ! កងពលទី៣, មាស មុត ។

ដានី: បាទ! តា មុត, មាស មុត ។

ស៊ីវ៉ន: តា មុត អនុមិនដឹងដែរ អត់ច្បាស់ទេ ។ កាលហ្នឹងគេទៅចិន ទៅអីត្រឡប់មកវិញ ទាល់តែសួរ តា មុត បានច្បាស់ អត់ពិបាកទេទៅជួបគាត់ ។

ដានី: ចុះតារិន?

ស៊ីវ៉ន: ឈូក រិនហ្នឹង!

ដានី: មាននៅក្នុងកងពលជាមួយ តា មុត ទេ?

ស៊ីវ៉ន: អត់ទេ! អត់ដែរស្គាល់ទេ ។

ដានី: ចាំតែ តាមុត ទេណ៎?

ស៊ីវ៉ន: ស្គាល់តាមុតច្បាស់តែម្ដង ដឹងថាក្រោយមកកងពលទី៣ទៅនៅខាងកងជើងទឹក នៅកំពង់សោម ។

ដានី: បាទ! ហើយកាលហ្នឹងគណៈភូមិភាគនិរតីពីណាខ្លះ?

ស៊ីវ៉ន: ដឹងតែតា ម៉ុក ហ្នឹងមួយ ក្រៅពីនេះអត់ច្បាស់ទេ ។

ដានី: ដឹងតែតា ម៉ុក មួយទេណ៎?

ស៊ីវ៉ន: ចា៎!

ដានី: ចុះឪពុកក្មេកអ៊ីមានធ្លាប់ធ្វើជាគណៈភូមិភាគនិរតីទេ កាលពីមុនមក?

ស៊ីវ៉ន: អត់ដឹងផង! គាត់ស្លាប់មុនយូរហើយ ។

ដានី: គាត់ស្លាប់តាំង៦៨មកអ៎េ?

ស៊ីវ៉ន: តាំងពី៦៨ ដល់ក្រោយមកគេរៀបចំក្រោយអត់ដឹង ។

ដានី: ចឹងអី! ពីឆ្នាំ៧៤ទៅកាលហ្នឹងអ៊ីមកធ្វើពេទ្យពីខែប៉ុន្មាន?

ស៊ីវ៉ន: ដូចមកខែ៣ ហ៎ដូចជាមិនមែនទេ! ឈ្នះឆ្នាំនោះថ្ងៃទីប៉ុន្មានទេ មកដល់ប៉ុន្មានថ្ងៃឈ្នះភ្នំពេញដែរ ដូចជាថ្ងៃទី១៧ហ៎ឈ្នះ?

ដានី: ឈ្នះទីក្រុងភ្នំពេញ ឈ្នះថ្ងៃទី១៧ ខែ៤ ឆ្នាំ៧៥ ។

ស៊ីវនៈ ត្រូវហើយ ខ្ញុំមកទំនងជាខែ៣ ។

ដានីៈ ខែ៣ ឆ្នាំ?

ស៊ីវនៈ ខែ៣,៧៤ ។

ដានីៈ ខែ៣,៧៤! ពេលហ្នឹងកងពលបង្កើតបានយូរដែរនៅ ពេលដែរ?

ស៊ីវនៈ យូរដែរហើយ!

ដានីៈ បានប្រហែលជា?

ស៊ីវនៈ រាប់ឆ្នាំ! ចុះតាំងពី៧០ វាចេះតែវាយចូលតាំងពី៧៣មក កងពលបណ្តើរៗមក ។

ដានីៈ ៧៣មកបង្កើតជាកងពលបណ្តើរៗ?

ស៊ីវនៈ ចាំ! មានបណ្តើរៗហើយ ។

ដានីៈ ដល់ពេល៧៤អីអ៊ឹបានកូនប៉ុន្មាននាក់ទៀតហើយ?

ស៊ីវនៈ អត់ទេ! តាមួយហ្នឹង ។

ដានីៈ តាមួយហ្នឹង! អូ!

ស៊ីវនៈ ទាល់តែ៧៦ បានមានមួយទៀត ។

ដានីៈ ទាល់តែ៧៦ បានមាន១ទៀត បាទ!

ស៊ីវនៈ ៧៦ មាន១ ដល់៧៨បានមានមួយទៀត រត់៧៩បណ្តោយ ដើរមក៨២បានមាន,៨៤, ៨៩អស់ហើយ ។

ដានីៈ ចុះអ៊ឹពេលដែលយើងរំដោះបានទីក្រុងភ្នំពេញឆ្នាំ៧៥ កងពលរបស់អ៊ឹចូលតាមណាទៅ?

ស៊ីវនៈ កងពលគាត់ចូលតាមម្តុំថ្នាតពងទៅ វាយម្តុំហ្នឹង វាយផ្លូវជាតិលេខ ២៦ ឬក៏៥៦តាំ? ២៦ ផ្លូវហ្នឹង ផ្លូវបាត់ឌឹង ។

ដានីៈ ផ្លូវ៥៦!

ស៊ីវនៈ ផ្លូវ៥៦ ។

ដានីៈ ៥៦! ខ្ញុំអត់សូវច្បាស់ដែរ ប្រហែលមិនមែន២៦ទេ ។

ស៊ីវនៈ ខ្ញុំកាលហ្នឹងពុតែគេហៅចាំដែរ ដល់យូរទៅភ្លេចគិត ។

ដានីៈ ចឹងចូលតាមហ្នឹងវិញណាំ! អ៊ឹដល់ពេលកងពលចូល យើងជាពេទ្យ យើងចូលតាមចល័តទៅតាមកងទ័ពដែរ?

ស៊ីវនៈ ចេះតែទៅ កងអ្នកវះកាត់ហ្នឹង ចេះតែលើកទៅ ចល័តទៅ ។

ដានី៖ យើងខបមាថាទាហាន កងទ័ពពេលដែលត្រូវរបួស ត្រូវអីអើ ដូចជាថ្នាំពេទ្យសម្ភារៈផ្សេងៗ ដូចថាព្យាបាលវ៉ះកាត់អីហ្នឹងយើងបានពីណាមក?

ស៊ីវន៖ ចិន!

ដានី៖ ចិន! កាលជំនាន់ហ្នឹង មានចិនជួយទេ?

ស៊ីវន៖ ចិនជួយ, ជួយរហូតទាំងកាំភ្លើងទាំងអី ។

ដានី៖ ទាំងកាំភ្លើងទាំងថ្នាំពេទ្យណ៎?

ស៊ីវន៖ ទាំងអស់ ទាំងការស្លៀកពាក់ ។

ដានី៖ កាលហ្នឹង កងពលរបស់អ៊ំ គាត់មានរថក្រោះរថអីដែរ?

ស៊ីវន៖ មាន!

ដានី៖ មានប៉ុន្មានគ្រឿង?

ស៊ីវន៖ អត់ច្បាស់ទេ, គ្រាន់តែដឹងថាមាន រថក្រោះក៏មាន ស្អីក៏មានគ្រប់ទាំងអស់ ឡានអី ។

ដានី៖ ចុះអ៊ំកងពលអីដូចថាត្រូវរបួសត្រូវអី ត្រូវដៃត្រូវជើង ពិការដៃពិការជើងហើយ ពេលយើងព្យាបាលជាហើយ យើងឲ្យគាត់មកកងទ័ពវិញដដែរ ឬក៏គាត់ទៅកន្លែងផ្សេង?

ស៊ីវន៖ អត់ទេ! គេរៀបចំដាក់មុំ ។

ដានី៖ គេដាក់មុំ?

ស៊ីវន៖ ចា៎! យកទៅ គេរៀបចំធ្វើផ្ទះធ្វើអីកន្លែងនោគេផ្គត់ផ្គង់ទាំងអស់ ទាំងអស់តែម្តងអត់មាន ។

ដានី៖ គេហៅមន្ទីរពិការ?

ស៊ីវន៖ រៀបចំគ្រួសារអីឲ្យ ធ្វើផ្ទះឲ្យ ហើយរបបហូបចុកអីមានទាំងអស់ អត់មានខ្វះ ។

ដានី៖ នៅក្នុងកងពលហនឹងដដែរ?

ស៊ីវន៖ នៅកងពលហ្នឹងដដែរ! តែគេរៀបដាក់មួយដុំ ដល់ពេលគេនេះ គេប្រមូលពីគ្រប់កងពលមកដាក់មុំទៀត ។

ដានី៖ អ៊ំកងពលទី១មានប៉ុន្មានវរសេនាធំទៅ?

ស៊ីវន៖ ៣វរសេនាធំ តែនៅមានកងពិសេសទៀតណា៎ ខ្ញុំអត់ច្បាស់ទេ ។

ដានី៖ ៣វរសេនាធំ ហើយកងពិសេស ។

ស៊ីវន៖ យើងអត់ច្បាស់ទេ អង្គភាពទ័ពហ្នឹង ។

ដានី៖ វរសេនាធំក៏បាន វរសេនាធំមានលេខប៉ុន្មានដែរ?

ស៊ីវន៖ អត់ដឹងទេ!

ដានី៖ ប្រធានវរសេនាធំ?

ស៊ីវ៉ន៖ ស្លាប់អស់ហើយ អត់ច្បាស់ទេ ចាំតែម្នាក់ហ្នឹងស្លាប់បាត់ហើយ អស់រលីង ។

ដានី៖ ឈ្មោះអីគេ?

ស៊ីវ៉ន៖ បង ល្វៃ ហ្នឹង វរសេនាធំហើយ ។ តា ល្វៃ មួយ តា ឡូញនោះពីរ ហើយមួយទៀត ដឹង ឈ្មោះអីទេ អត់ច្បាស់ ដឹងត្រួសៗទេ ខ្ញុំអត់ច្បាស់ទេ ។

ដានី៖ ចឹងដល់ពេលចូលឆ្នាំ ៧៥ ចូលតាមថ្នាតពងទៅដល់ត្រង់ណាទៅពេលយើងរំដោះ?

ស៊ីវ៉ន៖ ពោធិ៍ចិនតុង វាយសំដៅពោធិ៍ចិនតុង ។

ដានី៖ វាយសំដៅពោធិ៍ចិនតុង!

ស៊ីវ៉ន៖ ផ្ទះខ្ពស់!

ដានី៖ ផ្ទះខ្ពស់កន្លែងក្នុងព្រលានយន្តហោះតែម្តង?

ស៊ីវ៉ន៖ ចា៎! គាត់ទៅកាប់នៅហ្នឹងតែម្តង ។

ដានី៖ បាទ! ប៉ុន្តែទៅដល់ភ្លាមនៅហ្នឹងភ្លាម?

ស៊ីវ៉ន៖ ទៅដល់ភ្លាមនៅហ្នឹងភ្លាម ។

ដានី៖ ដល់ភ្លាមពេទ្យអីនៅណាទៅ?

ស៊ីវ៉ន៖ ពេទ្យនៅហ្នឹង ពេទ្យនៅក្រោយដដែរទេ តែគ្រាន់តែអ្នកដែលជាអី ដឹកឡានទៅប្រគល់ឲ្យកង ទ័ពវិញ ។

ដានី៖ គាត់ចូលដល់ភ្លាម ដល់ពោធិ៍ចិនតុងតែម្តង?

ស៊ីវ៉ន៖ ពោធិ៍ចិនតុងម្តុំហ្នឹង ត្រង់ហ្នឹងទាំងអស់ហ្នឹង, តាំងពីកំបូល,បែកចានអីចឹងមកហូរហែរមក ។

ដានី៖ កងទ័ពកាលហ្នឹងច្រើន?

ស៊ីវ៉ន៖ ច្រើន! កងពលពេញតែម្តងអត់មានខ្វះទេ ។

ដានី៖ ពេញប៉ុន្មានបើនិយាយ?

ស៊ីវ៉ន៖ ពេញបើនិយាយទៅមួយក្រុមវា១២នាក់ ១អនុសេនាតូច ១២គុណ៣ដងទៅ?

ដានី៖ ៣៦!

ស៊ីវ៉ន៖ ហ្នឹងហើយ៣៦ ទៅ៤០ ។

ដានី៖ ដល់ពេលអនុសេនាធំ?

ស៊ីវ៉ន៖ អនុសេនាធំ ៣អនុសេនាតូច ពេញបឹបអត់មានខ្វះទេ, វរសេនាធំ ៣វរសេនាតូចស្មើរ១វរ សេនាធំ ។ ៣វរសេនាធំស្មើរ១កងពល ។

ដានី៖ ហើយក្នុងនោះវាមានកងពិសេសដាច់ឡែកពីគ្នាទៀត កងអន្តរាគមន៍ កងអី?

ស៊ីវន៖ ចា៎! កងផ្សេងទៀត អត់ច្បាស់ទេ, របនាសម្ព័ន្ធគេអត់ដឹងទេ ។

ដានី៖ ចុះអឹពេលដែលយើងរំដោះបានទីក្រុងភ្នំពេញ ឆ្នាំ៧៥ទៅហើយ អឹចូលទៅខែថ្ងៃណាទៅ?

ស៊ីវន៖ ថ្ងៃ ចូលទៅថ្ងៃមើល, ខ្ញុំគិតមេដៃទៅដូចជាថ្ងៃទី១៩ ។

ដានី៖ រំដោះបាន២ថ្ងៃហើយហ៎?

ស៊ីវន៖ ចា៎!

ដានី៖ ថ្ងៃ១៧បានគេរំដោះ!

ស៊ីវន៖ ចា៎! ថ្ងៃ១៩ខ្ញុំទៅដល់ដែរ ដឹកអ្នកឈឺ ដឹកកងទ័ពជាៗទៅ ។

ដានី៖ យកអីដឹងទៅ?

ស៊ីវន៖ ដឹកឡាន ហ្សេ-អ៊ឹម-សេ ។

ដានី៖ ហ្សេ-អ៊ឹម-សេ? អ្នកជំងឺច្រើនកាលហ្នឹង?

ស៊ីវន៖ អ្នកជំងឺ៣០០-៤០០ដឹកទៅ ។

ដានី៖ ប៉ុន្មានឡានទៅចឹង?

ស៊ីវន៖ មើលមួយឡាន ចេះតែនាំគ្នាជិះឈរ បានច្រើនតើ ។

ដានី៖ បើចឹង៣០០,៤០០ដឹក?

ស៊ីវន៖ ដឹក៥ឡានអីអស់ហើយ ។

ដានី៖ យើងដឹកទៅ ហើយដឹកមកវិញ ឬក៏មានឡាន៥ទៅ?

ស៊ីវន៖ អត់ទេ! ឡានហ្នឹងថាយើងត្រូវការដឹកចឹង គេឲ្យឡានមកដឹក យើងចង់ទៅជាមួយក៏ទៅ បើយើងមិនចង់ទេក៏ហីទៅ តែភាគច្រើនយើងទៅជាមួយដើម្បីទៅរាយការណ៍ឲ្យគេ ។

ដានី៖ ហើយ! ចឹងថ្ងៃ១៩ អឹមកនៅទីណាទៅ?

ស៊ីវន៖ ខ្ញុំទៅតែមួយភ្លែត គ្រាន់តែជូនអ្នកនេះទៅ នៅផ្ទះខ្ពស់ ។

ដានី៖ នៅផ្ទះខ្ពស់?

ស៊ីវន៖ ចា៎! គាត់ចេញចូលហ្នឹង ចេះតែចេញចូលជាមួយគេក្មេងៗទៅ ជាមួយអ្នកបើកឡាន ។

ដានី៖ អឹ! ខ្ញុំមានចម្ងល់បន្តិចដល់ពេលដល់ថ្ងៃ១៧,១៨,១៩អីហ្នឹងក្រែង ដូចថាតាមផ្លូវវាសង្អៀតអ្នកជម្លៀសអីមកហ្នឹង?

ស៊ីវន៖ ហ្នឹងហើយអ្នកជម្លៀសដើរចឹងទៅ ។

ដានី៖ យើងបើកឡានចូលទៅរួចដែរ?

ស៊ីវ៉ន: រួច! អត់អីទេ គ្នាចៀសអីចឹងទៅណា ។ អូ! ខ្ញុំដឹកឡានអំពៅពេញឡាន បានចែកឲ្យគ្នាតាមផ្លូវ កាលហ្នឹងអំពៅយើងដាំបានពីកំពង់អី ៨មុំ ។

ដានី: ពី៨មុំហ៎?

ស៊ីវ៉ន: ចា៎!

ដានី: ដឹកទៅចឹងយើងដឹកអំពៅ?

ស៊ីវ៉ន: ដល់ឃើញចឹងទៅ ខ្ញុំអាណិតចេះតែឲ្យកង់ទ័ពលើកដាក់ឲ្យប្រជាជនទៅណា ។

ដានី: ច្រើនអុំ ឃើញច្រើន?

ស៊ីវ៉ន: ច្រើនមែន ច្រើន! អាហ្នឹងចេញមកដល់ផ្លូវលេខ៥៦អស់ហើយ ។

ដានី: ចេញមកដល់លេខ៥៦?

ស៊ីវ៉ន: ហ្នឹងហើយ! គ្នាដេក វាចេះតែត១គ្នាចេញទៅណា ហើយយើងដល់ឃើញចឹងអាណិតគ្នា ក៏ចេះតែលើកដាក់ឲ្យ ។

ដានី: អុំអាណិតដែរពេលហ្នឹងហ៎?

ស៊ីវ៉ន: ហ៊ឺ! អាណិតណាស់ក្មួយ ។

ដានី: ចុះអុំ ដឹងថាកាលហ្នឹងមូលហេតុបានជាគេជម្លៀសប្រជាជនចេញពីភ្នំពេញ?

ស៊ីវ៉ន: មិនដឹង! ស្រេចលើគោលការគេ គេថាគេជម្លៀសមិនឲ្យនៅ មិនស្រួលគេវាយ គេអីចេះចុះ គេថាឲ្យជម្លៀសសិន មិនមែនឲ្យជម្លៀសរហូតណា ។

ដានី: គេប្រាប់គេថាឲ្យជម្លៀសសិន?

ស៊ីវ៉ន: ហ្នឹងហើយ ពូថាសិនចឹង ។

ដានី: កាលហ្នឹងអុំពូតាមពីណា?

ស៊ីវ៉ន: ពូហ្នឹង ពូតាមប្រជាជនដែលដើរចឹងទៅ យើងឃើញសួរទៅណា ហើយអុំ ប្អូនបងអីមកហ្នឹង ម៉េចបាននាំគ្នាចេញមក? គេឲ្យចេញសិនក្មួយ!

ដានី: បងប្អូនណាគេ?

ស៊ីវ៉ន: ដូចថាយើងមើលឃើញ គាត់រាងចាស់ចឹង ហៅគាត់បង ចែចឹងទៅណា! គាត់ថាគេឲ្យចេញសិន ។ ដល់ចឹងទៅខ្លះដឹកអីវ៉ាន់ រុញឡាន ឡាននៅឆេះខ្លះ ឡានអត់ឆេះអីទៅណា មានកង់ មានម៉ូតូអីចឹងទៅណា ហ៊ូហ៊ែរ មានឃើញ ឃើញមែន!

ដានី: ឃើញច្រើន?

ស៊ីវ៉ន: ច្រើនណាស់ តាមផ្លូវរហូតអីចឹងទៅ ឲ្យតែឃើញឡានយើងចឹងទៅ គាត់ជៀសហើយ គាត់អត់ហ៊ាននៅជិតទេ ។

ដានី: ប៉ុន្តែមើលទៅមុខគាត់ ដូចថាព្រោះយើងរំដោះហើយថ្ងៃទី១៧មេសាចឹងយើងប្រជាជន បើតាមខ្ញុំដឹង ដូចថាគាត់អរគាត់សប្បាយ ។

ស៊ីវ៉ន: ហ្នឹងហើយ! សប្បាយស្រស់បស់អត់អីទេ!

ដានី: សប្បាយដូចថាលើកទង់លើកអី ទទួលកងទ័ពបដិវត្តន៍អីចង់ណា ប៉ុន្តែដល់ពេលពេលជម្លៀសចេញ ទឹកមុខគាត់មានការប្រែប្រួលពីសប្បាយអីដែរអត់?

ស៊ីវ៉ន: ដូចអត់អីដែរ! ដូចគ្រាន់ថាខ្វះហត់ភ្នាវាអស់កំលាំងដែរ ចុះដើរហាលថ្ងៃ ខែហ្នឹងក្តៅណាស់តាចឹងបានអាណិតដឹកអំពៅទាំងបាច់ៗ ជូនគាត់ បេះតែជូនតាមតែផ្លូវចឹង ។

ដានី: ហើយបងនោះគាត់សួរថា អឺមានឃើញមនុស្សស្លាប់តាមផ្លូវទេ?

ស៊ីវ៉ន: អត់ទេ! អត់ទាន់មានទេ និងហើយចេញថ្មីអត់មានទេ ។

ដានី: ហើយដល់ពេលអឹដឹកអ្នកជំងឺទៅ ទៅចូលនៅក្នុង ពោធិ៍ចិនតុងហ្នឹង?

ស៊ីវ៉ន: អត់ទេ! នៅត្រង់ផ្លូវក្រោយទេ អត់ដាក់ក្នុងពោធិ៍ចិនតុងទេ ដូចថាអគ្គភាពកងទ័ពគេនៅ គេហៅថាបន្ទាយបន្ទោកពីដើម នៅកន្ទោក,នៅបែកចាន, នៅកំបូល នៅដាក់តាមចឹង ។

ដានី: ដាក់តាមចឹង! ប៉ុន្តែគាត់ជាហើយបានយកទៅដាក់?

ស៊ីវ៉ន: គាត់ហើយ! ជាហើយយើងហៅឈ្មោះ ចុះទៅដូចថាកងវរសេនាធំណា ចុះហ្នឹង ។

ដានី: អឺ! មួយទៀត ពេលដែលគេកំពុងវាយគ្នាខ្លាំង អ្នកជំងឺរបួសខ្លាំង ឬក៏គាត់ស្លាប់គាត់អី ពេលដែលស្លាប់ហើយកប់មួយកន្លែង ឬក៏អត់ទេ?

ស៊ីវ៉ន: ដាក់មួយកន្លែង!

ដានី: ដាក់មួយកន្លែង នៅម្តុំណាទៅ?

ស៊ីវ៉ន: កន្លែងដែលដាក់ កាលមុនដាក់គ្រាំងល្វា ក្រោយមកទៀតដាក់នៅក្បាលចិន ។

ដានី: ដាក់នៅក្បាលចិន កន្លែងដែលគេកប់សព?

ស៊ីវ៉ន: គេធ្វើធំចឹងណា! ធ្វើស្តូបចឹងទៅបានគេកប់ កប់ហើយបានគេដាក់ឈ្មោះដាក់អី ហើយគោរពវិញ្ញាណក័ន្ធ ដល់តែពេលដល់ថ្ងៃដល់ខែគេត្រូវតែទៅធ្វើបុណ្យគោរព ។

ដានី: ហ្នឹងនៅគ្រាំងល្វាមួយ នៅ...?

ស៊ីវ៉ន: បើខ្ញុំដឹង, នៅគ្រាំល្វាមួយ នៅក្បាលចិនមួយ ។

ដានី: ក្បាលចិន នៅឯណាទៅ ក្បាលចិននោះ?

ស៊ីវន: ក្បាលចិននៅជិតខត្តុង្គ ។

ដានី: ជិតខត្តុង្គហ៎?

ស៊ីវន: ចា៎!

ដានី: ក្បាលចិននៅជិតខត្តុង្គមួយ នៅក្រាំងល្មា ។

ស៊ីវន: វាយចូលភ្នំពេញ គេកប់នៅក្បាលចិន ខ្ញុំទៅរកឥឡូវអត់ឃើញ មិនដឹងត្រង់ណា ។

ដានី: ទៅរកដែរ?

ស៊ីវន: ដូចថាទៅធ្លាប់ឃើញចឹង រកមើលវាអត់ឃើញ បែបគេធ្វើផ្ទះធ្វើចម្ការអីអស់ហើយដឹង ។

ដានី: នៅក្រាំងល្មាហើយហ្នឹងក្បាលចិនហ្នឹង?

ស៊ីវន: ក្រាំល្មាអត់ដែលទៅសោះ ។

ដានី: ក្បាលចិន អ៊ីធ្លាប់ទៅ?

ស៊ីវន: ចុះយើងជិះឡាន ។

ដានី: បាទ! ជិះឡានកាត់តាមហ្នឹង?

ស៊ីវន: ចា៎!

ដានី: ប៉ុន្តែពីជំនាន់មុនហ្នឹង គេមានដាក់ផ្លាក ដាក់អី?

ស៊ីវន: ដាក់ផ្លាក! យើងអត់មានអីយកជប ។

ដានី: ច្រើនហ៎កាលហ្នឹង?

ស៊ីវន: ច្រើនដែរ រាប់រយនាក់ ។

ដានី: រាប់ពាន់ រាប់យដែរ ។ ក្រាំល្មាច្រើនដែរទេ?

ស៊ីវន: ច្រើនរាប់រយពាន់នាក់ គ្រាន់តែកប់តំរៀបគ្នាតាមអង្គភាព ។

ដានី: ចុះអ៊ីកងពលទី១ ក្រែងក្រោយមកមានដូរឈ្មោះទៀតអត់?

ស៊ីវន: ដូរ!

ដានី: ដូរឆ្នាំណាទៅអ៊ី?

ស៊ីវន: កងពលលទី១ ដល់ហើយបំបែកកងពលហ្នឹងណា ពេលឈ្នះឆ្នាំ៧៥ ស្រាប់តែបំបែក គាត់ត្រូវមកកាន់កងពល៥០២វិញ ។

ដានី: កងពលទី១ហ្នឹង បំបែកតែម្តង?

ស៊ីវន: ចា៎! យកតែគាត់មួយមកហើយកងទ័ព គាត់ត្រូវនៅកងពល៥០២វិញ ។

ដានី: កាលហ្នុងគាត់មកកាន់កងពល៥០២ តែកងទ័ពអតីតរបស់កងពលទី១មកតាមគាត់ប៉ុន្មានដែរ?

ស៊ីវ៉ន: អត់ច្បាស់ទេ ចម្រុះគ្នាតែម្ដង រើសចម្រុះតែម្ដង ព្រោះកងទ័ពហ្នឹងជាកងទ័ពអាកាស ។

ដានី: បាទ! ជាកងទ័ពអាកាស ចឹងកងទ័ពអាកាសមកពីណាមក?

ស៊ីវ៉ន: គ្រប់កងពលទាំងអស់ មាន៨០១, ៩២០, ៤៥០ អូ! ច្រើនណាកងពលក្រោយ ។

ដានី: អាហ្នឹង គេប្រកាសថ្ងៃជាមួយគ្នាតែម្ដង?

ស៊ីវ៉ន: អត់ទេ! គេជ្រើសរើសមិនដឹងយ៉ាងម៉េច តែគ្រាន់តែដឹងថាដូច៨០១យកប៉ុន្មានមក,៩២០ ប៉ុន្មាន, ៤៥០ប៉ុន្មាន, កងពលទី១ប៉ុន្មាន ចឹងទៅណា បានមករៀបកងពលហ្នឹង ហើយគេជ្រើសរើសប្រវត្តិរូបអីចឹងទៅណា ។

ដានី: មកកាន់កងពល៥០២ មានអ៊ីប្រុសពីណាទៀត?

ស៊ីវ៉ន: តាល្វៃ! អូរ! បងសាន ឈ្មោះសាន ។

ដានី: សាន ០៦ហ្នឹង មិនមែន?

ស៊ីវ៉ន: ហ្នឹងហើយ! តាសាន នៅមណ្ឌលគិរី ។

ដានី: តាសាន មណ្ឌលគិរីហ្នឹង?

ស៊ីវ៉ន: ហ្នឹងហើយ ស្លាប់បាត់ហើយ ។

ដានី: បាទ! តាសាន ៩២០?

ស៊ីវ៉ន: ហ្នឹងហើយ កងពល៩២០!

ដានី: ដំបូងគាត់នៅ?

ស៊ីវ៉ន: គាត់រង គាត់ហ្នឹង អនុគាត់! ដល់ក្រោយមកបានឲ្យគាត់ទៅធ្វើប្រធាន៩២០ ។

ដានី: តាសាន, តាល្វៃ!

ស៊ីវ៉ន: ហើយគាត់ហ្នឹង តែពនាក់ ។

ដានី: ហើយកាលហ្នឹង មន្ទីរកងពលទៅណាទៅ?

ស៊ីវ៉ន: កងពល នៅជិតពោធិ៍ចិនតុង ។

ដានី: មិនមែននៅក្នុងព្រលានយន្តហោះហ្នឹងតែម្ដងទេ?

ស៊ីវ៉ន: អត់ទេ! គ្រាន់តែជិតទេ, ទីបាត់ការ ផ្ទះនៅពោធិ៍ចិនតុង ជិតៗហ្នុង ។

ដានី: នៅផ្សារពោធិ៍ចិនតុង ឬនៅក្បែរព្រលានយន្តហោះ?

ស៊ីវ៉ន: ជិតព្រលានដែរហ្នឹង ហ៎ជិតផ្សារមើលមានផ្ទះមួយគេដាក់នេះដូចថាកន្លែងនេះជាទីបញ្ជាការ១ ទៅ គេដាក់ខាងនោះទៅក្នុងពោធិ៍ចិនតុងទៀតទៅ ច្រើនកន្លែងដែរ ។

ដានី: កាលហ្នឹងពេទ្យអីនៅណាទៅ?

ស៊ីវ៉ន: ពេទ្យខ្ញុំ នៅពេទ្យកន្លែង គេហៅពេទ្យចិន, ពេទ្យចិនអា!

ដានី: ចឹងនៅក្នុងភ្នំពេញវិញ?

ស៊ីវ៉ន: វាមិនមែនទេ! មិនមែនអានៅក្នុងភ្នំពេញទេ ពេទ្យចិនហ្នឹងទើបតែធ្វើថ្មីទេណា មកពី!មើលតែចេះទៅឃើញព្រលានយន្តហោះ មកពីពោធិ៍ចិនតុងតិចមកមានផ្លូវចូល ពីមុនមានស្រះទឹកអីឥឡូវគេចាក់ពេញអស់ហើយ ខ្ញុំទើបតែទៅឥឡូវឃើញគេចាក់ពេញអស់ហើយ ។

ដានី: អាហ្នឹងពីមុនមកពេទ្យចិន ហើយក៏?

ស៊ីវ៉ន: គេថាពេទ្យចិនធ្វើ ។

ដានី: ពេទ្យចិនធ្វើមុនរំដោះបាន ឬក៏ធ្វើនៅក្នុងសម័យនេះដែរ?

ស៊ីវ៉ន: ទេ! ធ្វើពីមុន រដ្ឋាភិបាលធ្វើ ប៉ុន្តែគ្រាន់តែពេទ្យហ្នឹងរៀងថ្មី ហើយវារៀងដាច់ឆ្ងាយពីភ្នំពេញ ហើយវារៀងស្រឡះ ។

ដានី: ពេទ្យអឺគេហៅ ព-ប៉ុន្មាន?

ស៊ីវ៉ន: ពេទ្យខ្ញុំហ្នឹង កាលហ្នឹងដាក់លេខ៦៥ ។

ដានី: ចុះពេទ្យ ព-៣?

ស៊ីវ៉ន: ពេទ្យយោធា៦៥ ។

ដានី: ចុះពេទ្យ ព-៣ នៅណាទៅ?

ស៊ីវ៉ន: អត់ទេ! អត់ស្គាល់ទេ ។

ដានី: គេប្រាប់ខ្ញុំថាមានពេទ្យ ព-៣ហ្នឹងមួយ នៅពោធិ៍ចិនតុង ។

ស៊ីវ៉ន: ដឹងម៉េច គេទើបតែដាក់ថ្មី ឬក៏ម៉េច ខ្ញុំអត់ដឹងទេ ។

ដានី: ពេទ្យរបស់អឺ ពេទ្យកងពលហ្នឹង ពេទ្យ៦៥?

ស៊ីវ៉ន: ដាក់ពេទ្យយោធា៦៥ ។

ដានី: ពេទ្យលេខ៦៥, អឺដឹងថាគេដូរលេខកងពលពីលេខ១ មក៥៥២ ខែប៉ុន្មាន ឆ្នាំណា?

ស៊ីវ៉ន: ៥០២ហេ៎?

ដានី: បាទ!

ស៊ីវ៉ន: ឆ្នាំ ៧៥,៧៦ហ្នឹង ចាប់រៀបចំ ។

ដានី: បាទ! ពេលយើងចូលទៅថ្ងៃ១៧មេសា ឆ្នាំ៧៥?

ស៊ីវ៉ន: ចា៎! ៧៦ ។

ដានី: ចូលទៅយូរដែរអត់បានគេបំបែក?

ស៊ីវន: ទេអត់យូ! ចូលទៅរៀនភ្លាមៗដែរ ។

ដានី: ហើយប៉ុន្មានទៅ?

ស៊ីវន: ដូចថា៧៦!

ដានី: ៧៦ ប្រហែលជា៥, ៦ខែដែរ ។

ស៊ីវន: ហ្នឹងហើយ! ៥,៦ខែទម្រាំរៀបហើយ ប៉ុន្តែគ្រាន់ថាគាត់នៅប្រចាំហ្នឹងហើយ គេចេះប្រមូលពីនេះប្រមូលពីនោះមក ។

ដានី: គេចេះតែនេះ ហើយគេប្រកាសជាផ្លូវការថា កងពលអ៊៥០២ក្នុង...?

ស៊ីវន: ៧៦ហ្នឹងឃើញគេប្រកាសហើយ!

ដានី: ខែប៉ុន្មាន បើតាមអ៊ំចាំ?

ស៊ីវន: អត់ចាំទេ!

ដានី: ដើមខែ ឬក៏?

ស៊ីវន: ខែ១! ពីមុនខ្ញុំនៅពេទ្យកងពលទី១ ដល់ចឹងទៅបងសឿនហ្នឹងគាត់ថា ហើយគោលការណ៍គេអាហ្នឹង អ្នកណាមានប្តីនៅឯណាគេឲ្យទៅហ្នឹង ប្រពន្ធទៅណាទៅហ្នឹង ដល់ចឹងគេឲ្យខ្ញុំទៅនៅកងពលហ្នឹង ។

ដានី: ខែ១ ឆ្នាំ៧៦ បានអ៊ំទៅ?

ស៊ីវន: ចា៎! ខែ១, ៧៦ ខ្ញុំទៅ ។

ដានី: មុនដំបូងពេលបែកពីឆ្នាំ៧៥ ពីខែ៤ ឆ្នាំ៧៥ អ៊ំគ្រាន់តែដឹកអ្នកឈឺទៅទេ?

ស៊ីវន: អ្នកឈឺទៅទេ!

ដានី: ហើយត្រឡប់មកវិញ?

ស៊ីវន: ត្រឡប់មកវិញ ។

ដានី: ត្រឡប់មកនៅឯណាវិញ?

ស៊ីវន: កន្លែងខ្ញុំដែលរៀបចំនៅជម្ពូវ័ន ។

ដានី: នៅជម្ពូវ័ន ត្រឡប់មកនៅជម្ពូវ័នវិញ?

ស៊ីវន: ហ្នឹងហើយត្រឡប់មកវិញ នៅជម្ពូវ័នហ្នឹងពុំបានប៉ុន្មានទៀតត្រូវរើមកនៅលង្វែកទៀត ។

ដានី: អូ! អ៊ំបានមកនៅលង្វែកដែរ ។

ស៊ីវន: រៀបចំពេទ្យនៅលង្វែកហើយបាន អ៊ំសឿនគាត់ថា កងពលហ្នឹងខ្ញុំប្រាប់ថា ប្តីនៅណាទៅហ្នឹង ។

ដានី: គាត់ប្រាប់ចឹង?

ស៊ីវន: ចាំ! ដល់ចឹងបានខ្ញុំទៅនៅហ្នឹងវិញ ។

ដានី: កាលហ្នឹងកងពលទី១ចាស់ហ្នឹង បំបែកជា២, មួយទៅ៥០២ ហើយមួយទៀតនៅកងពលទី១ ដដែរមកខាងលង្វែក?

ស៊ីវន: មកខាងលង្វែក តែនៅប្រចាំការនៅព្រៃទប់អីអីណាកោះកុងណ៎ ។

ដានី: អូ! ទៅខាងព្រៃទប់ខាងកោះកុង ។ ប៉ុន្តែដំបូងមុនហ្នឹងទៅលង្វែកទៅជម្ពូវ័នសិន?

ស៊ីវន: ចាំ!

ដានី: កងពលក៏នៅជម្ពូវ័នដែរ?

ស៊ីវន: ចាំ! អត់ទេ ។ កងទ័ពនៅពេញហ្នឹង តែគ្រាន់តែពេទ្យនៅប្រចាំហ្នឹង ។

ដានី: ពេទ្យនៅជម្ពូវ័ន ។

ស៊ីវន: សាលារៀនជម្ពូវ័ន ។

ដានី: ប៉ុន្មានថ្ងៃទៅបានទៅលង្វែក?

ស៊ីវន: ហ៎យូរដែរ ប្រហែលជា២,៣ខែទេដឹង ។

ដានី: ២,៣ខែដែរណ៎?

ស៊ីវន: ចាំ! លង្វែក បានរៀបចំនៅលង្វែកហ្នឹងទៀត ។

ដានី: ទៅដល់លង្វែកគេរៀបជាគណៈកងពលពេទ្យអីចឹងទៅ?

ស៊ីវន: ខ្ញុំហ្នឹងហើយ គេរៀបចំ! គេរៀបហ្នឹងដដែរទេ, ខ្ញុំនៅតែប្រធានដដែរ តែគ្រាន់តែយើងរៀបពេទ្យរៀបស្អីនៅកន្លែងរៀបចំអ្នកជំងឺផ្ទុះបាយអីហើយអស់ទៅ បានអ៊ំសឿងគាត់ថា ប្តីនៅឯណាក៏បញ្ជូនខ្ញុំមកនៅភ្នំពេញទៅ ។

ដានី: ចឹងដល់ពេលកងពលទី១ នៅក្នុងភូមិភាគអីវិញទៅ?

ស៊ីវន: និរតី!

ដានី: នៅនិរតី?

ស៊ីវន: ចាំ! ហើយក៏ បស្ចឹមអីក៏មិនដឹងទេ ។

ដានី: បស្ចឹមហ៎?

ស៊ីវន: សង្ស័យតែបស្ចឹមហីយ ។

ដានី: ភូមិភាគពិសេសគេឈប់ហើយ ឈប់មាន?

ស៊ីវន: ឈប់! អត់ទៅភូមិភាគពិសេសគេនៅតែមានភូមិភាគពិសេសដដែរហ្នឹង នៅឯភ្នំពេញតែម្តងអ្នកភូមិភាគពិសេស ។

ដានី៖ អ្នកភូមិភាគពិសេសចូលមកភ្នំពេញ?

ស៊ីវន៖ ចូលមកនៅភ្នំពេញអត់មានចេញទៅណាទេ ។

ដានី៖ ភូមិភាគបស្ចឹមកើតក្រោយទេ?

ស៊ីវន៖ ភូមិភាគបស្ចឹមហ្នឹងហើយ! គេបំបែកទៅមានខាងកំពង់ឆ្នាំង ខាងកំពង់ស្ពឺណាទេចឹងណា ហូរហែរមានស្រុកថ្ពង ស្រុកអីណា ខ្ញុំអត់សូវច្បាស់ទេ យើងដឹងតែមកភ្នំពេញហើយ ។

ដានី៖ បាទ! ដឹងពេលមកភ្នំពេញ, ពេលដែលអ៊ំនៅលផ្នែក កាលហ្នឹងតាសឿងគាត់នៅជាគណៈកងពល?

ស៊ីវន៖ ជាប្រធាន ។

ដានី៖ ជាប្រធានកងពលដដែរ ។ អនុគាត់ពីណា?

ស៊ីវន៖ អនុខ្ញុំអត់ច្បាស់ទេ, តែដឹងថា តា សារី នៅ, នៅតែពីរនាក់តា សារី ហ្នុងហើយ គេមិនទាន់រើសថ្មីទៀត ។

ដានី៖ តាសារី! ហើយដល់ពេលនេះអ៊ំមកកងពល៥០២វិញ?

ស៊ីវន៖ ចា៎!

ដានី៖ ប៉ុន្តែនៅក្នុងកងពល៥០២ កាលហ្នឹង អត់ទាន់មានពេទ្យទេណ៎?

ស៊ីវន៖ កាលដំបូងអត់ទាន់មានទេ បានយកខ្ញុំមកធ្វើប្រធានពេទ្យនៅហ្នឹង ។

ដានី៖ បានមកធ្វើប្រធានពេទ្យនៅហ្នឹងវិញ?

ស៊ីវន៖ ចា៎!

ដានី៖ ហើយកាលហ្នឹង ដល់ពេលរំដោះហើយ នៅមានអ្នករបួសអ្នកអីទៀតអីដែរអត់ទេ?

ស៊ីវន៖ មានតិច! ដូចថាគ្នារបួសសើររើរ ដូចថាគ្នាទៅរើសគ្រាប់មានប៉ះពាអើ មានដែរ ប៉ុន្តែមានតិចអត់ច្រើនដូចកាលវាយ ។

ដានី៖ ហើយកាលហ្នឹង ចុះបើអ្នកជំងឺផ្សេងៗច្រើនឈឺអីទៅ?

ស៊ីវន៖ មានគ្រុនធម្មតា ផ្តាសាយ គ្រុនចាញ់ សំណល់ពីសង្គ្រាម ។

ដានី៖ សំណល់ពីសង្គ្រាមហេ៎?

ស៊ីវន៖ ចា៎!

ដានី៖ ហើយពេលចឹង អ៊ំហើយអ៊ំប្រុស អ៊ំបាននៅជុំគ្នាហ្នឹងណ៎?

ស៊ីវន៖ មិនជុំទេ! ខ្ញុំនៅឯពេទ្យនេះ គាត់នៅកន្លែងគាត់ គេមានកម្មវិធី១០ថ្ងៃជួបគ្នាម្តង ថ្ងៃទី១០, ២០, ៣០ ។ មួយខែជួបបានតែប៉ុណ្ណឹងទេ ថ្ងៃទី១០គេមកយកយើងទៅម្តង ថ្ងៃទី២០ម្តង

ថ្ងៃ៣០មួន ចា៎ស! បានតែប៉ុណ្ណឹង តែដោយឡែកដូចខ្ញុំអីចឹង ត្រូវមានកម្មវិធីប្រជុំអីចឹង ទៅមកបាន ។

ដានីៈ ទៅមកបាន?

ស៊ីវនៈ ចា៎!

ដានីៈ បាទ! ប៉ុន្តែម៉េចបានគេរើសយកថ្ងៃ១០, ២០ថ្ងៃ?

ស៊ីវនៈ គេសម្រាក ។

ដានីៈ ថ្ងៃហ្នឹងសម្រាក?

ស៊ីវនៈ ចា៎! ត្រូវសម្រាកត្រូវធ្វើការ១០ថ្ងៃចឹងសម្រាក ។

ដានីៈ ទាំងអស់គ្នា?

ស៊ីវនៈ ទាំងអស់គ្នាចឹង ។ សម្រាកហ្នឹងដូចថាយើងថ្ងៃឈប់អត់ធ្វើអីទេ ចង់ជួបជុំគ្រួសារទៅលេងទៅលេងទៅ ។

ដានីៈ ចឹងអ៊ីជាពេទ្យកងពលចឹង មិនស្ថិតនៅក្រោមអំការគ្រប់គ្រងរបស់?

ស៊ីវនៈ ស្ថិតក្រោមការគ្រប់គ្រងរបស់កងពលហ្នឹង ។

ដានីៈ ស្ថិតក្រោមរបស់កងពលហ្នឹងតែមួន?

ស៊ីវនៈ ចា៎!

ដានីៈ មិនមាននៅក្រោមក្រសួងសង្គមកិច្ចអីទៀតទេ?

ស៊ីវនៈ អត់ទេ! ប៉ុន្តែខាងសង្គមកិច្ចហៅត្រូវទៅរៀន យើងត្រូវទៅប្រជុំប្រអីដកពីសោធន៍រឿងបច្ចេកទេសបាន ។

ដានីៈ អូ៎! ចឹងហ៎?

ស៊ីវនៈ ចា៎!

ដានីៈ អ៊ីធ្លាប់ទៅប្រជុំ ទៅដកពិសោធន៍ដែរ?

ស៊ីវនៈ ចា៎!

ដានីៈ ប្រជុំនៅឯណាទៅ?

ស៊ីវនៈ នៅពេទ្យយើងឥឡូវហៅ អាពេទ្យរុស្ស៊ីហ្នឹង ។

ដានីៈ ពេទ្យរុស្ស៊ី, កាលហ្នឹងហៅអីគេ?

ស៊ីវនៈ ពេទ្យ១៧មេសា ។

ដានីៈ ពេទ្យ១៧មេសា!

ស៊ីវន: តែអាហ្នឹង មិត្តភាពខ្មែរសូវៀតហោ!

ដានី: បាទ! មិត្តភាពខ្មែរសូវៀតទេ ។

ស៊ីវន: ពេទ្យហ្នឹងស្អាត, ប្លង់ស្អាត ។

ដានី: បាទ! ស្អាត ។ ហើយអាហ្នឹងយើងទៅហ្នឹង យើងទៅប្រជុំបច្ចេកទេសទេ?

ស៊ីវន: បច្ចេកទេសទេ ។

ដានី: បើមាគ៌ានយោបាយ អត់ទេ?

ស៊ីវន: អត់ទេ! គេណែនាំតិចតួច ពេលទៅរៀនចឹងពេលទៅមើលអ្នកជំងឺ យើងគេមិនឲ្យសំដីធំតូចដាក់អ្នកជំងឺ មិនឲ្យជេរ កុំឲ្យប្រទេចកុំឲ្យធ្វើបាបធ្វើអីចឹងទៅណា! គេណែនាំរឿងចឹង ក្បួនគេ ។

ដានី: ហើយកាលហ្នឹង! បើយើងទៅរៀនបច្ចេកទេសយើងទៅរៀនយ៉ាងម៉េចទៀត ដូចអ៊ីរៀនជាមួយតា ជួន ជឿន?

ស៊ីវន: ចេះតែរៀនទៅកាលហ្នឹង, រៀនដើម្បីដកបទពិសោធន៍ រៀនធ្វើខុសធ្វើត្រូវអីចឹងទៅណាដល់ចឹង គេបង្ហាញអាពីរបៀបត្រូវៗទៀត ។

ដានី: ពីណាគេអ្នកកបង្រៀនកាលហ្នឹង?

ស៊ីវន: តា ជួន ជឿនហ្នឹង ។

ដានី: តាជួន ជឿនដដែរ?

ស៊ីវន: មានតា ជួន ជឿន ផង, មានគ្រូមកពីរៀននៅចិនស្រី រៀនឆ្មបរៀនអីហូរហែរចឹងមក ។ មានឆ្មប មានអ្នកវះកាត់, ជំងឺទូទៅ តា ជួន ជឿន គាត់មកសរុបឲ្យ ។ ប៉ុន្មានថ្ងៃគាត់ត្រូវមកជួបយើងម្តង ហើយគាត់អ្នកធ្វើឯកសារ ។

ដានី: ហើយអ៊ីធ្លាប់ទៅចិនទេ?

ស៊ីវន: អត់ទេ! អត់ដែលបានទៅទេ ។ តែមានគេទៅចឹងទៅយើងរៀនពីគេ ឆ្មបអី ។

ដានី: អ៊ីប្រុសធ្លាប់ទៅទេ?

ស៊ីវន: ធ្លាប់ ។

ដានី: គាត់ទៅរៀន ឬក៏ទៅទស្សនៈកិច្ច?

ស៊ីវន: ទស្សនៈកិច្ច, រៀនខ្ញុំមិនច្បាស់ដែរ! ព្រោះទៅយូរមិនដឹងយ៉ាងម៉េច ដឹងរៀន ដឹងយ៉ាងម៉េច ។

ដានី: គាត់ទៅយូរៗដែរ?

ស៊ីវន: ជួនកាលចង់កន្លះខែ ខ្វះមួយអាទិត្យ ។

ដានី: ទៅច្រើនដងចឹង?

ស៊ីវន: ទៅញឹកដែរ! តែគ្រាន់តែមិនដឹងទៅរឿងអី យើងមិនដែលសួរនាំទេ ។

ដានី: គាត់ចេះបើកកប៉ាលហោះទេ?

ស៊ីវន: កប៉ាល់ហោះអត់ដឹងទេ តែគ្រាន់តែគាត់អាចបើកបាន, ត្រូវរៀនបាន ដូចថាទៅពិនិត្យទៅសុខភាពស្អីៗ ត្រឹមបើកបានពីមុន បើនៅក្មេង ។

ដានី: គាត់ធ្លាប់បើកអីអ៊ំ អ៊ំឃើញគាត់ធ្លាប់បើកទេ?

ស៊ីវន: អត់ទេ អត់ដឹង ថាធ្វើស្អីក៏មិនដឹងដែរយើង! ជំនាន់ហ្នឹងលាក់ការបានល្អណាស់ ។

ដានី: ប្តីប្រពន្ធអត់ដែលនិយាយរកគ្នា អូ! សុខសប្បាយ សុខទុក្ខ ការងារអី?

ស៊ីវន: ដឹងតែពីរឿងឈឺជា បើឈឺយើងទៅមើល ។

ដានី: បើឈឺទៅមើលគាត់ទៅ?

ស៊ីវន: ចា៎!

ដានី: ចុះអ៊ំនិយាយថាអ៊ំមានកូនឆ្នាំ៧៦,៧៨ កូននៅជាមួយអ៊ំ ឬក៏អត់ទេ?

ស៊ីវន: ហ្នឹងនៅជាមួយខ្ញុំ ប៉ុន្តែមានអ្នកមើល យើងធ្វើការ ទាល់តែគេជួយមើល ។

ដានី: ចុះក្រុមគ្រួសារអ៊ំដែលដូចជាម្តាយ បងប្អូនអី គាត់មកនៅជាមួយដែរ ឬក៏យ៉ាងម៉េចពេលហ្នឹង?

ស៊ីវន: ពេលហ្នឹងគាត់ នៅផ្សេង មកដែរ! ប៉ុន្តែគាត់នៅផ្សេង ។

ដានី: បាទ! ប៉ុនក្នុងវង្វង់របស់កងពលហ្នឹងដែរ?

ស៊ីវន: ចា៎! ហ្នឹងតែម៉ែឪខាងខ្ញុំ ម៉ែឪខាងគាត់នៅផ្សេងទៀត ។

ដានី: ម៉ែឪខាងគាត់ទៅនៅឯណាទៅ?

ស៊ីវន: ឪគាត់មិនដឹងនៅឯណាដែរ មិនដែលឃើញទេឪពុកគាត់ ។

ដានី: បាទ! ឪពុកគាត់ ចុះម្តាយគាត់?

ស៊ីវន: ម្តាយគាត់នៅកំពង់ឆ្នាំង ។

ដានី: គាត់អត់មកនៅជាមួយកូនទេ?

ស៊ីវន: មុនដំបូងគាត់នៅជាមួយដែរ ដល់ក្រោយមកឃើញប្អូនគាត់ ប្អូនថ្លៃគាត់មកយកទៅនៅកំពង់ឆ្នាំងវិញ ។

ដានី: ចុះប្អូនៗគាត់ធ្វើអីទៅអ៊ំប្រុស?

ស៊ីវន: ប្អូនគាត់ស្លាប់អស់ហើយ! ប្រុស! ធ្វើទាហាន ។

ដានី: ធ្វើទាហាន?

ស៊ីវនៈ ហ្នឹងហើយ ។

ដានីៈ ប៉ុន្តែស្លាប់តាំងពីមុន៧៥ទៀត?

ស៊ីវនៈ ស្លាប់ពីមុន៧៥ក៏មានដែរ ។

ដានីៈ បាទ! ដល់ពេលឆ្នាំ៧៥?

ស៊ីវនៈ អត់មានទេ! ក្រោយមកទៀតអត់មានទេ ។

ដានីៈ បាទ!

ស៊ីវនៈ ៧៥ ហើយវាយចូល កាលហ្នឹងវាយម៉ាជួរផ្លូវជាតិលេខ៥ ។

ដានីៈ ចុះបងដូចជាបងស្រីគាត់ឈ្មោះ ឡាំ កាលហ្នឹងគាត់ធ្វើអីទៅ?

ស៊ីវនៈ មិនច្បាស់ទេ ។

ដានីៈ អត់ច្បាស់ទេ! ប៉ុន្តែមិនមែននៅភ្នំពេញទេ?

ស៊ីវនៈ អត់! ដូចថានៅឯពោធិ៍សាត់ មិនដឹងធ្វើអីខ្ញុំអត់ច្បាស់ ។ ហើយ ស៊ូ ហឿនហ្នឹងនៅកំពង់សោម តែមិនដឹងធ្វើអីដែរ គាមដឹងគេថានេសាទសមុទ្រ!

ដានីៈ នៅកំពង់សោមហ្នឹង នៅជាមួយតាមុត?

ស៊ីវនៈ មែនទេ! នៅជាមួយឈ្មោះតា ឡូញៗហ្នឹង នៅនេសាទសមុទ្រ ។ តាមុតហ្នឹង គាត់កងទ័ពជើងទឹក ។

ដានីៈ គាត់ខាងកងទ័ពជើងទឹក?

ស៊ីវនៈ តាមុត! កងទ័ពជើងទឹក, កងទ័ពជើងគោក, កងទ័ពជើងអាកាស ។

ដានីៈ កាលហ្នឹងអឺចាំទេ កងទ័ពជើងទឹក កងលេខ១០០ប៉ុន្មានកាលហ្នឹង?

ស៊ីវនៈ ១៦៤ ។

ដានីៈ ១៦៤ ខាងជើងទឹក ខាងជើងអាកាស១០០?

ស៊ីវនៈ ៥០២ ។

ដានីៈ ខាងជើងគោក?

ស៊ីវនៈ ៨០១,៩២០, ៤៥០ ដឹងប៉ុន្មានទៀតលែងស្គាល់ហើយ, ស្គាល់តែប៉ុណ្ណឹង ។ កាលហ្នឹង តា ហេង សំរិន ក៏ប្រធានកងពលដែរ ។

ដានីៈ តា ហេង សំរិន កងពលលេខប៉ុន្មាន?

ស៊ីវនៈ មិនដឹងជាទីប៉ុន្មានទេ ធ្លាប់ទៅប្រជុំនៅស្តាតក៏ឃើញ ។ បងគាត់ហ្នឹងក៏ស្គាល់ គាត់ប្រធានកងពល ដែរ ។

ដានី៖ ឈ្មោះអីគេ?

ស៊ីវ៉ន៖ តា ហេង សំកៃ នោះ, តែគេដូរឈ្មោះពីមុន ឈ្មោះស៊ួទេ! គេដូរហៅ តានេះ តានោះប៉ុន្តែមុខ ដឹងតែឃើញម៉ង ។

ដានី៖ អ៊ីធ្លាប់ឃើញ សម្តេចហេង សំរិន ហ្នឹងគាត់ កងពលទៅប្រជុំជាមួយគ្នានៅស្តាត?

ស៊ីវ៉ន៖ ចា៎! ប្រធានកងពលនោះ ។ គាត់ហ្នឹងក៏ប្រធានកងពលមួយដែរ អីចឹងបានខ្ញុំថាបើសិនគាត់ទោសប្រធានកងពល កាត់គាត់ដែរហើយ ។

ដានី៖ កាលហ្នឹងបើសិនជាអ៊ីបានជួប សម្តេចហេង សំរិន ហើយរំឮកប្រាប់គាត់ប្រហែលគាត់ចាំមើលទៅ?

ស៊ីវ៉ន៖ អត់ទេ! មិនចាំទេ គ្នាច្រើនណាស់ ។

ដានី៖ រំឮកថាហ្ន៎ ធ្លាប់ប្រជុំនៅស្តាត ។

ស៊ីវ៉ន៖ ហើយខ្ញុំអីនៅក្មេងណា៎! គាត់ប្រហែលជា៣០ជាងហើយ យូរដែរ ខ្ញុំ២០ជាង ។

អ្នកជិតខាង៖ ចុះហេង សំរិន គាត់មានបងប្រុសគាត់?

ស៊ីវ៉ន៖ មានតើស! តែស្លាប់ហើយ ។ ខ្ញុំទៅស្វាយរៀងឮពួកហ្នឹងស្គាល់គ្នា គេនិយាយប្រាប់ ។

ដានី៖ អ៊ីធ្លាប់ទៅដល់ស្វាយរៀងដែរ?

ស៊ីវ៉ន៖ ចា៎! មានពួកម៉ាកមួយនៅហ្នឹង ។

ដានី៖ អូ! ពួកម៉ាកណាគេ?

ស៊ីវ៉ន៖ ឈ្មោះ ឌួង វណ្ណា ។

ដានី៖ ឌួង វណ្ណា, គាត់ធ្វើអីគេ?

ស៊ីវ៉ន៖ គាត់ហ្នឹងពីមុនប្រធានគណៈបក្សប្រជាជន ។

ដានី៖ គណៈបក្សប្រជាជននៅឯណា?

ស៊ីវ៉ន៖ គណៈប្រជាជនខេត្តស្វាយរៀង ហើយប្រធានកបាទក្រហមអីគេនោះទៀតណា៎ ។

ដានី៖ អ៊ីស្គាល់គាត់?

ស៊ីវ៉ន៖ ហើយមួយទៀតឈ្មោះ ឈឹម សារឹម ឥឡូវមកនៅសភាភ្នំពេញអស់ហើយ ។

ដានី៖ អូ! គាត់មកតំណាងរាស្ត្រនៅភ្នំពេញអស់ហើយ?

ស៊ីវ៉ន៖ ចា៎! តាឡូយ សុជាត អីហ្នឹង ក៏ខ្ញុំស្គាល់ដែរ ។

ដានី៖ អូ! ឡូយ សុជាត ស្គាល់គាត់តាំងពីអន្តាល?

ស៊ីវ៉ន: ស្គាល់គាត់ ៩៧! ពេលដែលត្រូវគ្នាហើយហ្នឹង មានតាម្នាក់នៅនេះ តាប៉ុល សាវ៉ាន់ ដែលពុ ឈ្មោះអត់?

ដានី: ពុតើស!

ស៊ីវ៉ន: គាត់ហ្នឹងផ្កាយមួយនៅប្រចាំ គាត់ទំនាក់ទំនងជាមួយពួកខ្មែរក្រហមដែរចុះចូលទាំងអស់នោះណា៎ ដល់ចឹងគាត់ធ្វើនយោបាយអីចឹងទៅ គាត់បបួលពួកខ្ញុំទៅលេងភ្នំពេញ ហើយត្រូវទៅប្រជុំ គាត់ទៅប្រជុំ ខ្ញុំក៏ទៅដែរ ប្រពន្ធគាត់បបួលខ្ញុំទៅស្វាយរៀង។ គាត់ធ្វើកាស៊ីនៅស្វាយរៀង។ ដល់ចឹងត្រូវទៅជួប ហើយតាឡូយ សុផាត ចៅហ្វាយខេត្ត ដល់ជួបគាត់ថ្ងៃហ្នឹងឃើញខ្ញុំ ហើយ ដួង វណ្ណាហ្នឹង គាត់ថាពួកនេះធ្វើពួកម៉ាកគ្នាសមតែម្ដង។ ដល់ចឹងគេរៀបចំធ្វើពួកម៉ាកធ្វើអីហើយចេះតែរាប់អានគ្នាទៅ។

ដានី: អ៊ីចុះ តាមុត អ៊ីស្គាល់គាត់តាំងពីអង្កាលមក?

ស៊ីវ៉ន: តាមុត ស្គាល់តាំងពីនៅក្នុងព្រៃ។

ដានី: ស្គាល់ក្នុងព្រៃហោ៎?

ស៊ីវ៉ន: ចា៎!

ដានី: ប្រពន្ធគាត់ឈ្មោះ?

ស៊ីវ៉ន: ប្រពន្ធមុនឈ្មោះ ខុម ត្រូវជាកូនតាម៉ុកបង្កើត កូនបងគាត់។ តែប្រពន្ធគាត់ហ្នឹងឆ្កួត សរសៃប្រសាទពោះធំ។

ដានី: ហើយម៉េចទៅក្រោយមក?

ស៊ីវ៉ន: ស្លាប់បាត់ហើយ! តែមិនដឹងស្លាប់រឿងអី បែកគ្នា យើងចេះ ដូចយើងដឹកានតែធំ បែកគ្នាបណ្ដោយ ដូចថាក្ដាប់គ្នាអត់បាន។

ដានី: ក្រោយមកគាត់យកប្រពន្ធក្រោយទៀត?

ស៊ីវ៉ន: អាហ្នឹងប្រពន្ធក្រោយ។

ដានី: យកតាំងពីឆ្នាំណាមក?

ស៊ីវ៉ន: អត់ដឹងទេ! បែកគ្នា។

ដានី: ប្រពន្ធក្រោយគាត់ឈ្មោះ?

ស៊ីវ៉ន: ខា! តែមិនដឹងស្អីខាទេ។

ដានី: ហើយអ៊ីដឹងថា ប្រពន្ធមុនគាត់កើតជំងឺសរសៃប្រសាទ។

ស៊ីវ៉ន: កូនតាម៉ុក។

ដានី៖ កូនតាម៉ុក?

ស៊ីវន៖ ចាំ!

ដានី៖ ក្នុងពេលដែលអ៊ីទៅកំពង់សោមអី អ៊ីអត់ដែលបានទៅជួបអ៊ីទៀតទេ? គាត់អត់ដែលបានមកលេងទេភ្នំពេញ?

ស៊ីវន៖ អត់ទេ! កាលហ្នឹងកន្លែងណាទៅត្រង់ណាទៅត្រង់ហ្នឹង, មិនដើរច្របូកច្របល់អីៗ

ដានី៖ ចុះអ៊ីមានប្រសាសន៍ថាមកប្រជុំនៅស្តាត?

ស៊ីវន៖ មកប្រជុំនៅស្តាតមកជួបគ្នាម្តងៗ ដល់ជួបគ្នាច្រើនមិនបានសួរគ្នាទេ។

ដានី៖ មិនបាននិយាយសួរសុខទុក្ខគ្នា!

ស៊ីវន៖ មិនបានទេ! តែដល់ម៉ោងប្រើបគេឆែកយើងអីអស់ចឹងចូលអង្គុយនៅកៅអី ចប់ហើយ ហើយចាំស្តាប់ទៅដល់ម៉ោងចេញវិញ ហូបបាយៗ, ហូបបាយហើយសម្រាកតាមកន្លែងរៀងខ្លួនៗ

ដានី៖ ចុះអ៊ីមានដែលឮកងពល១៧០អីដែរទេ?

ស៊ីវន៖ ឮតើស! ប៉ុន្តែមិនដឹងថាកងពលស្អីគេទេ គេហៅស៊ីច័ន្ទចក្រី រាងគាត់ស្អាតណាស់ណាៗ

ដានី៖ ស្អាត?

ស៊ីវន៖ ឥឡូវមិនដឹងស្លាប់បាត់ហើយៗ

ដានី៖ អត់ដឹងថាកងពល ចាន់ ចក្រីហ្នឹង មានឮល្បីថាក្បត់អី គេចាប់គេអីទេ?

ស៊ីវន៖ គេនិយាយថាក្បត់ណាកាលហ្នឹង ប៉ុន្តែគ្រាន់តែខ្ញុំធ្លាប់ឃើញគាត់ទៅរៀនហ្នឹងមិនសមមនុស្សក្បត់ទេ ខ្ញុំមិនជឿក្បត់ទេ រាងគាត់ស្អាតណាស់ណា! ខ្ញុំអត់ជឿទេ ប៉ុន្តែដល់ក្រោយមក ស្រាប់តែបាត់គាត់ៗ អាគេថាក្បត់ៗ បើនិយាយមែនទែនទៅ ខ្ញុំច្បាស់ត្រង់ថាចេះ ឲ្យតែមានទំនាស់ស្អីគ្នា ចេះតែនាំគ្នាថាគ្នាក្បត់ៗ

ដានី៖ អូ! អ៊ីមានប្រសាសន៍ថា ជួនណាគំនុំបុគ្គលទៅ...?

ស៊ីវន៖ ហ្នឹងហើយ! ខ្ញុំសង្ស័យថាចឹងៗ

ដានី៖ គំនុំបុគ្គលទៅ ដល់ពេលម្នាក់ទៀតថាអានេះក្បត់ ដល់ពេលអានោះថាយើងនេះក្បត់អីទៅ ដល់ពេលចឹងអាចថាគេចាប់យើងតាមខ្សែតាមអីចឹងទៅៗ

ស៊ីវន៖ គេចាប់ គេដកអីចឹងទៅ ព្រោះខ្ញុំឃើញមុខគាត់ហ្នឹង ពេលដែលទៅរៀន កាលហ្នឹងទៅទាំងអស់គ្នា ប្រធានៗអីចឹងអីណា គេយកតែប្រធានៗទេ ខ្ញុំចេះអង្គុយមើល ហើយគាត់អង្គុយ គាត់ឡើងមានមតិមានយោបល់ច្បាស់លាស់របស់គាត់ណាស់ណាៗ

ដានី៖ ចាន់ ចក្រី?

ស៊ីវន: ហ្នឹងហើយ! រៀងគាត់ស្អាតទៀត រាងធំដំបងខ្ពស់សស្គុស គាត់រាងស្អាតណាស់រាងទំនងតែម្ដង មេទ័ពគឺទំនង ។

ដានី: អ៊ំឃើញគាត់ឡើងនិយាយឆ្នាំណា?

ស៊ីវន: ឆ្នាំ៧៦ហ្នឹង ដែលគេហៅទៅរៀនហ្នឹង ទំនងដូចជាខែ៥មិនដឹង ខែ៦មិនដឹង ។

ដានី: ហ្នឹងខាងបូព៌ា គាត់?

ស៊ីវន: ហ្នឹងហើយ! គាត់នៅខាង សោ ភឹម ។ ខ្ញុំទៅរៀនពេទ្យធ្លាប់ជួបប្រពន្ធគាត់ ប្រពន្ធតា សោ ភឹម កូនគាត់ ។

ដានី: ឈ្មោះអីទៅ?

ស៊ីវន: ខ្ញុំអត់ដឹងឈ្មោះទេ ព្រោះបែកក្រុមរៀងៗខ្លួន ហើយម្យ៉ាងដូចថាខាងនិរតីនៅផ្សេង បស្ចិមនៅផ្សេង អត់ដែរយើងនៅជាមួយគ្នាទេ ។ ច្បាស់លាស់ណាស់ តែហ៊ានប្រឫបូកប្រឫបល់ គេដឹង គេរាយការណ៍ពីយើង ថាចេះចុះ ។

ដានី: ចុះជំនាន់ហ្នឹងយើងអត់មានប្រឡូកប្រឡំអី មិត្តភក្តិអី ដឹកស៊ីអី ។

ស៊ីវន: មិត្តភក្តិអី អត់ទេ! បើថាធ្វើការដីងតែធ្វើការចឹងទៅ ជួបគ្នានិយាយញញឹមញញែមដាក់គ្នាតែប៉ុណ្ណឹងបានហើយ ដល់និយាយល្អិតចេះចុះអីអត់ ។ អត់ទាំងសួរថាប្ដីឈ្មោះអ្វី ធ្វើការនៅណាអីអត់សួរបានទេ ។

ដានី: បាទ! ហើយចុះខាងឧត្ដរ ពូថាក្បត់អីដែរអីអត់?

ស៊ីវន: ហ្នឹងហើយ ពូដែរតើស! ឈ្មោះតាញឹម ។

ដានី: ហ្នឹងពាយ័ព្យ!

ស៊ីវន: អូ! ពាយ័ព្យទេ(សើច) ។

ដានី: ឧត្ដរ តើ!

ស៊ីវន: បើ តាញឹម បានខ្ញុំធ្លាប់ឃើញ ។

ដានី: តាញឹមធ្លាប់ឃើញ! គាត់រាងយ៉ាងម៉េចទៅ ។

ស៊ីវន: រាងខ្មៅ ខ្មៅខ្ពស់! ប៉ុន្តែចរិកគាត់ក៏ល្អ សុទ្ធតែល្អទាំងអស់ ខ្ញុំអត់ជឿថាក្បត់អីទេ ។ ឃើញយើងអីចឹង ក្អួយ! សុទ្ធតែរាបសារណាស់ អាហ្នឹងមិនខុសពីតា នង សួន ទេ ។ តាហ្នឹងក៏ខ្ញុំធ្លាប់ឃើញ ។

ដានី: ប៉ុន្តែអ៊ំអត់ជឿទេ! មានដែរសួរអ៊ំប្រុសអីដែរអត់?

ស៊ីវ៉ុនៈ ក្នុងចិត្តយើងមិនជឿទេ! យើងធ្លាប់មើលមនុស្សដែរណា ប៉ុន្តែដល់ពុថាក្បត់យើងក៏មិនហ៊ាន មានមតិមានយោបល់ តែមានមិនស្រួលគេចាប់យើងទៀតហើយ ។

ដានីៈ តែនៅខាងក្រៅអី, ដូចថាអ៊ំប្រុសអី មានដែលលួចសួរគាត់ មានដែលសួរថា អូ!តាហ្នឹងសម ក្បត់មិនសមក្បត់អីដែរទេ?

ស៊ីវ៉ុនៈ អត់ទេ! មិនសួរ មិននិយាយទាំងអស់ហ្នឹង គឺអនុវត្តភាសាមិនសួរ មិននិយាយ មិនដឹង មិនឮ គឺចប់ ។

ដានីៈ ធ្វើមិនដឹង មិនឮទៅ!

ស៊ីវ៉ុនៈ អាហ្នឹងបានរស់បាន ។

ដានីៈ ចឹងអ៊ំរស់នៅសម័យនោះភ័យខ្លាចដែរ?

ស៊ីវ៉ុនៈ ខ្វល់ដែរ, ភ័យដែរ! ចុងក្រោយបង្អស់អត់កុហកទេ យើងនៅស្រុកសំឡូត តាម៉ុក មកចាប់គាត់ដែរ ថាគាត់ក្បត់ ។

ដានីៈ ចឹង?

ស៊ីវ៉ុនៈ ហ្នឹង! ចាប់ក្រោយបង្អស់អាឆ្នាំ៩៦ហ្នឹង មុនយើងត្រូវជាមួយរដ្ឋាភិបាលបន្តិចហ្នឹង ។

ដានីៈ ចឹង?

ស៊ីវ៉ុនៈ ហ្នឹងហើយ! មកចាប់ខុសត្រូវគ្នា១៥នាទីតើស ។

ដានីៈ គាត់ទៅណា?

ស៊ីវ៉ុនៈ អ្នកមកចាប់ហ្នឹង មកជួបគាត់ហើយ! ប៉ុន្តែពួកគាត់ណោះមានកងទ័ពវ៉ា៣ឡាន ហើយអ្នកមករកចាប់តែ១ឡាន ហើយមានគ្នាប្រហែលជា៥នាក់ ហើយណោះគ្នាប្រហែលចង់៣០ ដល់ចឹងដូចទំនងជាធ្វើអីអត់កើតណា ក៏ឡានហ្នឹងត្រឡប់ទៅវិញថាទៅយកគ្នាមកទៀត ដល់តែយកគ្នាមកទៀត គាត់នេះដឹងផែនការណ៍ ហីក្មេងៗវាហៅគាត់មកនេះកាលហ្នឹងនៅព្រៃ មកតាំងពីគេហៅស្ពានវែងមក គាត់ចូលមកណោះ ផ្លូវនៅលំបាកដែរ ។

ដានីៈ ៩៦ អ៊ីចឹងនៅមាន តាម៉ុក ចោទថាគាត់ក្បត់ទៀត?

ស៊ីវ៉ុនៈ អូ! កាលហ្នឹងមិនពួកប៉ៃលិនបះបោរចូលមក ។

ដានីៈ ចុះកូនប្រសារគាត់ តាមុត?

ស៊ីវ៉ុនៈ រឿង តាមុត ហ្នុងនៅណាអន្លង់វែង ទើបមកដែរ ។

ដានីៈ តាមុត គាត់មកក្រោយទេ?

ស៊ីវ៉ុនៈ មកក្រោយតើស! ពីមុននៅអន្លង់វែងទាំងអស់ ។

ដានី៖ ប៉ុន្តែ គាត់មកឆ្នាំណា តាមុត?

ស៊ីវន៖ កាលហ្នឹង ដូចជាបោះឆ្នោត៩៨ ។

ដានី៖ ចឹង?

ស៊ីវន៖ ហ្នឹងហើយ! ទើបតែមកទេ ។

ដានី៖ ទើបតែមកទេ ចឹងកាលពីមុនអត់ជួបជាមួយអ៊ំប្រុសទេ?

ស៊ីវន៖ ឃើញជួបដែរ តែគ្រាន់ថា គាត់ដូចនៅក្នុងអាណិត្តអ្នកមកថ្មី យើងអ្នកចាស់ ។ តាមុតហ្នឹង កាលមុនប្រជាជនបោះឆ្នោតធ្លាប់មួយសារហើយហ្នឹង បានតាម៉េតហ្នឹង ជួយចុះជួយឡើង ដល់តែមានលែងស្គាល់គ្នា ទាស់គ្នាវិញណ៎ ។

ដានី៖ ចឹង! គាត់ទាស់គ្នាដែរពីរនាក់ហ្នឹង?

ស៊ីវន៖ ចុះប្រឆាំងគ្នា បានទៅជារឿង ។

ដានី៖ ចុះក្រោយៗមុនគាត់ខូចអីហ្នឹង គាត់?

ស៊ីវន៖ មិនជួបដែរ មិនដែរអីអត់ទេ!

ដានី៖ អត់ទេ! ដាច់គ្នាតែម្តងចឹង?

ស៊ីវន៖ ចុះបើវាយគ្នាចុងក្រោយនោះ កាលហ្នឹងបែកគ្នាណា គាត់ហ្នឹងត្រូវទទួលខុសត្រូវរួមនៅស្រុកសំឡូត ឃើញសភាពការណ៍មិនស្រួល គាត់ទៅរាយការណ៍ឲ្យរដ្ឋាភិបាលក្រោយពេលដែលយើងត្រូវគ្នាហ្នឹង ។ ហ្នឹងហើយ! គាត់ឃើញសភាពការណ៍គេអត់ស្រួលចឹង គាត់ទៅរាយការណ៍ ទៅរាយហ្នឹង គាត់ហៅខ្ញុំក៏ទៅ កូនក៏ទៅ ទៅតែមួយទេ នៅកូន៣,៤នាក់នៅផ្ទះទាំងអស់ ហើយស្រាប់តែគេបះបោរ អៀង ដាន និង មាស មុត បះបោរ ។ បោះបោរនាំកម្លាំងទៅថៃ ហើយពួកខ្ញុំទៅខាងណុះ ដល់ទៅខាងណុះទៅរដ្ឋាភិបាលមាន បងសេង គាត់នៅភូមិភាគ៥រៀបចំគាត់ឲ្យមកវាយ ឲ្យគាត់មកឈរជើងវាយជាមួយពួកហ្នឹងវិញ ចឹងតើស! វាយទៅបាន២ឆ្នាំ បានពួកហ្នឹងចុះចូលវិញ ពួកតាមុតហើយតាដានហ្នឹងចុះចូល គេថាអីចេះ «បើចុះចូលតាមណាចូល បើចុះចូលតាម តាម៉េត គេមិនចូលទេ» ដល់អីចឹង តាមាស សុភា គាត់ចុះមក ចុះមកដល់ធ្វើពិធីនៅកន្លែង តា ម៉េត ដដែលហ្នឹង ។

ដានី៖ តែតាំងពីហ្នុងមក គាត់អត់ដែលនិយាយគ្នា អត់ដែលទាក់ទងអី?

ស៊ីវន៖ និយាយ! ជួបទៅនិយាយទៅ គ្រាន់តែថាមិនសូវមានការងារហ្នឹងជួប ព្រោះតាមុតហ្នឹងមិនត្រូវឡើងទៅលើ អគ្គសេនាធិការលើ តាទិត អីមិនទៅលើអស់ហើយ នៅតែគាត់មួយនៅភូមិភាគនៅវាយប្រចាំការរៀបចំទីបញ្ជាការ មន្ទីរបក្សអីហ្នឹង គាត់រៀបចំទាំងអស់ហ្នឹង ។

ដានី: ដល់ពេលអ៊ីប្រុស គាត់នៅភូមិភាគ៥?

ស៊ីវន: ហ្នឹងហើយ! នៅភូមិភាគ៥ ប្រចាំទិសសំឡូត គាត់ធ្វើរហូតហ្នឹង ។

ដានី: នៅភូមិភាគ៥ហ្នឹង រហូតដល់ខូចតែម្តង?

ស៊ីវន: អត់ទេ! នៅភូមិភាគ៥ ប្រចាំការនៅទិសសំឡូត តាំងពីប្រជាជននៅសំឡូត នៅព្រៃនៅអីអត់ទាន់គាត់ គាត់និយាយជាមួយ បង សេង ណា គាត់ថា គាត់សុំនៅស្រុកសំឡូត ដរាបណាប្រជាជនបានជីវភាពធូរធារអីចឹងទៅណា បានខាងលើផ្លាស់គាត់ទៅណាគាត់ទៅបាន ហើយបើថាប្រជាជននៅស្រុកសំឡូតមិនទាន់ធូរធារទេគាត់មិនទៅទេ គាត់និយាយថាអីចឹងម៉ង មិនទៅតែម្តង គាត់ចង់ឲ្យប្រជាជនមានផ្ទះមានសំបែង ។ ដល់តែពេលទៅ ឡើងក្រោយទៅ គេឲ្យឡើងអគ្គសេនាធិការនោះឡើងផ្កាយ២ ។ អាផ្កាយហ្នឹង ក៏គាត់មិនចង់ឡើងដែរ តាកែ គឹមយ៉ាន កាលជំនាន់ តាកែ គឹមយ៉ាន ឲ្យគាត់ឡើង អាហ្នឹងគាត់និយាយប្រាប់ខ្ញុំទេណា "បងយ៉ានឲ្យពុកឡើង តែពុកថាមិនបាច់ទេឲ្យក្មេងៗឡើងទៅ ព្រោះយើងឡើងក៏មិនដឹងឡើងទៅធ្វើស្អីដែរ បន្តិចទៅធ្វើទ័ពធ្វើអីលែងកើតទៅហើយឲ្យក្មេងៗវាឡើងទៅ" ដល់ចឹង តាកែ គឹមយ៉ាន គាត់ថា "បងឯងគេឲ្យឡើង គេសុទ្ធតែសូកប៉ាន់ បងឯងគ្មានសូក១រៀលហើយអត់ឡើង អត់ចង់ឡើងម៉េច ត្រូវតែឡើង" អីចឹងបានឡើងផ្កាយ២ហ្នឹង ។

ដានី: ផ្កាយ២ តែគាត់មានតួនាទីអីដែរ?

ស៊ីវន: តួនាទីមេបញ្ជាការរង ដូចថាមកប្រចាំនៅភូមិភាគ៥ ។

ដានី: ភូមិភាគ៥?

ស៊ីវន: ហ្នឹងហើយ!

ដានី: ផ្កាយ២ ជាមេបញ្ជាការរងនៅជាមួយ តាប៊ុន សេង?

ស៊ីវន: ចា៎! ហើយជាទីប្រក្សាអគ្គសេនាធិការ ។

ដានី: ទីប្រក្សាអគ្គសេនាធិការ មានមេបញ្ជាការរងយុទ្ធភូមិភាគ៥ ។ ហើយពីមុនហ្នឹង?

ស៊ីវន: មុនហ្នឹង គាត់មិនដឹងស្អីទេ! ខ្ញុំមិនសូវច្បាស់ដែរការងារហ្នឹង ប៉ុន្តែគ្រាន់តែដឹងថាមានការងារបក្សប្រចាំនៅសំឡូតហ្នឹងទៀត ។

ដានី: អូ! ការងារបក្សប្រចាំទិសនៅសំឡូត?

ស៊ីវន: ចា៎! ដូចគាត់រងពីបង សេង ណា! បង សេង ប្រធាន គាត់អនុ ។ ហើយគាត់គណៈបក្សប្រជាជនតាំងពីដើម ។

ដានី: អូ! តាំងពីចូលមក ។

ស៊ីវនៈ ចាំ! ព្រោះគាត់ច្បាស់លាស់ណាស់ ។

ដានីៈ គាត់មានដែរនិយាយពីរឿង ឪពុកគាត់អីប្រាប់អីទេ?

ស៊ីវនៈ អត់ទេ! ស្វាត់មិនដែលពូតែម្តង មិនដឹងថាធ្វើស្អី ។

ដានីៈ គាត់អត់ដឹងខ្លួនគាត់ដែរឬក៏គាត់...?

ស៊ីវនៈ មិនដឹង! នៅនេះគេអនុវត្តន៍ មិនដឹង មិនពូ មិននិយាយ ។

ដានីៈ លាក់ការណ៍ខ្ពស់រស់បានយូរ!

អ្នកជិតខាងៈ អីសុំកាត់ប្រសាសន៍ (ស្តាប់ពុំបាន) ។

ស៊ីវនៈ គាត់អត់និយាយទេ តែនិយាយទៅ គាត់ស្លាប់បាត់ហើយភ័យអីទេ ។

ដានីៈ ពេលយើងមានសង្គ្រាមជាមួយយួន កាលហ្នឹងអីនៅចាំទេ?

ស៊ីវនៈ នៅក្នុងព្រៃ?

ដានីៈ អត់ទេ ក្នុងឆ្នាំ៧៦?

ស៊ីវនៈ ៧៦-៧៧ ។

ដានីៈ ពីឆ្នាំ៧៦ ចាន់ ចក្រី អ៊ីពូសូរក្បត់ ។

ស៊ីវនៈ ពូថាក្បត់ ។

ដានីៈ តាញឹម ក៏ពូថាក្បត់?

ស៊ីវនៈ ចាំ!

ដានីៈ ខ្ញុំនឹកឃើញខាងខត្តរ កុយ ធួន ហៅធុច ។

ស៊ីវនៈ តាធុច ហ្នឹងក៏រាងគាត់ស្អាតបាតណាស់ ។

ដានីៈ គេថាក្បត់ដែរ?

ស៊ីវនៈ ហ្នឹងហើយក្បត់ ។

ដានីៈ មានកងពល៣១០ ។

ស៊ីវនៈ ហ្នឹងហើយស្គាល់ ។

ដានីៈ ឈ្មោះ អឿន?

ស៊ីវនៈ តាអឿន ក៏ខ្ញុំស្គាល់ ។

ដានីៈ ស្គាល់ដែរ?

ស៊ីវ៉ន: ស្គាល់ តាអឿន ឃើញខ្ញុំកាលពីដើមច្រើនតែហៅសមមិត្ត គាត់និងតាម៉េត ស្គាល់គ្នារាប់អានគ្នា ។

ដានី: អីចឹង?

ស៊ីវ៉ន: ចុះពីដើមធ្លាប់នៅជាមួយគ្នានោះ នៅចាប់ដៃ ។

ដានី: គាត់នៅពីខាងភ្នំប្រសិទ្ធ?

ស៊ីវ៉ន: នៅចាប់ដៃគ្នា ស្គាល់គ្នា ហើយរាងគាត់ស្អាតណាស់ តាអឿន ហ្នឹង ប្រពន្ធក៏ខ្ញុំស្គាល់ ។

ដានី: ប្រពន្ធឈ្មោះអីគេ?

ស៊ីវ៉ន: ភ្លេចអស់ហើយ កាលហ្នឹងប្រពន្ធគេយកមកនៅកន្លែងពោធិ៍ចិនតុង គ្រួសារមេៗគេច្រើនយកមក គេរៀបចំមានផ្ទះមានសំបែង បាយទឹកគិតគូរ ដល់ក្រោយមកពុសូរថាក្បត់ ។

ដានី: អីចឹងមេខាងកងពលនិយាយទៅស្គាល់ទាំងអស់?

ស៊ីវ៉ន: អត់ទេ ។ តាសារឿន ក៏ខ្ញុំស្គាល់ដែរ ។

ដានី: តាសារឿន (០៥)?

ស៊ីវ៉ន: ហ្នឹងហើយ៨០១ ស្គាល់ ។

ដានី: ប្រពន្ធគាត់ឈ្មោះអី?

ស៊ីវ៉ន: ប្រពន្ធឈ្មោះ ណូន គាត់ល្អណាស់ទាំងអស់គ្នាមេៗ ខ្ញុំមិនចេះតែមុខលោកក្លួយទេចេះតែនិយាយ គឺល្អតែម្តង បើឃើញយើងឈឺ យើងគ្រុន យើងអត់ខោអាវស្លៀក ឲ្យ នេះឯងយកក្រមាមួយទៅ ។

ដានី: អ៊ំស្គាល់ប្រពន្ធតាសារឿន ច្បាស់ដែរ?

ស៊ីវ៉ន: ច្បាស់ ។

ដានី: គាត់អ្នកស្រុកណា ណូន?

ស៊ីវ៉ន: ពួកហ្នឹងមកពី មិនដឹងជាកំពត ឬតាកែវ ។ មកពីហ្នឹងទាំងអស់ខាងខ្មែរ តាម៉ុក ។

ដានី: លឺថាគាត់នៅរស់តាំប្រពន្ធ?

ស៊ីវ៉ន: អត់ទេ នៅចោលអស់ហើយ តាម៉ុក នៅចោលទាំងអស់ សូម្បីតែកូនមួយក៏មិនសល់ដែរ ។

ដានី: គ្នាឯងហ្នឹង?

ស៊ីវ៉ន: អាចុងក្រោយហ្នឹង ។

ដានី: ដូចថាតាម៉ុក, តាសារឿន មកពីខាងនិរតី ស្គាល់គ្នា គ្នាឯងហ្នឹង?

ស៊ីវ៉ន: គ្នាឯងហ្នឹង ។

ដានី: ម៉េចអីចឹងនោះ យើងតស៊ូ យើងបដិវត្តន៍ ខបមាថាគ្នាឯងស្គាល់គ្នា តាំងពីតូចរហូតដល់ចាស់ អីគិតថាក្បត់គ្នាកើតដែលអត់?

ស៊ីវន: ចុងក្រោយបងស្រីសូម្បីតែតាខ្ញុំ ក៏ចង់កុនដែរ គាត់តាមចាប់ អ៊ី ឈាន ហើយអ៊ី ឈាន មកប្រាប់តាខ្ញុំ បានដឹង។ ទៅដល់ប៉ៃលិនចូលរៀន ឈ្មោះណាដែលគាត់ប្រុងយកវៃចោល គាត់គូសប៊ិចក្រហម ដល់អីចឹង អ៊ី ឈាន អត់មកជួប ដល់អត់មកជួបភ័យខ្លាចរត់ទៅវិញ តាម៉ុក រត់។

ដានី: តាម៉ុក រត់ដែរ?

ស៊ីវន: រត់! ពូ អ៊ី ឈាន និយាយប្រាប់ខ្ញុំ បានខ្ញុំដឹង។

ដានី: អ៊ី ឈាន និយាយថាម៉េច?

ស៊ីវន: គាត់ហៅខ្ញុំបងសង្សា ហៅលេង បងសង្សាឯងមើលសមអី គូសឈ្មោះឯងសុទ្ធតែក្រហម អាក្រហមបងសង្សាឯងដឹងទេ អាហ្នឹងគេវៃចោល ខ្ញុំអត់ខ្ចីមកជួប ដល់អីចឹងពេលទៅវិញឲ្យគេជូនឡានស្រួលបួលគាត់ប្រកាសតែម្តង គាត់ថា យើ!អាក្មេងឯងចង់សាកជាមួយមនុស្សចាស់ តាម៉ុកហ្នឹង កាលហ្នុងខ្ញុំពូ អ៊ី ឈាន និយាយទេ មិនដឹងមែន ឬមិនមែនទេ។

ដានី: ឆ្នាំណាដែលហ្នឹង?

ស៊ីវន: ឆ្នាំ៩៥ហ្នឹងណា៎។

ដានី: កាលគាត់មក?

ស៊ីវន: កាលហ្នឹងមកចូលទាំងអស់កងទ័ពប្រហែល៨០០០នាក់មក កាលហ្នឹងតាម៉ុករត់ ដល់រត់ពួកហ្នឹងដេញមក។

ដានី: អីចឹងអ៊ឹ អឿន ហ្នឹងក៏ស្គាល់ច្បាស់ តាសារឿន ក៏ស្គាល់ច្បាស់។

ស៊ីវន: តាសាន។

ដានី: តាសាន (០៥) ក៏ច្បាស់ដែរ?

ស៊ីវន: ចា៎!

ដានី: ប្រពន្ធគាត់?

ស៊ីវន: ស្គាល់ ឈ្មោះយាយវីន ស្អី វីន ទេ។ ហ៊ីង សាវីន ចាស់ហើយគាត់។

ដានី: ហើយគាត់ប្អូន តាអាន?

ស៊ីវន: ចា៎! តាអាន នៅ។ ស្គាល់ តាអាន ទេ?

ដានី: ស្គាល់ ធ្លាប់ជួបគាត់។

ស៊ីវន: ហ្នឹងហើយ ញូដូចសម្ភាសន៍ម្តង ។

ដានី: បាទ!

ស៊ីវន: ស្គាល់តើ! នៅស្រុកជិតគ្នា ។

ដានី: អ៊ំស្គាល់តាអាន ច្បាស់ដែរ?

ស៊ីវន: ស្គាល់ ។

ដានី: ធ្លាប់ជួបគាត់ទេពីសម័យតស៊ូ?

ស៊ីវន: ពីក្មេងជួប តែតាំងពីយើងរត់ចូលព្រៃមក បាត់លែងដែលជួបគ្នា ។

ដានី: ពេលដែលយើងរំដោះភ្នំពេញហើយក៏អត់ដែលជួប?

ស៊ីវន: អត់ដែលជួប គាត់ធ្វើការតាមស្រុកយើងនៅភ្នំពេញ បើយាយវីន ខ្ញុំធ្លាប់ជួប ។

ដានី: យាយវីន អ៊ំធ្លាប់ជួប?

ស៊ីវន: ចាំ!

ដានី: ជួបគាត់នៅណា?

ស៊ីវន: នៅភ្នំពេញ ។

ដានី: កាលជំនាន់គាត់អនុកងពល?

ស៊ីវន: គាត់មកលេងដល់អ៊ីចឹងជួបគ្នា ។

ដានី: កាលគាត់បែក៧៥ដំបូង តាសាន គាត់នៅវេងកងពល៥០២ ។

ស៊ីវន: អ៊ីចឹងទៅមកជួបគ្នា ។

ដានី: គាត់នៅវេងយូរដែរបានគាត់ទៅ?

ស៊ីវន: មិនយូរប៉ុន្មានទេ នៅប្រហែលជា១ឆ្នាំ មិនដល់មិនដឹង លឿនដែរស្រាប់តែឃើញដូរបាត់ទៀតហើយ ។

ដានី: ពីណាឡើងជំនួសគាត់?

ស៊ីវន: ដូចអត់ច្បាស់ទេ ពីណាទេ ខ្ញុំអត់សូវដែលទៅកន្លែងគេ ហើយអត់សូវដឹង តែដឹងថា តាល្វៃ គាត់នៅជាប់ ។

ដានី: តាធួក?

ស៊ីវន: តាធួក ក្រោមទេ ក្រោយមកឲ្យមកនៅព្រលាន ។

ដានី: នៅព្រលាន?

ស៊ីវន: កំពង់ឆ្នាំង ។

ដានី៖ គាត់នៅព្រលានកំពង់ឆ្នាំងវិញ?

ស៊ីវន៖ ហ្នឹងហើយ ទទួលភារកិច្ចអប់រំអ្នកយកពីណាពីណីមក ថាក្បាត់អីចឹង យកមកឲ្យធ្វើការនៅព្រលាន ហើយឲ្យបងធូក គាត់មើលទៅ បើសិនជាអ្នកក្បត់មកវាប់រយរាប់ពាន់អីចឹងវាហួសហេតុពេកហើយ ។

ដានី៖ ឲ្យគាត់មើល ពីព្រោះភាគច្រើនអ្នកធ្វើព្រលានហ្នឹងគេថាពួកក្បត់?

ស៊ីវន៖ ថាអីចឹង តែដល់មកយើងឃើញឲ្យបើកឡាន ឃើញគ្នាប្រឹងធ្វើ ដូចគ្មានអី ។

ដានី៖ ពីណាអ្នកថាអីចឹង?

ស៊ីវន៖ ចេះតែល្បី គេផ្សាយអីចឹង គេបញ្ជូនមកគេថាក្បត់១០០នាក់ លើកទី២ក្បត់ទៀតហើយ ១០០នាក់ ។

ដានី៖ ធ្វើព្រលានហ្នឹងអីចាំទេ គេចាប់ផ្ដើមធ្វើពីអង្កាល់?

ស៊ីវន៖ ដូចជា៧៦ហ្នឹង ។

ដានី៖ អ៊ំមានធ្លាប់ទៅមើល ក្រុមពេទ្យមានដែលទៅព្រលានហ្នឹងដែលអត់?

ស៊ីវន៖ ពេទ្យទៅ តែខ្ញុំអត់បានទៅទេ ឲ្យតែគេទៅ ប្រចាំការ ឲ្យទៅមើល ។

ដានី៖ ព្រលានហ្នឹងយើងធ្វើខ្លួនឯង ឬក៏ខាងណាគេជួយ?

ស៊ីវន៖ ចិន ។

ដានី៖ ចិនគេមកជួយធ្វើ?

ស៊ីវន៖ ខ្លួនក្អំចិនតើស! បច្ចេកទេសចិន ។

ដានី៖ បច្ចេកទេសចិន យើងគ្រាន់តែជាកម្មករ?

ស៊ីវន៖ យើងគ្រាន់ហ្នឹងហើយ ទៅរៀនសូត្រពីគេ ទៅជួយធ្វើគេ ចិន គាស់ដើមត្នោត ហ្នឹងដើមត្នោតច្រើនណាស់ ខ្ញុំឮគេប្រជុំនិយាយទេ ទី១គាស់ដើមត្នោត យកឫសចេញឲ្យអស់ ។

ដានី៖ អ៊ំអត់ដែលទៅសោះតែម្ដងព្រលានហ្នឹង?

ស៊ីវន៖ ទៅតែជិះឡានមួយភ្លែតៗ ។

ដានី៖ យើងជិះគ្រាន់តែឃើញ?

ស៊ីវន៖ គ្រាន់តែផ្លែលេង ។

ដានី៖ តែអត់ដែលឈប់មើលគេគាស់ គេធ្វើទេ?

ស៊ីវន៖ អត់ទេ ព្រោះខ្ញុំមានពេទ្យមួយកន្លែងទៀតនៅកំពង់ឆ្នាំងហ្នឹង សាខាមកពីភ្នំពេញឲ្យទៅមើល

ដានី៖ មានពេទ្យមួយកន្លែង ពេទ្យរបស់អីដែរនៅកំពង់ឆ្នាំង?

ស៊ីវន: ចាំ!

ដានី: តែខ្ញុំឆ្ងល់មួយអ៊ី! កាលសម័យហ្នឹងយើងមានព្រលានយន្តហោះនៅពោធិ៍ចិនតុងមួយ ហើយម៉េច បានគេធ្វើព្រលានយន្តហោះកំពង់ឆ្នាំងមួយទៀត?

ស៊ីវន: ព្រលានហ្នឹងតាមគេប្រជុំគេនិយាយទេ អ៊ំស្ដាប់បាន គេថាត្រូវធ្វើព្រលានត្រៀមសង្គ្រាម គេណែនាំអ៊ីចឹង ព្រលានហ្នឹងគឺជាព្រលានរបស់យោធា ។ ព្រលានយើងពោធិ៍ចិនតុងព្រលានស៊ីវិល ។ ព្រលានយោធានេះទីមួយត្រូវខួងភ្នំដាក់យន្តហោះត្រៀមសង្គ្រាមហើយទី២ធ្វើមន្ទីរពេទ្យក្នុងដីដែរ មន្ទីរពេទ្យក៏មានក្នុងដី ។

ដានី: មន្ទីរពេទ្យក្នុងដីនៅណា?

ស៊ីវន: មិនដឹងត្រង់ណា តែគេប្រែធ្វើហើយនៅហ្នុង ។

ដានី: ឆ្នាំណាដែលគេចាប់ផ្ដើម?

ស៊ីវន: ៧៦-៧៧គេចាប់ផ្ដើមធ្វើ ។

ដានី: ៧៦ចុងឆ្នាំ ឬក៏ដើម?

ស៊ីវន: ចុង ។

ដានី: អ៊ីចឹងគេប្រែ គេប្រជុំហ្នឹង ប្រជុំនៅក្នុងកងពលរបស់អ៊ំ ឬទៅប្រជុំនៅ?

ស៊ីវន: កងពល ។

ដានី: ហើយខាងធ្វើព្រលាននៅកំពង់ឆ្នាំង គេឲ្យអ៊ំប្រុសជាអ្នកគ្រប់គ្រង?

ស៊ីវន: ចាំ! គាត់មើលរួមទាំងអស់ឲ្យតែព្រលាន ព្រលានទូទាំងប្រទេស ។

ដានី: តាមខេត្តដែលចុះយន្តហោះបានសុទ្ធតែនៅក្នុងកងពលហ្នឹងទាំងអស់?

ស៊ីវន: ចាំ! ឲ្យតែមានកន្លែងចុះយន្តហោះបាន គាត់ទៅ គាត់ដឹង ហើយពួកខ្ញុំដឹងតែថាតាមព្រលាន ដូចជា បាត់ដំបង អីណាអ៊ីចឹងមានពេទ្យទៅប្រចាំការ ។

ដានី: តែអ៊ំ! ព្រលានយន្តហោះយោធាដែលគេប្រុងធ្វើសង្គ្រាមហ្នឹង អ៊ំប្រុសគាត់អ្នកមើលផ្ទាល់ តែនេះធ្វើមករបស់មជ្ឈិម របស់ក្រសួងការពារជាតិ ខាងលើគេអ្នកធ្វើ ឬយ៉ាងម៉េច?

ស៊ីវន: គេណែនាំពីលើមក គាត់អ្នកមើលតៗ គាត់អ្នកមើលផ្ទាល់ ។

ដានី: តាសុន សេន គាត់ធ្លាប់ចុះទៅ?

ស៊ីវន: ទៅតើស គាត់ធ្លាប់ ។ តាសុន សេន ចុងក្រោយវ៉ៃគាត់ស្លាប់អស់រលីង តែកូនគ្មានសល់ ។

ដានី: តាសុន សេន បើជិនាន់ហ្នឹងគាត់អីគេ?

ស៊ីវន: គាត់ទទួលកងទ័ពទូទាំងប្រទេស ។

ដានី: ទទួលដា?

ស៊ីវន: អាហ្នឹងស្អីគេ អគ្គសេនាធិការ ។

ដានី: អគ្គសេនាធិការ?

ស៊ីវន: ត្រូវហើយ ។

ដានី: កាលជំនាន់ហ្នឹង អ៊ំសុន សេន ជាអគ្គសេនាធិការ ។ ហើយអ៊ំប្រុសគាត់មានតួនាទី?

ស៊ីវន: គាត់គ្រាន់តែរងៗ ។

ដានី: អគ្គសេនាធិការរងដែរ?

ស៊ីវន: ចា៎! បងសារឿន ក៏រង ។

ដានី: តាសារឿន ក៏រង ។

ស៊ីវន: តាមុត អ៊ី ។

ដានី: តាមុត ក៏រងដែរ ។

ស៊ីវន: ហ្នឹងហើយ ប្រធានៗរងគាត់ ពេលទៅធ្វើទស្សនៈកិច្ចប្រធានៗទៅជាមួយ តាសុន សេន ទៅ ។

ដានី: ៣នាក់រង?

ស៊ីវន: មិនដឹង៣ ឬប៉ុន្មានទេ វាច្រើនដែរជំនាន់ហ្នឹង ប្រធានកងពលច្រើន ។

ដានី: ចាំមើលពេលដែលយើងធ្វើព្រលាន គេនិយាយថាពួកក្បត់ៗដែលថាមកធ្វើព្រលានហ្នឹង ក្រោយមកមានសភាពការណ៍យ៉ាងម៉េច ក្បត់មែនឬយ៉ាងម៉េច?

ស៊ីវន: អត់សូវមានទេ អ្នកគ្រប់គ្រងតាឌួកមកប្រជុំ ខ្ញុំស្តាប់គាត់និយាយទេ គាត់ថាដូចអ្នកខ្លះ ចេះតែថាគ្នាក្បត់ គ្នាមកដល់គ្នាខំធ្វើ ដូចថាគ្នាខ្វះចន្លោះតិចតួចចេះតែចោទគ្នា ។ ចុះឲ្យគ្នាធ្វើការងារធ្ងន់ហួសគ្នាធ្វើមិនបានចោទគ្នាថាគេក្បត់ ។

ដានី: តាឌួក គាត់ហ៊ាននិយាយអីចឹងដែរក្នុងពេលប្រជុំ?

ស៊ីវន: គាត់អត់ខ្លាចទេពេលទៅប្រជុំ ព្រោះប្រជុំហ្នឹងមានគាត់ហ្នឹងប្រធានកងពលគេឲ្យយើងរាយការណ៍ តាមកន្លែងទាំងអស់ ដូចខ្ញុំពេទ្យរាយខាងពេទ្យ តាឌួកខាងព្រលាន គាត់រាយពីហ្នឹងមក ។

ដានី: រាយការណ៍ប្រាប់អ៊ំប្រុស?

ស៊ីវន: ហ្នឹងហើយ រាយជាក់ស្តែងអីចឹង ដល់អ៊ំប្រុសគាត់សរុបទៅយកទៅរាយឲ្យ តាសុន សេន តគ្នា ។

ដានី៖ តាធួក សព្វថ្ងៃគាត់នៅណា?

ស៊ីវ៉ន៖ តាធួក?

ដានី៖ បាទ!

ស៊ីវ៉ន៖ ឥឡូវ?

ដានី៖ បាទ!

ស៊ីវ៉ន៖ ស្លាប់បាត់យូរហើយ ។

ដានី៖ គាត់ស្លាប់ហើយ?

ស៊ីវ៉ន៖ ៨២មិនដឹង ៨៤ ស្លាប់ហើយ៨៤ ត្រូវគ្រាប់ៗ គ្រាប់ផ្លោងមកៗ

ដានី៖ កាលហ្នឹងមានពួកក្បត់មកធ្វើ កន្លែងហ្នឹងមានមន្ទីរឃុំឃាំង មន្ទីរសន្តិសុខនៅក្បែរព្រលានហ្នឹង ដែរអត់ទេ?

ស៊ីវ៉ន៖ ខ្ញុំមិនច្បាស់ដែរ ព្រោះអត់ដែរទៅ និយាយត្រង់ កូនតូចៗ

ដានី៖ ពេលដែលនៅពោធិ៍ចិនតុង ខានលើមកគេប្រាប់ថាក្បត់?

ស៊ីវ៉ន៖ គេអត់ដាក់នៅហ្នឹងទេ ។

ដានី៖ គេយកទៅណា?

ស៊ីវ៉ន៖ គេយកទៅកន្លែង តាឌុច នោះ កន្លែងស្អីគេ ។

ដានី៖ ស-២១?

ស៊ីវ៉ន៖ ស-២១ ហ្នឹងហើយ ។ ម៉េចៗគេរៀបទៅហ្នឹងហើយ គេអត់ដាក់ទេ កន្លែងអីចឹងៗ ។

ដានី៖ កាលហ្នឹងអ៊ំស្គាល់ ឌុច ដែរ?

ស៊ីវ៉ន៖ ស្គាល់ ។

ដានី៖ ស្គាល់គ្នាតាំងពីពេលនៅពោធិ៍ចិនតុងហ្នឹង?

ស៊ីវ៉ន៖ ស្គាល់តាំងពីការ តាំងពីឆ្នាំ៧៥ហ្នឹងមក ។

ដានី៖ គាត់ការឆ្នាំ៧៥?

ស៊ីវ៉ន៖ ចា៎! ខ្ញុំទៅការដែរ ។

ដានី៖ អ៊ំសាច់ញាតិជាមួយគាត់?

ស៊ីវ៉ន៖ អត់សាច់ញាតិទេ តែខ្ញុំប្រធានពេទ្យគេអញ្ជើញទៅចូលរួមក្នុងកម្មវិធី តែប្រធានយើងមាន មុខទៅហើយ ។

ដានី៖ អីចឹងឌុច ហ្នឹងមួយនៅក្រោមអ៊ំប្រុសដែរ?

ស៊ីវ៉ន: មិនដឹងម៉េចទេគាត់ ដូចជាមនុស្សផ្សេង ព្រោះគាត់ក្រោមអគ្គសេនាធិការនោះតើស ។

ដានី: ព្រោះអ៊ំជាអគ្គសេនាធិការរងដែរ ខ្ញុំសួរគ្រាន់តែបញ្ជាក់ច្បាស់ទេ មិនមែនសួរថាចង់អីទេ ។

ស៊ីវ៉ន: អត់អីទេសួរទៅ ព្រោះស្លាប់បាត់ហើយ ។

ដានី: ប្រពន្ធរបស់ឌុច ក្រែងអ្នកកំពង់ឆ្នាំងដែរ?

ស៊ីវ៉ន: អ្នកកំពង់ឆ្នាំង នៅឃុំពាមដែរ តែភូមិហុងត្នោត ខុសគ្នា ។

ដានី: មិនមែនសាច់ញាតិរបស់អ៊ំ ឬអ៊ំប្រុសទេ?

ស៊ីវ៉ន: អត់ទេ តែអ្នកដែលធ្លាប់នៅព្រៃជាមួយគ្នា យើងចេះតែរាប់អានគ្នាទៅ ។

ដានី: ឌុច កាលពីជំនាន់អ៊ំនៅពោធិ៍ចិនតុង ឌុច គាត់ខស្សរាហ៍ចេញចូលមកអ៊ំ ជាមួយអ៊ំប្រុសអី ដែរ?

ស៊ីវ៉ន: ដូចមិនសូវឃើញទេ ឃើញតែពេលប្រជុំ រៀនធំៗដូចនៅស្តាតអីចឹង ខ្ញុំឃើញតែពេលហ្នឹង

ដានី: អ្នកដែលធ្លាប់ស្គាល់ជាមួយអ៊ំ នៅក្នុងកងពល ឬនៅពេទ្យ បាត់ទៅច្រើនដែលអត់? ដូចថាគេ យកទៅកន្លែងតាឌុច អីហ្នឹង?

ស៊ីវ៉ន: ដូចអត់សូវ នៅជាមួយគាត់អត់សូវបាត់ ព្រោះគាត់អត់ប៊ិនរាយការណ៍ គ្នាខុសតិចតួចអត់ រាយការណ៍អីចឹងទៅវាអត់មានរឿងទេ ។ តាផល ចៅហ្វាយស្រុកសុទ្ធតែតាខ្ញុំ គេរាយការណ៍ ថាគាត់ចេះចុះ មកដល់គាត់ថានៅហ្នឹងឲ្យនៅ ។

ដានី: ចៅហ្វាយស្រុកសំឡូតហ្នឹង?

ស៊ីវ៉ន: ចៅហ្វាយស្រុករាល់ថ្ងៃហ្នឹង ។

ដានី: ឈ្មោះអី ផល?

ស៊ីវ៉ន: ហែម សុផល ។

ដានី: អីចឹងកាលហ្នឹងគាត់នៅក្នុងកងពលជាមួយអ៊ំប្រុសដែរ?

ស៊ីវ៉ន: ហ្នឹងហើយនៅដែរ គាត់ថាអត់អីទៅនៅរហូតទៅ រត់ជាមួយគ្នាទៅ ផ្ញើកងទ័ពវៃជាមួយគ្នាចុះ ឡើងមកទល់ឥឡូវមានស្អី ។

ដានី: គាត់នៅរាប់អានអ៊ំ?

ស៊ីវ៉ន: ដន្លងខ្ញុំ ។

ដានី: ដន្លងគ្នា?

ស៊ីវ៉ន: ទៅជាដន្លងឥឡូវ ។ គាត់ច្រើនតែជួយគេអីចឹង ថាក្បត់មកបាត់ដំបងអីចឹង គេថាក្បត់គាត់ មើល កុំយកគ្នាទៅវៃអី ទុកហ្នឹងហើយម៉េចតាមដានគ្នាទៅ រស់ទៅ ។

ដានី៖ អ៊ំកាលហ្នឹងចិនមានមកធ្វើការជាមួយអ៊ំច្រើនដែរ?

ស៊ីវន៖ មានតើស! ធ្វើនៅព្រលានយន្តហោះ ។

ដានី៖ ធ្វើនៅណា?

ស៊ីវន៖ ព្រលានយន្តហោះពោធិ៍ចិនតុង, ព្រលាននៅកំពង់ឆ្នាំង, នៅព្រលានបាត់ដំបង ។

ដានី៖ បាត់ដំបងមានធ្វើព្រលានដែរ?

ស៊ីវន៖ ចិននៅហ្នុង នៅបង្រៀនអ្នកបើកយន្តហោះផ្នែកយោធា ។

ដានី៖ នៅបាត់ដំបង?

ស៊ីវន៖ ចា៎!

ដានី៖ កន្លែងពេទ្យអ៊ំមាននៅអត់?

ស៊ីវន៖ អត់ទេ ខ្ញុំចិនអត់មានចូល ភាគច្រើនតែបច្ចេកទេសយោធា ។

ដានី៖ កាលហ្នឹងអ៊ំ, អ៊ំប្រុសចេះចិនអត់? គាត់ខស្សរាហ៍ទៅចិនអីចឹង?

ស៊ីវន៖ មិនដឹងម៉េច បកប្រែគេមិនដឹង ។

ដានី៖ ចិនមកភាគច្រើនមានអ្នកបកប្រែ?

ស៊ីវន៖ គេមិនសូវឲ្យយើងមកនិយាយទេ ច្រើនមានអ្នកបក ។

ដានី៖ មានអ្នកបក អីចឹងអ្នកបកហ្នឹងជនជាតិខ្មែរ ឬជនជាតិចិន?

ស៊ីវន៖ ចិនកាត់ចិន តែនៅស្រុកខ្មែរយូរ ឥឡូវហ្នឹងនៅអូស្រ្តាលី ឈ្មោះតាហាក់ៗ ។

ដានី៖ តាហាក់ ហ្នឹងអ្នកបកប្រែចិនឲ្យអ៊ំប្រុស?

ស៊ីវន៖ ទាំងអស់ តាមបច្ចេកទេស ដូចថាគាត់ចុះទៅមួយកន្លែងមានអ្នកបកប្រែនៅហ្នឹង ចុះទៅមួយកន្លែងនោះ មានអ្នកនៅនោះ ។

ដានី៖ តាហាក់ គាត់បកប្រែនៅណា?

ស៊ីវន៖ នៅពោធិ៍ចិនតុង។ គាត់ហ្នឹងគ្រូពីដើម គ្រូចិន ទាំងប្តី ទាំងប្រពន្ធ មានកូនមួយពិបាកមើល ពេកឲ្យមកខ្ញុំ១ខែកន្លះខ្ញុំយកមកមើល ។

ដានី៖ តាហាក់ ហ្នឹងក្មេង ឬចាស់?

ស៊ីវន៖ កាលហ្នឹងក្មេងដែរ អាយុប្រហែល២៩, ៣០ចុះ ។

ដានី៖ កាលហ្នឹងចំណាស់ៗអ៊ីដែរ?

ស៊ីវន៖ ស្រករគ្នា ស្រករគាត់ ថាប្អូនគាត់តិចតួច ឬដំណាលគាត់ ។

ដានី៖ តែឥឡូវគាត់នៅអូស្ត្រាលី?

ស៊ីវន៖ គាត់នៅអូស្ត្រាលីថាបើកហាង។

ដានី៖ នៅរដ្ឋណា?

ស៊ីវន៖ មិនដឹងរដ្ឋណា យកកូនទៅ អាកូនមួយដែលខ្ញុំចិញ្ចឹមហ្នឹងគាត់យកទៅ។

ដានី៖ ឆ្នាំណាគាត់យកទៅ?

ស៊ីវន៖ គាត់យកទៅដូចជាឆ្នាំដែលនៅជំរំខាវអ៊ីដាង ឆ្នាំប៉ែតប៉ុន្មាន ដូចជា៨៤មិនដឹង ៨៥មិនដឹង។

ដានី៖ ឥឡូវគាត់មានដែលទាក់ទងមកអីទេ?

ស៊ីវន៖ អត់ទេ! នឹកឃើញថាយើងធ្វើបុណ្យបានតែប៉ុណ្ណឹងបានហើយ។

ដានី៖ ដូចថាមានទំនាក់ទំនងជាមួយគ្នា សំបុត្រអី ឬក៏ធ្លាប់ជួបមុខគ្នា?

ស៊ីវន៖ តែមានអ្នកខ្លះរត់ទៅអាមេរិក ហ្នឹងបានធ្លាប់ទំនាក់ទំនង។

ដានី៖ អីកាលឆ្នាំ៧៧ យើងចាប់ផ្តើមវៃជាមួយយួន?

ស៊ីវន៖ គេអ្នកវៃ៧៧។ ៧៨-៧៩ មានបើកយន្តហោះទម្លាក់ហើយ រៀននៅបាត់ដំបងហ្នឹង ដល់អីចឹងទៅទម្លាក់នៅយួន យួនវៃមកនេះ ៧៩ខ្ញុំដឹកអ្នករបួស។

ដានី៖ អ្នករបួសដែលបើកយន្តហោះហ្នឹង?

ស៊ីវន៖ បើកយន្តហោះ។

ដានី៖ ឆ្នាំចិតសិបប៉ុន្មានដែលយើងអាចចេះបើកយន្តហោះ ហើយបើកយកទៅ?

ស៊ីវន៖ បើកបាន៧៨-៧៩ គេហៅសេ-២៣។ កាលហ្នឹងយន្តហោះហ្នឹងវាវាង គេដាក់ពណ៌ប៉ារ៉ាស្លាបវាវាងត្រង់ៗ ខ្ញុំមិនសូវចាំលេខទេ ទៅទម្លាក់គ្រាប់បែក។

ដានី៖ កាលហ្នឹងមានប៉ុន្មានគ្រឿង?

ស៊ីវន៖ ច្រើនដែលតើស! យន្តហោះពីមុនថ្មីៗទើបនឹងទិញ នៅពោធិ៍ចិនតុង។

ដានី៖ ដល់យើងបើកយន្តហោះទៅទម្លាក់គេបាញ់នេះ?

ស៊ីវន៖ ដល់អីចឹងយួនបាញ់នេះ។

ដានី៖ នេះទាំងអស់?

ស៊ីវន៖ ដល់បាញ់នេះយន្តហោះលោតឆ័ត្រ ឃើញដឹកមករបួសកាលហ្នឹងតែ២នាក់ទេ ដល់៧៩ខ្ញុំដឹករហូតមក ដឹកពីភ្នំពេញដល់កំពង់ឆ្នាំង ដល់បាត់ដំបង ហើយរត់មកដល់គាសាញហ្នឹង។

ដានី៖ ឥឡូវគាត់នៅរស់ទេ?

ស៊ីវន៖ នៅរស់ នៅភូមិកញ្ជាំង អ្នកភូមិកញ្ជាំងភាគច្រើនអ្នកបើកយន្តហោះ។

ដានី៖ អ្នកដែលធ្លាប់បើកយន្តហោះទៅហើយ យួនបាញ់នេះ គាត់លោតចេញមកហើយនៅរស់?

ស៊ីវន: លោតចេញហើយខ្ញុំដឹកតាមមក មើលគាត់ជាទៅ ឥឡូវរៀបចំប្រពន្ធកូនឲ្យនៅភូមិកញ្ចាំង ។

ដានី: នៅភូមិកញ្ចាំងគាត់ឈ្មោះអី?

ស៊ីវន: ឈ្មោះពូវេង ។

ដានី: វេង ហើយប្រពន្ធគាត់ឈ្មោះអី?

ស៊ីវន: ផាត ។

ដានី: វេង-ផាត គាត់អ្នកបើកយន្តហោះតែម្តង ។

ស៊ីវន: អ្នកបើកយន្តហោះច្រើនណាស់នៅហ្នឹង បើកសេ-៤៧ ។

ដានី: វេង ប្រពន្ធឈ្មោះផាត ។

ស៊ីវន: ចា៎! ដូចជាសេ-១២៣ ខ្ញុំមិនច្បាស់ទេរឿងលេខយន្តហោះ ។

ដានី: ៧៨-៧៩?

ស៊ីវន: ចា៎! ៧៩ ដឹកមកហ្នឹងថ្ងៃទី៦ ។ ថ្ងៃទី៦ធ្លាក់ ដឹកមកតែម្តង ខ្ញុំចាំណាស់ថ្ងៃហ្នឹងព្រោះឆេះអស់រលីងគ្មាសៀកបានតែខោខ្មី ។

ដានី: ឥឡូវនៅមានស្នាក់ស្នាម?

ស៊ីវន: នៅស្នាមដែរហ្នឹងស្នាមពេញខ្លួន គ្រាន់តែមើលអត់សូវដឹង ។ ខ្ញុំអត់ស្នានថាជាផង ។

ដានី: តែកាលហ្នឹងរៀនបើកយន្តហោះរៀននៅបាត់ដំបងទេ?

ស៊ីវន: រៀននៅបាត់ដំបង រៀនពីចិន ។

ដានី: ចិនមកបង្រៀននៅបាត់ដំបង?

ស៊ីវន: ទៅរៀននៅបាត់ដំបង រៀននៅចិន ហើយមានមនុស្សទៅរៀននៅចិនទៀត បើកអាធន់៥ធន់៦ អាល្បឿនលឿនជាងសំលេង ។

ដានី: អាធន់៥-៦! ដល់ពេលបើកនៅបាត់ដំបងធន់សេ-១២៣?

ស៊ីវន: ចា៎! យន្តហោះយោធា ខុទ្ទម្ភាគចក្រ ។

ដានី: បានប៉ុន្មានគ្រឿងទៅ?

ស៊ីវន: ខ្ញុំអត់ដឹង អត់ដែលមកសោះ បាត់ដំបងទើបនឹងរត់មកស្គាល់ ។

ដានី: ពេលដែលយើងវៃជាមួយយួនចាប់ពីចុងឆ្នាំ៧៧ អ៊ីប្រុសគាត់រវល់ទេ?

ស៊ីវន: គាត់រវល់ដែរ ។

ដានី: ដូចថាគាត់នៅពោធិ៍ចិនតុង ឬគាត់ទៅប្រចាំការនៅសមរភូមិ?

ស៊ីវនៈ អត់ទេ នៅតែពោធិ៍ចិនតុង ទី១យន្តហោះចេញ-ចូល បរទេសចេញ-ចូលនោះ ទី២យន្តហោះយោធា បង្រៀនមើលតាមកន្លែងគេរៀន គាត់នៅរវល់តែហ្នឹង អត់ដែលទៅទេ រឿងព្រំដែនមានគេអ្នកផ្សេង ព្រោះគេខាងកងទ័ពជើងគោក ។

ដានីៈ ជើងគោកពីណាគេកាលហ្នឹង?

ស៊ីវនៈ តាសារឿន អីហ្នឹងជើងគោក, តាសានអីហ្នឹង ។ គេហៅ០៥, ០៦ ។ តាអឿន ៣១០ហ្នឹង ។

ដានីៈ ហ្នឹងគេហៅជើងគោក?

ស៊ីវនៈ ចាន់ ចក្រី អីហ្នឹង ។

ដានីៈ ប៉ុន្តែទ័ពជិនាន់ហ្នឹង ចាន់ ចក្រី, តាអឿន គាត់ក្បត់ គាត់ទៅបាត់ហើយ ។

ស៊ីវនៈ គាត់ក្បត់ បាត់មុខតែនៅទ័ពរបស់គាត់ ។

ដានីៈ តែឆ្នាំ៧៧? តាសុន សេន គាត់ចុះទៅតាមសមរភូមិអត់?

ស៊ីវនៈ មិនដឹងម៉េច ខាងលើមិនសូវដឹង ។

ដានីៈ តែអាំប្រុស ដឹងតែគាត់អត់ទៅទេ?

ស៊ីវនៈ អត់ទេ អត់ទាន់បានទៅណាទេ ដឹងតែរឿងយន្តហោះ ។ បច្ចេកទេសយន្តហោះ ត្រូវវៃត្រូវអីវៃកើត មិនកើតយន្តហោះ មិនងាយទេ ទាល់តែគេកុនបានគេហៅយើងទៅ ។

ដានីៈ អាំខស្សាហ៍ជួប តាសុន សេន ទេកាលហ្នឹង?

ស៊ីវនៈ ខ្ញុំ?

ដានីៈ អាំប្រុស?

ស៊ីវនៈ អាំប្រុសគាត់ជួបជាប្រចាំ ។

ដានីៈ អាំសុន សេន កាលហ្នឹងគាត់នៅភ្នំពេញ ឬគាត់ចុះទៅតាមសមរភូមិ?

ស៊ីវនៈ កន្លែងដែលគាត់ជួបៗតែភ្នំពេញ តែត្រង់គាត់ចុះពេលណាអត់ដឹងទេ បែបចុះតាមមើល ។

ដានីៈ កាលហ្នឹងអាំយើងនៅក្នុងភ្នំពេញពេលវៃជាមួយយួន កាលហ្នឹងយើងយ៉ាងម៉េច? យើងគិតថាយើងវៃឈ្នះយួន ឬយ៉ាងម៉េចកាលហ្នឹង?

ស៊ីវនៈ គិតតែចាញ់តែម្តង ។

ដានីៈ ម៉េចអីចឹង?

ស៊ីវនៈ បានថាចាញ់ព្រោះមួយថ្ងៃហ្នឹងខ្ញុំឮ តាផល គាត់នៅជាប់គាត់គេរាយការណ៍ថា ហៅខ្ញុំថាម៉ែវាអើយរៀបចំឥវ៉ាន់ណា ។

ដានីៈ គាត់ថាអីចឹង?

ស៊ីវន: គាត់និយាយលេងផង មែនផង ខ្ញុំនឹកឃើញថាសភាពការណ៍មានតែ២ទេ បើមិនឈ្នះ ចាញ់ ។ បើចាញ់រត់ហើយគ្មានធ្វើអី ។

ដានី: អ៊ំព្រួយបារម្ភទេកាលហ្នឹង?

ស៊ីវន: ធម្មតា ។

ដានី: អត់មានភ័យព្រួយពេលយួនវ៉ៃចូលមក?

ស៊ីវន: ភ័យដែរ បើសិនជាយើង អ្នកខ្លះថាបើកុំរត់មានអី តែខ្ញុំបើអត់រត់ក៏មិនបាន គេវ៉ៃងាប់ហើយ ។

ដានី: ម៉េចអីចឹង?

ស៊ីវន: ចុះគេដឹងថាយើងគ្រួសារទាហាននោះអីចឹងខ្លាច បើដឹងនៅរស់ណារត់ធ្វើអី រត់វេទនាចង់ងាប់ ។

ដានី: តែអ៊ំខស្សរាប់ចេញ-ចូលមកលេងស្រុកកំណើតលេង?

ស៊ីវន: ខ្ញុំចេញ-ចូលម្ដងកាលហ្នឹង កូនខ្ញុំទី២ហ្នឹងបាន២ខែកន្លះ គាត់ទៅប្រជុំព្ធ តានួន ជា និយាយប្រាប់ថា គេចាប់ឪពុកក្មេកម៉េតឯង យកទៅដាក់កន្លែងឃុំឃាំង ហ្នឹងឪពុកខ្ញុំ កាលពីមុនគាត់ធ្វើប្រធានសហករណ៍ ដល់ពេលគេប្រើរបស់របរខ្ជីខ្ជារខ្ជះខ្ជាយ គាត់ចេះតែណែនាំ ដូចកែវ ចាន គាត់ថា របស់នេះបានដោយសារញើសឈាមកងទ័ពយើងត្រូវសន្សំសំចៃទៅ យើងមិនកំណាញ់ទេប្រើក៏ប្រើទៅ ប៉ុន្តែកុំយកទៅចោលអារ៉ាត់អារាយ ដល់អីចឹង គេថាគាត់ក្បត់ អីចឹងបានដឹង ។

ដានី: គេថាគាត់ក្បត់ ឆ្នាំណាដែលគេចាប់ឪពុកអ៊ំ?

ស៊ីវន: ឪពុកខ្ញុំចាប់៧/៨ហើយ ។

ដានី: ឆ្នាំ៧/៨ហើយ?

ស៊ីវន: ហ្នឹងហើយ ។

ដានី: ហើយបាន អ៊ំនួន ជា ប្រាប់?

ស៊ីវន: អ៊ំនួន ជា គាត់ប្រជុំប្រាប់តាខ្ញុំ ខ្ញុំចុះមកមើល គេយកគាត់ទៅដាក់នៅកន្លែងការដ្ឋានមែន ។

ដានី: ពីណាគេអ្នកចាប់គាត់?

ស៊ីវន: សហករណ៍គេហ្នឹងមិនដឹងពីណាគេ ពួកគេថាអីចឹង ។

ដានី: ដល់ពេលអ៊ំចុះទៅយ៉ាងម៉េចទៅ? អ៊ំប្រុសទៅជាមួយអត់?

ស៊ីវន: អត់ទេ! ទៅតែខ្ញុំ ដល់ទៅដល់គាត់ថាទៅមើលពិតប្រាកដឬអត់ ដល់ទៅមើលវាប្រាកដមែន អត់ជួបគាត់ខ្ញុំឡប់មកវិញ បានបងម្នាក់ក្រោយទៀតគាត់ទៅយក ។

ដានីៈ បងណា?

ស៊ីវនៈ បងហ្នឹងគាត់អនុខ្ញុំ ។

ដានីៈ ឈ្មោះអីគេគាត់?

ស៊ីវនៈ ឈ្មោះហៀង គាត់ថាឯងមិនបានទៅទេ ចាំគ្នាទៅយកពូ-មីង ។

ដានីៈ យកមកនៅភ្នំពេញ?

ស៊ីវនៈ ចា៎! យកមកនៅភ្នំពេញ ។

ដានីៈ ហៀង ស្រីឬប្រុស?

ស៊ីវនៈ ស្រី ។

ដានីៈ គាត់នៅដែរតើស?

ស៊ីវនៈ រាល់ថ្ងៃនៅភូមិកញ្ចាំង ។

ដានីៈ មួយក្រុមអ៊ំនៅភូមិកញ្ចាំងទាំងអស់?

ស៊ីវនៈ នៅហ្នឹងទាំងអស់ ដោយឡែកតែខ្ញុំមកកាប់ចំការនៅនេះ ។

ដានីៈ កាលហ្នឹងម៉េចបាន អ៊ំនួន ជា ដឹងថាគេចាប់ឪពុកអ៊ំ?

ស៊ីវនៈ គេរាយការណ៍ឲ្យគាត់តាមខេត្ត តាមស្រុកភូមិ ។

ដានីៈ គេរាយការណ៍ឲ្យគាត់?

ស៊ីវនៈ កាលហ្នឹងគាត់ប្រធានប្រជាជន សភាប្រជាជន តែគាត់អាចដឹង ។

ដានីៈ អ៊ំស្គាល់ តានួន ជា ច្បាស់ដែរ?

ស៊ីវនៈ ស្គាល់ដែរ ស្គាល់ទាំងប្រពន្ធ ។

ដានីៈ ស្គាល់ទាំងប្រពន្ធទៀត?

ស៊ីវនៈ ចា៎!

ដានីៈ តែជំនាន់អ៊ំនៅពោធិ៍ចិនតុង ឧស្សាហ៍ជួបគាត់ ឧស្សាហ៍និយាយលេង?

ស៊ីវនៈ យើងអត់សូវជួបទេ ទើបមកជួបរត់មក ។

ដានីៈ តែកាលហ្នឹងដែលគាត់ប្រាប់អ៊ំប្រុស ថាឪពុករបស់អ៊ំត្រូវគេដាក់ឃុំ កាលហ្នឹងឆ្នាំ៧៨ហ្នឹងដែរ ប្រជុំ?

ស៊ីវនៈ ៧៧-៧៨ ។ ចុង៧៧ហ្នឹង គឺខ្វាំងតែម្ដង រឹបណាស់ ។

ដានីៈ គណៈសហករណ៍ដែលចាប់?

ស៊ីវនៈ គណៈឃុំមិនដឹង គណៈសហករណ៍មិនដឹង គេរាយការណ៍តៗ ។

ដានី៖ តែអ៊ំអត់មានទៅជួបគណៈសហករណ៍សួរនាំឲ្យច្បាស់?

ស៊ីវ៉ន៖ អត់សួរអី គ្រាន់ថាបាត់ចង់ទៅជួបគាត់ សួរគាត់ផ្ទាល់តែម្ដង ដល់អត់ឃើញយើងប្រញាប់ឡប់ទៅកន្លែងវិញ ។

ដានី៖ ដល់ពេលគាត់មក ឪពុកអ៊ំគាត់មកនៅជាមួយមានសួរនាំគាត់អត់?

ស៊ីវ៉ន៖ គាត់មក សួរគាត់ថាគេចាប់មែន យកទៅដាក់គេបង្អត់បាយឡើងហើមសាច់ ។

ដានី៖ តែអត់ដឹងឈ្មោះអ្នកចាប់?

ស៊ីវ៉ន៖ ដឹងឈ្មោះស្អីណាផាប់អស់បាត់ ។

ដានី៖ ឈ្មោះអីទៅស្ទាប់បាត់?

ស៊ីវ៉ន៖ ឈ្មោះស្អីទេ គាត់ប្រាប់តែខ្ញុំអត់សូវចាំ គេមកពីកន្លែងផ្សេងមកនៅ ។

ដានី៖ សំណាងណាស់ចេះ អ៊ំនួន ជា គាត់ដឹង គាត់ប្រាប់?

ស៊ីវ៉ន៖ ហ្នឹងហើយ ។

ដានី៖ កាលហ្នឹងឪពុកម្ដាយយើងអត់សូវមានអីទាក់ទងគ្នា?

ស៊ីវ៉ន៖ អត់លើង គេអត់ឲ្យមកលេងផ្ទះផង ។

ដានី៖ ដូចថាយើងជាគ្រួសារកម្មាភិបាលថ្នាក់ខ្ពស់ដែរ?

ស៊ីវ៉ន៖ អត់មកលេងបានទេ គេប្រកាសអីចឹងតែម្ដង យើងគ្រួសារកម្មាភិបាលមកលេង គ្នាអត់កម្មាភិបាលគ្នាចង់មក អីចឹងអត់ទាំងអស់គ្នា គិតអីចឹង បើយើងមក គ្នាប្អូនៗនៅជាមួយយើង គ្នាចេះតែចង់ទៅដែរ ដល់គោលការណ៍គេមិនឲ្យទៅ មិនមកទាំងអស់ អីចឹងអត់ជួបទាំងអស់គ្នា ។

ដានី៖ អ៊ំនួន ជា គាត់កាន់ទ័ពដែរ?

ស៊ីវ៉ន៖ មិនកាន់ទ័ពទេ តែគាត់ប្រជុំរួម ដូចគាត់ខាងស្អីខ្ញុំមិនសូវចាំ ។

ដានី៖ គាត់ប្រាប់?

ស៊ីវ៉ន៖ ចាំ!

ដានី៖ អ៊ំប៉ុល ពត អ៊ំស្គាល់គាត់ច្បាស់ទេ?

ស៊ីវ៉ន៖ អត់ទេ អត់ដែលឃើញទេ គ្រាន់តែធ្លាប់ឃើញរៀនរួមៗឃើញគាត់តែម្ដង គាត់អង្គុយទី១ ទី២, ទី៣ ឃើញមុខតែពេលហ្នឹងទេ ។

ដានី៖ អ៊ំនួន ជា, អ៊ំប៉ុល ពត, អ៊ំវ៉ន វេត គេចោទថាគាត់ក្បត់?

ស៊ីវ៉ន៖ ហ្នឹងហើយថាគាត់ក្បត់ ខ្ញុំនៅតែមិនជឿព្រោះធ្លាប់រស់នៅជាមួយគាត់នៅក្នុងព្រៃគាត់ល្អណាស់ សុទ្ធតែមនុស្សល្អ មនុស្សត្រឹមត្រូវតែម្ដង ដល់គេថាគាត់ក្បត់ ប្រពន្ធគាត់ក៏ល្អ ។

ដានី៖ អ៊ំៗគ្នាចោទថាគាត់ក្បត់?

ស៊ីវនៈ ដូច តាហ៊ូ យន់ ខ្ញុំក៏ធ្លាប់នៅដែរ ។ អ៊ំខៀវ សំផន ។

ដានី៖ អ៊ំថាពួកគាត់ថាពួកគាត់សុទ្ធតែមនុស្សល្អ?

ស៊ីវនៈ ហ៊ូ នឹម អីក៏អីចឹងដែរ អត់ទេ តាមមើលចេះ តាមខ្ញុំគិតមើល ដូចថា គាត់ហ៊ានមានមតិហ៊ាន មានយោបល់ ពេលដែលយើងឈ្នះភ្នំពេញហើយ តាហ៊ូ នឹម គាត់និយាយហើយ អត់ចាយលុយមិនបានទេ ត្រូវតែចាយលុយ តាម៉ុក គាត់បដិសេធន៍ដល់ហើយថាតាហ៊ូ នឹម ក្បត់ ។ តាហ៊ូ នឹម រាងគាត់ក៏ស្អាតដែរ ។

ដានី៖ អ៊ំមានឮថាអត់ចាយលុយអត់បាន?

ស៊ីវនៈ គាត់និយាយអីចឹងតែម្ដង ពេលប្រជុំ ។

ដានី៖ ប្រជុំនៅណា?

ស៊ីវនៈ មិនដឹងគេប្រជុំនៅណា ខ្ញុំឮតាខ្ញុំគាត់និយាយ ស្ងាត់ៗនាំគ្នាជុំគ្នានិយាយថា គិតទៅអ៊ំនេះគាត់និយាយចេះ តានេះនិយាយចោះ ម៉េចទេ ។

ដានី៖ តាម៉ុក ទេអ្នកថាចាយលុយអត់បាន?

ស៊ីវនៈ តាម៉ុក គាត់ថាត្រូវតែអត់ចាយ បើតាហ៊ូ នឹម គាត់ថាអត់ចាយអត់បាន ។

ដានី៖ ហ៊ូ នឹម ឬហ៊ូ យន់?

ស៊ីវនៈ ហ៊ូ នឹម! ហ៊ូ យន់ ស្លាប់តាំងពីមុន គេធ្វើបាបគាត់ស្លាប់តាំងពីមុនហ្នឹងទៀត ។

ដានី៖ មុនហ្នឹងទៀត? តាំងពីជំនាន់ណា?

ស៊ីវនៈ សង្ស័យតាំងពីមុនរំដោះ៧៥ អត់ឃើញគាត់ តែខ្ញុំធ្លាប់ជួបគាត់នៅភ្នំឱរ៉ាល់ មាឌធំ មុខគាត់ស្អាតបាតដែរតើស ។ រាងអ្នកធំទំនងដែរ ។

ដានី៖ ដល់ពេលបែកទៅបាត់គាត់តែម្ដង?

ស៊ីវនៈ អត់ឃើញ ។

ដានី៖ ដល់ពេល ហ៊ូ នឹម គាត់និយាយអីចឹងទៅ, តាម៉ុក គាត់ថាដាច់ខាតអត់ចាយ ។

ស៊ីវនៈ គាត់ថាធ្វើអីចឹងមកពីអ្នកឯងក្បត់ចេះ ក្បត់ចោះ ចាប់គាត់បាត់ស្ងាត់ឈឹងត្រឹមហ្នឹងទៀតទៅ ។

ដានី៖ អ៊ំប៉ុល ពត, នួន ជា, អ៊ំខៀវ សំផន អត់មានយោបល់?

ស៊ីវនៈ អត់សូវហ៊ាននិយាយទេ អ៊ំខៀវ សំផន ព្រោះគាត់ដឹងថា តាម៉ុក តែនិយាយមានរឿងទៀត តាម៉ុក មិនបានទេ ។

ដានី៖ តាម៉ុក កាចណាស់អីចឹង?

ស៊ីវនៈ គេថាផ្ដាច់ការគឺតាម៉ុក ។ ដែលពួកគេនិយាយទេ?

ដានីៈ ខ្ញុំអត់ដែលបានជួបគាត់ ។

ស៊ីវនៈ មុខគាត់ហ្នឹង តែអ្នកខ្លះថាមុខគាត់ស្រដៀងយួន ។

ដានីៈ អីចឹងវិញថាមុខគាត់ស្រដៀងយួន?

ស៊ីវនៈ ស្អាតបាតមិនមែនអាក្រក់ទេ តាម៉ុក សតើស ។

ដានីៈ ខ្ញុំឃើញរូបថត ។

ស៊ីវនៈ មុខគាត់ស្រដៀងយួន គេថាអីចឹងគ្រប់គ្នា ។

ដានីៈ អ៊ីអត់ដែលជួបគាត់ផ្ទាល់ទេ?

ស៊ីវនៈ ជួបដែរ ពេលរៀន ពេលប្រជុំអីឃើញ ជួបមួយភ្លែតៗ ។

ដានីៈ ព្រោះគាត់គណៈភូមិភាគនីរតី អ៊ីនៅក្នុងកងទ័ពអី!

ស៊ីវនៈ តែយើងមិនងាយបានទៅជួបទេ អាហ្នឹងគេប្រជុំតែអ្នកធំៗ បានអ្នកតមកប្រជុំយើងទៀត ។ ទាល់តែចូលក្នុងស្អាតតែម្ដងអាហ្នឹងទើបបានជួប ដូចថាសឹងមួយឆ្នាំជួបបានម្ដង កន្លះឆ្នាំអី ។

ដានីៈ អ៊ីៗដែលអ៊ីស្និតស្នាលជាងគេមានអ៊ីមួយណា?

ស៊ីវនៈ មិនទេ មិនស្និតទេ ។

ដានីៈ អត់មានទេ?

ស៊ីវនៈ ព្រោះយើងចាត់ទុកគាត់ថាជាអ្នកដឹកនាំយើងគោរពគាត់ទាំងអស់ ។

ដានីៈ គោរពហើយគាត់ស្គាល់អ៊ីច្បាស់ ហើយខស្សរាប់និយាយជាមួយអ៊ី?

ស៊ីវនៈ ដូចគ្នា អ៊ីណាក៏អីចឹង ឲ្យតែជួបគាត់និយាយធម្មតា ។

ដានីៈ ដូចថាអ៊ីប្រុសឪពុកគាត់អ្នកតស៊ូដើមចាស់ដែរ ក្រែងលោអ៊ីៗគាត់គោរព ដូចថាស្គាល់យើងរាប់អានយើងស្និតស្នាល អីចឹងដែរ?

ស៊ីវនៈ អីចឹង ។

ដានីៈ អីចឹងអ៊ីៗគាត់ស្គាល់អ៊ីប្រុសច្បាស់?

ស៊ីវនៈ គាត់ស្គាល់ច្បាស់ តែដោយឡែកខ្ញុំអត់សូវច្បាស់ទេ ព្រោះយើងកូនប្រសារ តែបើជំនាន់ លន់ នល់ កូនប្រសារអីចឹងអត់បានទេ ក៏រករឿងដែរ ។

ដានីៈ អ៊ីអាចរៀបរាប់ពេលដែលដូចថា យួនចូលមកអ៊ីចេញពីភ្នំពេញថ្ងៃណា? ចេញយ៉ាងម៉េច? ជួបជុំគ្នាដែរ?

ស៊ីវនៈ ហ្នឹងយួនចូលមានពីរដង ។

ដានី៖ យួនចូលពីរដង?

ស៊ីវន៖ លើកទី១ឆ្នាំ១៩៧០យួនចូលមកម្តង ។

ដានី៖ ឆ្នាំ៧០ យួនចូលមកនៅណា?

ស៊ីវន៖ មកជួយវៃមួយសារ ។

ដានី៖ យួនចូលមក?

ស៊ីវន៖ ខ្ញុំបានធ្វើពេទ្យមើលយួនប្រហែលជា៥០នាក់ដែរ ។

ដានី៖ ពួកវៀតកុង?

ស៊ីវន៖ មិនដឹងពួកណា ពួកហាណូយដែរ ។

ដានី៖ ពួកធ្មេញខ្មៅ?

ស៊ីវន៖ ធ្មេញខ្មៅពួកណា?

ដានី៖ ពួកវៀតកុង ដល់ពេលពួកព្រៃនគរ គេហៅពួកធៀវគី ។

ស៊ីវន៖ អ៎! ធ្មេញខ្មៅជំនាន់ហ្នឹង ។

ដានី៖ គេថាយួនហាណូយ?

ស៊ីវន៖ ពួកហ្នឹងវិន័យស្អាតបាតណាស់ កាលហ្នឹងខ្ញុំគេឲ្យមើលអ្នករបួសប្រហែលជា៥០នាក់ នៅភ្នំពីស យើងវៃអមលាំងហើយដល់ពេលរបួស ដឹកអ្នករបួសហ្នឹងទៅភ្នំពីស ។ ស្គាល់ភ្នំពីសទេ?

ដានី៖ ព្រតែឈ្មោះ ដូចភ្នំវៃចាប កាលពីព្រឹកមិញខ្ញុំចូលទៅខាងកំពង់ឆ្នោត ហ្នឹងគេហៅភ្នំវៃចាប?

ស៊ីវន៖ អត់ទេ អត់ដឹង ដូចជាណោះទេ ភ្នំវៃចាប ជិតកងពល៥២ ។

ដានី៖ នៅខាងណា?

ស៊ីវន៖ ទៅតាមផ្លូវចេះមិនទៅលើ៥២មានភ្នំទៅចេះទៀត ព្រគេនិយាយខ្ញុំអត់ច្បាស់ទេ ។

ដានី៖ អ៊ំពេលដែលយើងរត់យួនវៃចូលលើកទី២ ឆ្នាំ៧៩ យ៉ាងម៉េចដែរ?

ស៊ីវន៖ រត់ ហ្នឹងខ្ញុំចាប់រត់ហើយ ។

ដានី៖ រត់ថ្ងៃណាទៅ?

ស៊ីវន៖ រត់ថ្ងៃទី៨ខ្ញុំ ។

ដានី៖ ថ្ងៃ៨ មករា?

ស៊ីវន៖ ហ្នឹង ។

ដានី៖ ថ្ងៃ៧ មករា ក្រែងយួនចូលមកដល់ភ្នំពេញហើយ?

ស៊ីវន៖ ដូចអត់ទាន់ដល់ អ៎! ចេះ ថ្ងៃទី៦ ខ្ញុំចេញពីភ្នំពេញទៅកំពង់ឆ្នាំង ។

ដានី៖ ទៅណា?

ស៊ីវន៖ ទៅដល់កំពង់ឆ្នាំង ថ្ងៃទី៧ ។

ដានី៖ ជិះអីទៅ?

ស៊ីវន៖ ជិះឡាន ។

ដានី៖ ជិះទៅជាមួយអ៊ំប្រុស?

ស៊ីវន៖ អត់ទេ ផ្សេងគ្នា ឡានខ្ញុំផ្សេង ឡានពេទ្យដឹកអ្នកឈឺដែលថាធ្លាក់យន្តហោះ ។

ដានី៖ អ៊ំទៅជាមួយអ្នកធ្លាក់យន្តហោះហ្នឹង?

ស៊ីវន៖ ចា៎!

ដានី៖ ចុះឪពុកម្តាយអ៊ំ?

ស៊ីវន៖ អត់ទេ! រត់បែកគ្នាត្រឹមហ្នឹងទៀត ។

ដានី៖ បែកគ្នាត្រឹមហ្នឹងទៀតហើយ?

ស៊ីវន៖ បែកតែរហូតតែម្តង ។

ដានី៖ បែកគ្នាត្រឹមហ្នឹងហើយអ៊ំទៅតែម្នាក់ឯងទេ?

ស៊ីវន៖ ខ្ញុំទៅតែជាមួយកូន ។

ដានី៖ កូនប៉ុន្មាននាក់?

ស៊ីវន៖ កូន២នាក់ ហើយតែកុងឡាន ។

ដានី៖ កាលហ្នឹងកូន២នាក់នៅជាប់ជាមួយអ៊ំតែម្តង?

ស៊ីវន៖ ចា៎! ជាប់ ។

ដានី៖ ដល់ជិះមកដល់កំពង់ឆ្នាំងម៉េចទៀតទៅ?

ស៊ីវន៖ ដល់កំពង់ឆ្នាំងដេកហ្នឹងមួយយប់ ស្អែកឡើងទៅបាត់ដំបង ថ្ងៃទី៧ ។

ដានី៖ ដេកនៅកន្លែងណា? នៅព្រលានយន្តហោះ?

ស៊ីវន៖ អត់ទេ! នៅកន្លែងពេទ្យខ្ញុំ ។

ដានី៖ ពេទ្យហ្នឹងនៅម្តុំណា?

ស៊ីវន៖ ពេទ្យហ្នឹងនៅផ្សារកំពង់ឆ្នាំង នៅទីរួមខេត្តកំពង់ឆ្នាំងមានផ្ទះថ្មនៅហ្នឹង ។

ដានី៖ ពេលហ្នឹងមានព្រួយដំណឹងអ៊ំប្រុសដែលអត់?

ស៊ីវន៖ ដឹង គាត់ដឹងចាំតែបញ្ជាកងទ័ពវៃសមរភូមិមុខ ។

ដានី៖ គាត់នៅណា? ម្តុំណាកាលហ្នឹង?

ស៊ីវន: កាលហ្នឹងពូថាគាត់ចេញពីភ្នំពេញហើយ មកតាមផ្លូវទត្តុក្ក ហើយមិនដឹងចេញទៅណាទៀត ទេឡានដូចគ្នា ។

ដានី: យើងមានគេអូ ឬអាយកូម ទាក់ទងគ្នា?

ស៊ីវន: យើងជាមួយប្តី ប្រពន្ធអត់ទេ គេទាក់ទងជាមួយកងទ័ពមាន ។

ដានី: តែអ៊ីដឹងដំណឹងថាគាត់នៅ?

ស៊ីវន: ពូគេថា ។

ដានី: ដល់ពេលអ៊ីសំរាកនៅកំពង់ឆ្នាំងមួយយប់ តមកបាត់ដំបង?

ស៊ីវន: ចេញមកបាត់ដំបងទៀត ។

ដានី: ចេញមកបាត់ដំបង មកនៅណាទៅ?

ស៊ីវន: មកបាត់ដំបងដំបូងគាត់ឲ្យយកសំបុត្រមកឲ្យគេហៅ តានឹម ។ គាត់កាន់កងពលនៅហ្នឹង ។

ដានី: ឈ្មោះអីគេ?

ស៊ីវន: តានឹម ឥឡូវស្លាប់បាត់ហើយ ។

ដានី: តានឹម គាត់កាន់កងពលនៅបាត់ដំបង?

ស៊ីវន: ចាំ!

ដានី: តានឹម អ្នកស្រុកនៅណា?

ស៊ីវន: អ្នកនៅតាមដែរ ។

ដានី: គេផ្លាស់គាត់ឲ្យមកកាន់កងពលនៅបាត់ដំបង?

ស៊ីវន: កងទ័ព ។

ដានី: ឲ្យមកតានឹម ។ ឈរជើងនៅណាទៅ?

ស៊ីវន: ឈរជើងនៅបាត់ដំបងជិតព្រលានយន្តហោះហ្នឹង ។

ដានី: ឲ្យទៅគាត់ម៉េចទៅ?

ស៊ីវន: ឲ្យសំបុត្រ កាលហ្នឹងចិននៅច្រើនឲ្យចិនចេញ ។

ដានី: គាត់ឲ្យសំបុត្រហ្នឹងសរសេរថាម៉េច?

ស៊ីវន: សំបុត្រហ្នឹងគ្រាន់តែដឹងប៉ុណ្ណេះទេ គាត់ផ្តាំចុងព្រលាន ដើមព្រលាន កុំឲ្យនៅ ថ្ងៃទី៨ ដល់ហើយខ្ញុំប្រាប់ដំណឹងថា គាត់គ្រាន់តែផ្តាំថា ដើមព្រលាន ចុងព្រលាន អត់ឲ្យនៅ ហើយក្នុងសំបុត្រហ្នឹងតាមដឹងឲ្យចិនចេញតាម ទៅប៉ោយប៉ែត ព្រោះកាលហ្នឹងដូចរាងប្រធុចញុចដែរ ចិននៅកំពង់ឆ្នាំងក៏ជិះឡានមកជាមួយគ្នាទាំងអស់ សំរុកទៅតាមប៉ោយប៉ែត ។

ដានី៖ ទៅប៉ោយប៉ែតចិននៅ...។

ស៊ីវ៉ន៖ ទៅប្រទេសចិនវិញ។

ដានី៖ ឈ្មោះ នឹម ប្រធានកងពលនៅបាត់ដំបងហ្នឹងក្រោមគាត់?

ស៊ីវ៉ន៖ ក្រោមការចាត់តាំងរបស់គាត់។

ដានី៖ សំបុត្រហ្នឹងអ៊ំកាន់សំបុត្រមកផ្ទាល់ឬយ៉ាំងម៉េច?

ស៊ីវ៉ន៖ ខ្ញុំកាន់ផ្ទាល់។

ដានី៖ គាត់ឲ្យពីអង្កាល់?

ស៊ីវ៉ន៖ គាត់ឲ្យល្ងាចថ្ងៃទី៧។

ដានី៖ អ៊ីចឹងគាត់មកជួបនៅកំពង់ឆ្នាំង?

ស៊ីវ៉ន៖ ចា៎! គេយកមកឲ្យមិនមែនគាត់ទេ ដូចថាមានអ្នកបើកឡានយកមកឲ្យខ្ញុំ ប្រាប់ថាទៅដល់ ប្រាប់ខ្ញុំថា ប្រាប់ នឹម ត្រង់ណាដើមព្រលាន ចុងព្រលាន ប្រាប់តែប៉ុណ្ណឹងទៅហើយកុំនៅឲ្យសោះ ហ្នឹងមិនដឹងម៉េចយើងអត់ដឹង។

ដានី៖ ពេលមកដល់ជួប នឹម ហ្នឹងដែរ?

ស៊ីវ៉ន៖ ជួបនឹម ដើររកជួបម៉ោង១២យប់។

ដានី៖ ជួបគាត់នៅណាទៅ?

ស៊ីវ៉ន៖ ជួបនៅកន្លែងសាលាសកល។

ដានី៖ កន្លែងទឹករលក?

ស៊ីវ៉ន៖ ហ្នឹងហើយ តាំងសាលាសកលចាស់។

ដានី៖ អត់មានជួប តាម៉ុក នៅហ្នឹង?

ស៊ីវ៉ន៖ អត់ទេ។

ដានី៖ អត់ឃើញគាត់?

ស៊ីវ៉ន៖ អ្នកធំយើងអត់ឃើញ អត់ត្រូវជួប។

ដានី៖ ម៉េចទៀតទៅពេលឲ្យសំបុត្រ ដល់ពេលជួប នឹម ឲ្យសំបុត្រទៅគាត់ដែរ?

ស៊ីវ៉ន៖ ដល់ឲ្យទៅគាត់ គាត់រៀបចំចិនឲ្យចេញប្រុសប្រាស់ គេឲ្យខ្ញុំសំរាកនៅសាលាសកលម៉ោងជិតភ្លឺ បានគេមកប្រាប់ចេញពីហ្នឹងទៅទៀត បានមកសំរាកនៅគោកពន្លៃ។

ដានី៖ គោកពន្លៃនៅណាទៅ?

ស៊ីវ៉ន៖ ជិតភ្នំសំពៅ ខ្ញុំទើបនឹងឃើញឥឡូវទេ ពីមុនអត់ស្គាល់ដែរ។

ដានីៈ មកគោកពន្ទៃជួបពីណាខ្លះ?

ស៊ីវ៉នៈ អត់មានជួបពីណាទេ មានតែឡាន២គ្រឿងហ្នឹងមើលអ្នកឈឺ ដល់ល្ងាចបានឃើញពួក តានឹម មកយកខ្ញុំទៅវិញ ។

ដានីៈ យកទៅណាវិញ? យកទៅបាត់ដំបងវិញ?

ស៊ីវ៉នៈ អត់ដល់ទេ លែងហ៊ានចូលបាត់ដំបងហើយ មិនដឹងនៅត្រង់ណាទេដាយ ដល់ជិតភ្លឺបានគេមក ដាស់យើង គេថាយកទៅប៉ៃលិន ខ្ញុំទៅប៉ៃលិនទៀត វវល់រហូត រត់រហូត ។

ដានីៈ ទៅដល់ប៉ៃលិន ។ កាលហ្នឹងរត់តែមួយក្រុមរបស់អ៊ំហ្នឹងទេ អត់មានចូលជាមួយពីណា?

ស៊ីវ៉នៈ អត់ទេ តែមួយក្រុម គេរត់ផ្សេងយើងរត់ផ្សេង ទៅព្រោងព្រាតដូចគ្នា ។

ដានីៈ ថ្ងៃណាដល់ប៉ៃលិន?

ស៊ីវ៉នៈ ថ្ងៃទី៩-១០ដល់ប៉ៃលិន ។

ដានីៈ ដល់ប៉ៃលិនអ៊ំនៅក្រុងប៉ៃលិនតែម្តង?

ស៊ីវ៉នៈ នៅក្រុងហ្នឹង ឃើញអ្នកភ្នំពេញមកហ្នឹងគគោកនៅហ្នឹង មិនដឹងគេមកពីអន្លង់ ។

ដានីៈ នៅប៉ៃលិនកងពលរបស់អ៊ំដែរ ឬអត់ទេ?

ស៊ីវ៉នៈ អត់ទេ គ្រាន់តែមានអ្នកផ្សេង តែមិនដឹងម៉េចទេ អ្នកផ្សេងគេនាំខ្ញុំទៅទៀត ខ្ញុំអត់ស្គាល់ទេ ។

ដានីៈ នាំទៅដល់ណាទៀតទៅ?

ស៊ីវ៉នៈ នាំទៅដល់ប៉ៃលិន ។ មានឡានមួយគ្រឿង ។

ដានីៈ អ៊ំស្នាក់នៅប៉ៃលិនយូរទេ?

ស៊ីវ៉នៈ អត់យូរប៉ុន្មានទេ ប្រហែលជិតមួយខែ បានរត់មកនេះបានមកនៅតាសាញ រត់រហូត ។

ដានីៈ អ៊ីចឹងចេញពីប៉ៃលិនមកនៅតាសាញ?

ស៊ីវ៉នៈ តាសាញនៅជិតវត្ត ព្រោះពេទ្យខ្ញុំ ។

ដានីៈ កន្លែងតាសាញ ផ្ទះតាមុត?

ស៊ីវ៉នៈ ចា៎! ព្រោះពួកខ្ញុំពេទ្យហ្នឹងឡានធំៗប្រហែលជា២០គ្រឿងនៅហ្នឹង ខ្ញុំរកពួកខ្ញុំវិញ ។

ដានីៈ អ៊ីចឹងនៅក្នុងឆ្នាំ៧៩ អ៊ំថានៅ២-៣ខែដែលនៅប៉ៃលិន បានត្រឡប់មកនេះ ខែប៉ុន្មានមក ដល់តាសាញ?

ស៊ីវ៉នៈ មិនយូរប៉ុន្មានទេ ដូចជាខែ៤ដឹង ។

ដានីៈ បើខែ១!

ស៊ីវ៉នៈ ខែ១រត់ហើយ ខែ៤ហ្នឹង ។

ដានី៖ មកដល់គាសាញហ្នឹងជួបអ៊ំប្រុស?

ស៊ីវន៖ អត់ទេ អត់ជួបគ្នា ។

ដានី៖ ដល់ខែ៤អ៊ំនៅគាសាញយ៉ាងម៉េចទៅ?

ស៊ីវន៖ នៅគាសាញហ្នឹងចេះតែមើលអ្នកឈឺហ្នឹងទៅ មានអ្នកឈឺទៀត ចេះតែមើល ។

ដានី៖ អ្នកឈឺកងទ័ព?

ស៊ីវន៖ កងទ័ពហ្នឹង ចេះតែនៅមើលនឹងគេឯង ។

ដានី៖ ខែ៤អ្នកស្រុក អ្នកភូមិនៅហ្នឹងតើស?

ស៊ីវន៖ អ្នកស្រុក អ្នកភូមិអត់សូវឃើញមានទេ ឃើញតែពួកអ្នករត់ច្រើន តែប្រជាជននៅនេះពីមុន អត់សូវមានទេ ។

ដានី៖ ប្រជាជននៅនេះអ្នកស្រុកគេអត់សូវមានទេ?

ស៊ីវន៖ អត់សូវឃើញមាន ភាគច្រើនថារត់ទៅថៃ ខ្ញុំទៅនៅភូមិ៨៣ស្អីគេនោះជនជាតិ ។

ដានី៖ ភូមិ៨៣?

ស៊ីវន៖ ឃើញយើង រត់ហើយ ។

ដានី៖ ភូមិជនជាតិរបស់?

ស៊ីវន៖ ហ្នឹងហើយ មនុស្សគេរាងល្អិតៗ សក់ក្រញាញ់ ខ្មៅៗ ។

ដានី៖ ហើយអ៊ំនៅគាសាញហ្នឹងបានប៉ុន្មានទៅ?

ស៊ីវន៖ នៅបានតិច ថារត់រហូត ។

ដានី៖ បានតិចទៅណាទៀត?

ស៊ីវន៖ ទៅខាងអមលាំង ។

ដានី៖ បកទៅខាងអមលាំងវិញ?

ស៊ីវន៖ ហ្នឹងហើយ ទៅអមលាំង ទៅហ្នឹងបានជួបតាម៉ុកវិញ(សើច) ។

ដានី៖ ទៅអមលាំងទៅជួបតាម៉ុកវិញទៀត?

ស៊ីវន៖ ទៅអមលាំងទៅជួបតាម៉ុកៗ ថាឲ្យធ្វើពេទ្យទទួលខុសត្រូវនោះទៀត កងទ័ពវាប្របូកប្របល់ ។

ដានី៖ ឆ្នាំណាដែលទៅដល់អមលាំងវិញ?

ស៊ីវន៖ ទៅដល់ឆ្នាំហ្នឹងដដែលដូចជាខែ១២ ។

ដានី៖ ខែ១២ ឆ្នាំ៧៩ហ្នឹង?

ស៊ីវ៉ន៖ ហ្នឹងហើយ កងទ័ពប្រប៉ូកប្រប៉ល់ពេក មិនមែនទេខែ៨ ។ ខែ៨ទៅដល់គាត់ឲ្យធ្វើប្រធានពេទ្យនៅហ្នឹង ។

ដានី៖ ពេទ្យរបស់អីគេ?

ស៊ីវ៉ន៖ ពេទ្យរបស់កងទ័ពដដែលហ្នឹងដែលវៃគ្នាហើយរបួសមក ។

ដានី៖ តែកងទ័ពពេលហ្នឹងចំរុះហើយ មិនមែនតែ៥០២ទេ?

ស៊ីវ៉ន៖ អត់ទេ គ្រប់ទាំងអស់មក ដល់អីចឹងអ្នកនៅហ្នឹងគ្នាគ្រប់គ្រងលែងបាន ដល់គ្រប់គ្រងអត់បានឃើញពួកខ្ញុំមក តាម៉ុក គាត់ថាទំនងគេស្ដាប់ខ្ញុំអាចគ្រប់គ្រងបាន គេឲ្យនៅមួយរយៈ ដល់ពេលបងជីដូនមួយខ្ញុំកងវរសេនាធំ អើយ! ទៅគ្រប់គ្រងស្អី មិនបាច់ទេ យកតែកូនទៅ ឲ្យខ្ញុំរត់មកទៀត ។

ដានី៖ ពីណាគេ?

ស៊ីវ៉ន៖ បងខ្ញុំមួយដែលថាវរសេនាធំនៅកំពង់សោម នៅនេសាទសមុទ្រ ។

ដានី៖ គាត់ឈ្មោះអី?

ស៊ីវ៉ន៖ ឈ្មោះ ឡូញ ។

ដានី៖ ហ្នឹងបងជីដូនមួយរបស់អ៊ំ?

ស៊ីវ៉ន៖ ចា៎!

ដានី៖ សព្វថ្ងៃគាត់នៅណា?

ស៊ីវ៉ន៖ ស្លាប់បាត់ហើយ ។

ដានី៖ អត់ដែលជួបគាត់ទេ?

ស៊ីវ៉ន៖ តាម៉ុក រកសម្លាប់តាំងមុន អត់ដែលឃើញទេ ដល់រត់មកឆ្នាំ៧៩ដដែល ជួបគាត់ខែ៨ ។

ដានី៖ ជួបខែ៨ ដែលតាម៉ុក ឲ្យធ្វើប្រធានពេទ្យនៅអមលាំង?

ស៊ីវ៉ន៖ តាម៉ុក ហ្នឹងឲ្យខ្ញុំធ្វើ ។

ដានី៖ ជួបបានប៉ុន្មានខែ?

ស៊ីវ៉ន៖ បានប្រហែល១ខែ គ្រាន់តែរៀបចំហើយខ្ញុំមើលទៅដូចសភាពការណ៍មិនស្រួល ដល់អីចឹងបងខ្ញុំថាមិនបាច់ទៅទទួលខុសត្រូវអី មកដល់សម័យនេះហើយ អង្ករ១០បាវគ្រាន់តែបបរអីចឹងធ្វើមិនបានទេ គាត់ឲ្យឡានដូវឡានឲ្យខ្ញុំថ្មី ឥឡូវជិះអាថ្មីជីកត្រីទៅតែម្ដង ឲ្យមកពោធិ៍សាត់មកតាមផ្លូវលាចវិញ ។

ដានី៖ មកតាមផ្លូវលាច?

ស៊ីវន: ចា៎! ដល់អីចឹងតាម៉ុក គាត់ឃាំងដៃអ្នកណាមកហ្នឹងអត់បានទេ ឲ្យទៅវៃជាមួយយួន ហើយ កងទ័ពអ្នកណាទៅវៃនាំគ្នារត់ខ្ទិចខ្ទី ។

ដានី: តាម៉ុក ខឹងអ៊ំអត់ដល់ពេលអ៊ំអត់ធ្វើ?

ស៊ីវន: ខឹងខ្ញុំ ព្ទុថាដេរ គិតទៅអាប្រពន្ធកម្មាភិបាលហ្នឹងអត់កើតតែម្តង ថាវារត់ៗ ថាវាទៅៗ ហ្នឹងព្ទុ សូរបងប្អូនគេនិយាយ ។ ថាម៉េចថាទៅ យើងមិនខឹងទេ ។

ដានី: ដល់ពេលអ៊ំបានឡានថ្មីមកតាមលាចហ្នឹងគាត់អត់ឲ្យមក?

ស៊ីវន: អត់ឲ្យមកទេ ឲ្យនៅហ្នឹង ដល់បងជីដូនមួយខ្ញុំថា ចាំមើលគ្នាស៊ីញ៉ូ គាត់នៅឈរតាមផ្លូវ គាត់ ជិះឡានតូច គាត់ទៅជួបអីចឹងទៅ តាម៉ុក អាឡែងទៅជួបនោះ គាត់បក់ឡានខ្ញុំឲ្យទៅលឿន ។

ដានី: ដល់ពេលអ៊ំទៅផុត?

ស៊ីវន: ផុត ។

ដានី: ផុតមកដល់ណាមក?

ស៊ីវន: មកដល់លាច ពងពង់ មកតាមព្រៃ ។

ដានី: ឡានបើករួចដែរ?

ស៊ីវន: រួច! ឡានចិនច្រើនណាស់កាលហ្នឹង អាកង់វាយ, កង់ឌុប, កងឌុបយើងមិនសូវយកទេ យក អាកង់វាយ អាកង់៦ ។

ដានី: មកដល់លាចហើយម៉េចទៀតទៅ?

ស៊ីវន: បេះតែមកតៗ មកដល់ហ្នឹងដដែល ។

ដានី: ប៉ុន្តែអ៊ំមកហ្នឹងប៉ុន្មាននាក់ដែលមកជាមួយអ៊ំ?

ស៊ីវន: អត់ច្រើនទេ មានអ្នកបើកឡាន២នាក់ ហើយក្មេងស្រីៗ២-៣នាក់ ។

ដានី: មកដល់អ៊ំស្នាក់នៅណា?

ស៊ីវន: បេះតែស្នាក់ កន្លែងត្រង់ណាក៏ស្នាក់ មើលអ្នកឈឺអីចឹងទៅ ។

ដានី: ពេលហ្នឹងដឹងដំណឹងអ៊ំប្រុស ឬក៏បានជួបគាត់?

ស៊ីវន: អត់ដឹងទេ អត់ដឹងថានៅត្រង់ណា ។

ដានី: ភ័យអត់ទេ? ភ័យព្រួយ?

ស៊ីវន: អត់ភ័យទេ រាងធម្មតា រត់យករួចខ្លួន រៀងៗខ្លួន ។

ដានី: កាលហ្នឹងយើងភ័យយួនយ៉ាងម៉េច?

ស៊ីវន: ភ័យថាយួនចូលមកកាប់សម្លាប់ ។

ដានី៖ ពីណាអ្នកនិយាយ?

ស៊ីវ៉ន៖ គេចេះតែនិយាយតៗអីចឹង យួនឃើញមិនបានទេ តែឃើញកាប់សម្លាប់អីចឹងទៅ។

ដានី៖ អ៊ីៗគាត់មានដែលនិយាយប្រាប់អីចឹងទេ? តាម៉ុក ឬអ៊ីៗផ្សេងទៀត?

ស៊ីវ៉ន៖ អត់ទេ! តៗក្មេងៗ ។

ដានី៖ ដល់អីចឹងអ៊ីចេះតែភ័យ?

ស៊ីវ៉ន៖ ដល់អីចឹងលែងជួបអ្នកដឹកនាំ រត់រៀងៗខ្លួន។

ដានី៖ អ៊ីចេញពីលាចទៅណាទៀតទៅ?

ស៊ីវ៉ន៖ ឡើងភ្នំម្តង ។

ដានី៖ ភ្នំណា?

ស៊ីវ៉ន៖ ជួរភ្នំក្រវាញ ចេះតែដើរៗទៅរាប់មួយខែ ចុះទៅដល់កោះកុង ។

ដានី៖ ពេលចេញពីលាចឡើងភ្នំក្រវាញ លើភ្នំហ្នឹងរយៈពេល១ខែ?

ស៊ីវ៉ន៖ ចាំ! ឡើងគ្រប់គ្នា អ្នកណាក៏ឡើង ចេះតែឡើងតាមគ្នា ។

ដានី៖ ហូបចុកយ៉ាងម៉េចទៅ?

ស៊ីវ៉ន៖ ចាំ?

ដានី៖ ដូចអ៊ីធ្លាប់យើងនៅធ្វើជាកម្មាភិបាលនៅភ្នំពេញ យើងធ្លាប់មានការហូបចុកអត់សូវលំបាក ដល់ពេលយើងទៅឡើងភ្នំយ៉ាងម៉េចទៅ?

ស៊ីវ៉ន៖ លំបាកតែយើងចេះតែតស៊ូតាមគេ យើងចេះតែឃើញបងប្អូនទៅ មួយថ្ងៃឡើងបានបន្តិច ដល់ល្ងាចនាំគ្នាសំរាក ព្រឹកឡើងចេញដំណើរទៀតទៅ ហើយអត់មានអីហូបទេ លែងមានអង្ករអស់ហើយ ។

ដានី៖ អីចឹងធ្វើម៉េចបានអីហូបទៅ? កូនចៅអ៊ី?

ស៊ីវ៉ន៖ កូនចៅចេះតែបេះនេះ បេះនោះដាក់ឲ្យហូបទៅ ។

ដានី៖ ១ខែ?

ស៊ីវ៉ន៖ មានអង្ករតិចតួចអត់ហ៊ានហូបខ្លួនឯង ទុកបបរឲ្យកូនតិចៗ កូនតាំងពីមានសាច់រហូតស្គមខោអាវ មានតែមួយកំប៉េ នាំគ្នារោលតាំងពីស៊ូកចុះ យូរស៊ូកលែងចុះក៏មាន ។

ដានី៖ វាធំ?

ស៊ីវ៉ន៖ មិនមែនធំទេ វារួញ ចុះក្រណាត់គេតារុងអី យើងចេះតែរោលយូរៗទៅរួញ ហើយភ្លៀងស្រុកហ្នឹង ។

ដានី៖ នៅលើភ្នំអីហ្នឹងមួយខែបានចុះទៅកោះកុង?

ស៊ីវន៖ ចុះទៅដល់កោះកុង កាលហ្នឹងគេហៅស្ពឺ ចុះទៅដីត្រង់ហ្នឹងល្អណាស់ នៅក្នុងថ្មបាំង ។

ដានី៖ ដីខ្មែរ?

ស៊ីវន៖ ដីខ្មែរស្អាតមែនទែន តាតែ គេហៅតាតែ ។

ដានី៖ ហើយម៉េចទៀតទៅអ៊ំដីវិត?

ស៊ីវន៖ ទៅនៅហ្នឹងបានមួយរយៈជួបបងជីដូនមួយខ្ញុំទៀត គេបាញ់បានដឹរីតាំងពីលើភ្នំទៅ នៅបានមួយរយៈថា តាម៉ុក ហៅគាត់ទៅ ។ ទៅគាត់សន្យាជាមួយខ្ញុំ គាត់ថាបើបាត់គាត់មួយខែ ត្រូវម្ចាស់ការចុះ ទៅបាត់ចាំមើលបាត់មួយខែ ដល់សួររកទៅគេថាមិនដឹងគាត់ទៅណា គេថាតាម៉ុក យកវ៉ៃចោល ។

ដានី៖ តាម៉ុក យកទៅវ៉ៃចោល?

ស៊ីវន៖ ហ្នឹងហើយយកទៅវ៉ៃចោល ចប់គ្នាត្រឹមហ្នឹង ។

ដានី៖ តែប្រពន្ធកូនគាត់នៅ?

ស៊ីវន៖ ប្រពន្ធកូនចេះតែនៅ ក្រោយមកគេយកប្រពន្ធកូនវ៉ៃចោលអស់ទៀត ។

ដានី៖ ពេលនៅលើភ្នំហើយមានអ្នកវ៉ៃចោលទៀត?

ស៊ីវន៖ លើភ្នំរត់ហើយហ្នឹង វ៉ៃចោលទាល់អស់រលីងមួយពូជហ្នឹងគ្មានសល់ទេ នៅសល់កូនមួយផ្ញើរយាយនៅស្រុក ។

ដានី៖ អ៊ំដល់ពេលនៅកោះកុងហ្នឹងយ៉ាងម៉េចទៀតទៅ?

ស៊ីវន៖ នៅកោះកុងហ្នឹង ខ្ញុំមិនសូវហ៊ាននៅទេ រត់មកទៀត ។

ដានី៖ រត់ទៅណាវិញ?

ស៊ីវន៖ ខ្លាចគេ ព្រោះល្បីថា តាម៉េតក្បត់ៗ ខ្ញុំមិនហ៊ាននៅខ្លាចគេវ៉ៃចោលទៀត ចេះតែដើរទៅធ្លាក់កាលហ្នឹងបានដឹរីដិះ ធ្លាក់ទៅជាំ រលាក់កងជើង ទៅហ្នឹងទៀត ។

ដានី៖ រលាក់កងជើង កំពង់ស្ពឺ ឱរ៉ាល់វិញ?

ស៊ីវន៖ ហ្នឹងទៅជួបតាប៉ាល់ គាត់ប្រធានភូមិភាគដែរ ដល់ទៅជួបគាត់ ។ គាត់ថា «ក្មួយអើយ! ឈប់រត់ទៀតទៅ រត់អីចឹងឆាប់ក្ងួយ» ។

ដានី៖ គាត់ស្គាល់អ៊ំតាំងពីអន្លូល?

ស៊ីវន៖ គាត់ស្គាល់តាំងពីក្មេងមក ។

ដានី៖ តាប៉ាល់ គាត់ប្រធានភូមិភាគណា?

ស៊ីវន៖ គាត់នៅបស៊ីម ។

ដានី៖ ជាមួយតា?

ស៊ីវន៖ តាស៊ី, តាជូ ជេត ។ គាត់ឲ្យអង្គរឲ្យអីត្រឹមហ្នឹង បានដឹងដំណឹងថាគាត់នៅបាត់ដំបងហ្នឹងគេឲ្យកម្លាំងទៅយកខ្ញុំមក ។

ដានី៖ ឆ្នាំណា ខែណា បានដឹងដំណឹងថាអ៊ំទៅដល់រលាក់កងជើងវិញ?

ស៊ីវន៖ ដូចជាខែ១១មិនដឹង ខែ១០មិនដឹង ។

ដានី៖ ខែ១១ ឆ្នាំ?

ស៊ីវន៖ ឆ្នាំ៧៩ រត់រីវក់ៗពេញតែហ្នឹង ។

ដានី៖ ខែ៨ឡើងភ្នំ ខែ៩នៅកោះកុង ។

ស៊ីវន៖ ខែ១០គេទៅយក ។

ដានី៖ ខែ១០គេទៅយកជិះដីរីមកនៅរលាក់កងជើងវិញ?

ស៊ីវន៖ ចា៎!

ដានី៖ ខែ១១ ដឹងអ៊ំប្រុសនៅបាត់ដំបង គាត់ដឹងដំណឹងថាអ៊ំនៅហ្នុង គេទៅយកមក?

ស៊ីវន៖ ព្រោះអ្នកដែលនៅជាប់ខ្ញុំភាគច្រើនគ្រួសារកងទ័ព គាត់ឲ្យគេទៅយក ។

ដានី៖ តាប៉ាល់ គាត់ស្លាប់នៅណាទៅ?

ស៊ីវន៖ តាប៉ាល់ ស្លាប់នៅវ-៨ ហ្នឹង ។

ដានី៖ នៅណា?

ស៊ីវន៖ នៅវ-៨ ព្រំដែនថៃ ។

ដានី៖ វ-៨ ហ្នឹងនៅក្នុងខេត្តណា?

ស៊ីវន៖ វ-៨ គេហៅកោះកុង ។

ដានី៖ ស្លាប់ឆ្នាំណា?

ស៊ីវន៖ ខ្ញុំភ្លេចឆ្នាំ ។

ដានី៖ គេទៅយកអ៊ំមកជួបអ៊ំប្រុសនៅណា?

ស៊ីវន៖ មកជួបគាត់នៅគេហៅ រូង ក្រហត ត្រង់ណាទេ ។

ដានី៖ នៅក្រហត?

ស៊ីវន៖ អន្ទង់មៀន ត្រង់ណាមិនដឹងមិនសូវស្គាល់ ។

ដានី៖ ទៅនៅហ្នឹងបានយូរទេ?

ស៊ីវ៉ន: អត់ទេ ជួបគ្នាតែបន្តិចបែកគ្នាទៀត គាត់ត្រូវមកប្រជុំណានេះ គេយកខ្ញុំទៅផ្ញើរ ។

ដានី: គេយកអ៊ំទៅផ្ញើរណាវិញទៀត?

ស៊ីវ៉ន: ទៅផ្ញើរនៅជាមួយ តាសារុន វិញ ។

ដានី: តាសារុន គណៈតំបន់ដែលអ៊ំនៅជាមួយគាត់ចាស់?

ស៊ីវ៉ន: ចា៎! យកទៅផ្ញើរហ្នឹងបាន ។

ដានី: ផ្ញើរហ្នឹងនៅណា?

ស៊ីវ៉ន: គេហៅថាក្រពើពីរ ។

ដានី: ក្រពើពីរតាមកំពង់ល្ពៅ តាមស្ទឹងតូច ។

ស៊ីវ៉ន: ខ្ញុំសង្ស័យបែបហ្នឹងតែកាលហ្នឹងសុទ្ធតែព្រៃ ។

ដានី: វាលចំបាំង ក្រពើពីរ ។

ស៊ីវ៉ន: ស្ទឹងហ្នឹងធំណាស់ ។

ដានី: ក្នុងស្រុកសំឡូតដែរ?

ស៊ីវ៉ន: ចា៎!

ដានី: អ៊ំគាត់ទៅប្រជុំនៅណាទៅ?

ស៊ីវ៉ន: គាត់ថាមកប្រជុំនៅហ្នឹង មកជួបជាមួយ តានួន ជា ។

ដានី: មកប្រជុំនៅសំឡូតហ្នឹង?

ស៊ីវ៉ន: ចា៎! ស្ទឹងក្រញូង តានួន ជា កាលហ្នឹងនៅស្ទឹងក្រញូង តាសាញហ្នឹងហើយ ។

ដានី: ម្ដុំតាសាញ ស្ទឹងក្រញូង! មកជួបប្រជុំនៅហ្នឹង ហើយអ៊ំនៅក្រពើពីរនៅជាមួយ តាសារុន?

ស៊ីវ៉ន: គាត់ចេះតែដើរតៗមក ។

ដានី: ដើរមកដល់ណាទៅ?

ស៊ីវ៉ន: ដើរមកជួបគាត់នៅស៊ុង ហើយបានទៅផ្ញើកន្ទែងស្នាក់នៅ៤០០ហ្នឹង ។

ដានី: នៅភ្នំ៤០០ហ្នឹង?

ស៊ីវ៉ន: នៅភ្នំ៤០០ ជើងភ្នំ ។

ដានី: នៅព្រំដែនតែម្ដង?

ស៊ីវ៉ន: ព្រំដែនតែម្ដង ដល់ខាងហ្នឹងវៃទៀតមកឆ្លងទៅដីថៃ ។

ដានី: ទៅនៅដីថៃ?

ស៊ីវ៉ន: ចា៎! ដីថៃ ។

ដានី: គេហៅជំរំអី?

ស៊ីវន: ហៅម៉ាមួង គេហៅឆ្កែកាច ។

ដានី: នៅថៃបានយូរទេ?

ស៊ីវន: នៅយូរ ។

ដានី: ប្រហែលប៉ុន្មានឆ្នាំបានត្រឡប់មកវិញ?

ស៊ីវន: ប្រហែល២-៣ឆ្នាំ ។

ដានី: នៅបាន២-៣ឆ្នាំបានត្រឡប់មកវិញ?

ស៊ីវន: ចា៎!

ដានី: កាលហ្នឹងអ៊ំប្រុសនៅព្រំដែន នៅ៤០០ហ្នឹងគាត់ទទួលខាងអីវិញ?

ស៊ីវន: គាត់ប្រធានសមរភូមិប្រក៤០០ ។

ដានី: គាត់ប្រធានសមរភូមិប្រក៤០០?

ស៊ីវន: ប្រក៤០៤ ។

ដានី: ប្រធានសមរភូមិ?

ស៊ីវន: ប្រធានហើយគាត់ ។

ដានី: ប្រធានសមរភូមិប្រក៤០០ ហើយ៤០៤ទៀត?

ស៊ីវន: ហ្នឹង ៤០៤ គេដាក់លេខអីចឹង សមរភូមិសំឡូតហ្នឹងដាក់អីចឹងក៏បាន ។

ដានី: ប្រក៤០០អានេះ ចុះ៤០៤នៅណា?

ស៊ីវន: ទាំងអស់ហ្នឹងគេសរុប៤០៤ ។

ដានី: ៤០៤?

ស៊ីវន: ដល់កោះកុង៥០៥ ។

ដានី: កោះកុង៥០៥ ពីណាគេនៅកោះកុង?

ស៊ីវន: ក្រោយមកតាមុត ។

ដានី: តាមុត កោះកុង(៥០៥) ។ អីចឹងសមរភូមិមាន២ មានប្រកកោះកុង ។

ស៊ីវន: ក្រោយមករំលាយចូលគ្នាទៅជា៩០៩ ។

ដានី: ឆ្នាំណារំលាយចូលគ្នា?

ស៊ីវន: ដូចជា៩៤ ។

ដានី: ឆ្នាំ៩៤បានរំលាយ កាលពីមុនអត់ទាន់រំលាយទេ?

ស៊ីវ៉ន៖ អត់ទាន់ទេ! ៩៨ហ្នឹងតាម៉ុក រត់ពីអន្លង់វែង ។

ដានី៖ ជិតបែកហើយហ្នឹង៩៨?

ស៊ីវ៉ន៖ ជិតត្រូវគ្នា ។ កាលហ្នឹងវៀតណាមវ៉ៃខ្លាំងណាស់ វ៉ៃឡើងពួកខ្ញុំត្រៀមរុញផ្ទះចោល ផ្ទះខ្ញុំ ។

ដានី៖ វៀតណាមវ៉ៃខ្លាំង៨៤-៨៥?

ស៊ីវ៉ន៖ ហ្នឹងហើយ ៨៤-៨៥វ៉ៃរហូត ខ្លាំងរហូត ។

ដានី៖ អ៊ំនៅច្រក៤០៤ ហើយរត់ទៅនៅថៃហ្នឹងឆ្នាំណា?

ស៊ីវ៉ន៖ រត់ទៅថៃ៨៤-៨៥-៨៦ ។ ៩០បានត្រឡប់មកវិញ ។

ដានី៖ ៩០ត្រឡប់មកវិញគាត់បញ្ចូលគ្នានៅ?

ស៊ីវ៉ន៖ ហ្នឹងអត់ទាន់បញ្ចូលទេ ។

ដានី៖ នៅ៤០៤ និង៥០៥?

ស៊ីវ៉ន៖ អត់ទាន់ចូលគ្នា ។

ដានី៖ អ៊ំដឹងថានៅច្រក៤០៤មានប៉ុន្មានកងពល?

ស៊ីវ៉ន៖ ប៉ុន្មានទេ ខ្ញុំអត់ច្បាស់ ព្រោះកងពលគាត់រៀបចំអត់បានសួរគេផង តែធ្លាប់ឃើញអ្នកមកប្រជុំ
ដូចជា ២-៣នាក់ ។

ដានី៖ ពីណាគេ?

ស៊ីវ៉ន៖ ទី១តាគង់ (ញ៉ែម គង់) ។

ដានី៖ ញ៉ែម គង់ គាត់នៅកំរៀងឬមិនមែនទេ?

ស៊ីវ៉ន៖ អត់ទេ នៅនេះ ។ ហ្នឹង សុក គង់ ។

ដានី៖ អូ! ញ៉ែម គង់ ។

ស៊ីវ៉ន៖ ឥឡូវផ្កាយពីរដែរហ្នឹង ។

ដានី៖ ពីណាទៀត?

ស៊ីវ៉ន៖ តាអង ស្លាប់បាត់ហើយ ។

ដានី៖ ពីណាទៀត?

ស៊ីវ៉ន៖ ឃើញតែប៉ុណ្ណឹង ។

ដានី៖ តែពីរកងពលហ្នឹងទេ?

ស៊ីវ៉ន៖ ៣កាលហ្នុង ខ្ញុំស្តាប់មិនសូវបានទេ ។ ឈ្មោះដាត មួយទៀត សុទ្ធតែមេកងពល ៣កងពល ។
អនុៗលែងស្គាល់ ភ្លេចអស់ ។

ដានី៖ អឺចឹងច្រក៤០៤យើងនៅតែម្តុំច្រកហ្នឹង កាន់ពីត្រឹមណាដល់ត្រឹមណា?

ស៊ីវន៖ ៤០៤, ព្រែកបី, សានចៅ។

ដានី៖ ៤០៤, ព្រែកបី?

ស៊ីវន៖ សានចៅ, ៤០៤គេហៅសានចៅ។ សានចៅ ហ្នឹងចុះទៅថៃបាន។

ដានី៖ សានចៅហ្នឹងនៅក្នុង៤០៤ដែរ?

ស៊ីវន៖ នៅក្នុងសមរភូមិសំឡូត។

ដានី៖ ហើយណាទៀត?

ស៊ីវន៖ លើភ្នំ ទៅគេហៅព្រែកបីមួយទៀត។

ដានី៖ ព្រែកបីនៅណា?

ស៊ីវន៖ ព្រែកបីទៅជាប់ប៉ៃលិន។

ដានី៖ ទៅខាងនេះវិញ?

ស៊ីវន៖ ទៅខាងនេះវិញ ហ្នឹងសុទ្ធតែចុះទៅថៃបាន។

ដានី៖ សានចៅ ហើយនិងព្រែកបី តែ២ហ្នឹងទេ?

ស៊ីវន៖ ចាំ!

ដានី៖ ២ហ្នឹងមានពាក់ងពល?

ស៊ីវន៖ ច្រក៣ហ្នឹងមាន៤០០។ ភ្នំហ្នឹងកំពស់៤០០ អឺចឹងគេហៅ៤០០។

ដានី៖ ៤០៤មាន៣ច្រក។

ស៊ីវន៖ ហ្នឹងហើយ៣ច្រក។

ដានី៖ មានច្រក?

ស៊ីវន៖ សានចៅ ហើយនិងព្រែកបី។

ដានី៖ មុនដំបូងគេ៤០០, បន្ទាប់មកទៀត សានចៅ, ទី៣មកព្រែកបី។

ស៊ីវន៖ ជាប់ថៃទាំងអស់គ្នា។

ដានី៖ អ៊ំប្រុសគាត់គណៈសមរភូមិគ្រប់គ្រង៣ច្រកហ្នឹង?

ស៊ីវន៖ ចាំ! មានគាត់, មានតាទិត។

ដានី៖ មានគាត់, មានតាទិត ហើយពីណាទៀត?

ស៊ីវន៖ ម្នាក់ទៀតពីណាទេ អត់ច្បាស់ម្នាក់ទៀត។

ដានី៖ ហើយតាទិត គាត់មកនេះតាំងពីអង្កាល់?

ស៊ីវន: នៅតាំងពីយូរ ។

ដានី: នៅតាំងពី?

ស៊ីវន: នៅតាំងពីមុន ដល់ត្រូវគ្នាគេដកតាទិត ទៅនៅភ្នំពេញ ។

ដានី: តែគាត់មក៧៩ គាត់នៅនេះ?

ស៊ីវន: នៅហ្នឹង នៅមុនខ្ញុំទៀត ។

ដានី: បានន័យថាគាត់នៅហ្នឹងតាំងពី?

ស៊ីវន: ព្រោះគាត់ធ្វើការនៅខេត្តបាត់ដំបង ស្រុកសំឡូត ។

ដានី: គាត់គ្រប់គ្រងស្រុកសំឡូតហ្នឹងដែរ កាលពីជំនាន់៣ឆ្នាំ?

ស៊ីវន: ជំនាន់ខ្មែរក្រហម ។

ដានី: ដល់យួនចូលមកក៏គាត់នៅហ្នឹង?

ស៊ីវន: គាត់ម្ចាស់ការនៅហ្នឹង ។

ដានី: គាត់ម្ចាស់ការនៅហ្នឹងតែប្រែក៤០៤ហ្នឹង អាំប្រុសគាត់ធ្វើប្រធាន ហើយតាទិត អនុ?

ស៊ីវន: គាត់ធ្វើប្រធាន ហើយតាទិត អនុ ។

ដានី: សមាជិក?

ស៊ីវន: មិនដឹងពីណា ដូចអត់ស្គាល់ ដឹងតែ២នាក់ហ្នឹងច្បាស់ ។

ដានី: ហើយពីសំឡូតទៅខាងនោះ? តទៅខាងនោះ?

ស៊ីវន: មានតាមុត មិនដឹងពីណាទៀតខ្ញុំអត់ច្បាស់ ។

ដានី: តពីសំឡូតទៅខាងកោះកុង គឺតាមុត វិញ!

ស៊ីវន: អ៊ឺ!

ដានី: ដល់ពេលអាំប្រុសពីសំឡូតទៅខាងប៉ៃលិន?

ស៊ីវន: ចាំ!

ដានី: ដាច់គ្នា?

ស៊ីវន: បែកគ្នា តែគេប្រជុំជួរគ្នាយើងអត់ដឹងទេ ។

ដានី: តែដូចអាំប្រុស, តាមុត អីកាលពីមុនដែលថាផ្ដាច់ខ្លួនចូលរដ្ឋាភិបាល កាលមុនយើងនៅត្រូវ គ្នា ល្អូកល្អើនអីធម្មតា?

ស៊ីវន: ត្រូវគ្នាធម្មតា ធ្វើការប្រជុំ ដល់ផ្ដាច់ខ្លួន តាមុត ហ្នឹងបបួលគាត់បះបោរ ទៅអីចេះ គាត់ថា គាត់អត់ធ្វើអីចឹងទេ យើងនិយាយម៉េចយើងធ្វើអីចឹងទេ យើងនិយាយថាត្រូវគ្នាជាមួយរដ្ឋា

ភិបាល យើងត្រូវទៅខាងរដ្ឋាភិបាល មានការអីយើងរាយការណ៍ឲ្យរដ្ឋាភិបាល ។ តាមុត គេសុខចិត្តទៅជាមួយ អៀង ដាន ។

ដានី: អៀង ដាន គាត់នៅខាងវាលវែង?

ស៊ីវន: ទៅខាងណុះ វៃជាមួយតាម៉េត វៃជាមួយរដ្ឋាភិបាល ។ តាម៉េត គំណាងរដ្ឋាភិបាលមកវៃ

ដានី: ខាងតាមុត មានប៉ុន្មានកងពល? ពកងពលដែរ?

ស៊ីវន: មិនដឹងប៉ុន្មានទេអត់ច្បាស់ ។

ដានី: មានតាមុត ហើយពីណាអនុគាត់?

ស៊ីវន: អៀង ដាន ហ្នឹង ដឹងតែ អៀង ដាន ហើយនិងតាមុត ហ្នឹង ។ ២នាក់ហ្នឹងគេនាំគ្នាបះបោរ ។

ដានី: ដល់ពេលអ៊ំមកនេះបានកូនថែម២ទៀត?

ស៊ីវន: មានតាំងពីយូរ ។

ដានី: ចុះអ៊ំថាមកពីភ្នំពេញមានតែ២?

ស៊ីវន: មាន២ មកនៅក្នុងព្រៃកើតបានមួយទៀត កើត៨២, ៨៤, ៨៩ ។

ដានី: ៨៩មួយទៀត?

ស៊ីវន: មួយនៅដីថៃ ។

ដានី: មួយកើតនៅក្នុងទឹកដីថៃ?

ស៊ីវន: ដីថៃ២ ចល័តលិច-កើត។ ហ្នឹងគ្រាន់ជួបគ្នាអីខ្លះ ។

ដានី: អ៊ំមកដល់នៅនេះហើយយើងស្រួល លែងលំបាក លែងរត់លូន?

ស៊ីវន: លែងអីហើយ ។

ដានី: ទោះជាទៅដីថៃត្រឡប់មកវិញក៏អត់អីដែរ?

ស៊ីវន: អត់អីដែរ មានឡានដិះ ចិនឲ្យមកទៀត ។

ដានី: អ៊ំប្រុសមានធ្លាប់ទៅចិនទៀតទេ?

ស៊ីវន: អ៊ំប្រុសមិនដឹងម៉េចខ្ញុំអត់ច្បាស់ តែធ្លាប់បាត់ ។

អ្នកជិតខាង: អ៊ំមានរូបគាត់ រូបថតចាស់។?

ស៊ីវន: រូបថតគាត់អត់ទេ មានតែរូបថតបុណ្យម៉ង ។

ដានី: អ៊ំប្រុសគាត់ឈឺអីមុនគាត់ខូច?

ស៊ីវន: មុនគាត់ឈឺហ្នឹង គាត់ចេះតែឈឺចុះស្គម២ឆ្នាំ ខ្ញុំឃើញប្លែក ខ្ញុំថាទឹកនោមផ្អែម ដល់ដំណាក់ការចុះ ។

ដានី: ទឹកនោមផ្អែម គាត់អត់ដែលទៅពេទ្យទេ?

ស៊ីវន: ពេទ្យគឺមួយអាទិត្យទៅមើលយកថ្នាំមកលេប លេបអស់ថ្នាំទៅយកមកទៀត តែគាត់តម អត់បាន ទី១បារីតមអត់បានទេ ទី២ស្រាបៀរហ្នឹងតមមិនបានទេ២មុខហ្នឹង ហើយពេទ្យគេប្រាប់កូនខ្ញុំដែលវាជូនទៅហ្នឹងថា លោកពូបើក្មួយឯងណែនាំឲ្យគាត់តមមិនបាន ឈឺលើកក្រោយអត់មានកន្លែងសង្គ្រោះទេ ពេទ្យប្រាប់ច្បាស់តែម្តង ។ កូនហ្នឹងប្រាប់ខ្ញុំយើងចេះតែ យើងខំតាមដានតាមមើលគាត់រឿងបារី លួចជក់រហូត លួចតែម្តង ។

ដានី: គាត់អត់តម?

ស៊ីវន: អត់ទេ ។

ដានី: តែគាត់ធ្វើអីធ្វើហ្នឹងហើយ?

ស៊ីវន: ធ្វើអីធ្វើហ្នឹងហើយ ចង់តាមខ្ញុំមកនេះ ដឹងម៉េចទេ គាត់ចង់ជក់បារី ព្រោះវាសេរីស្រួលនៅផ្ទះនោះពិបាកព្រោះរបងជិត ឲ្យតែជក់ គេអត់ឲ្យកាន់លុយទេខ្ញុំប្រាប់កូន អត់ឲ្យគាត់កាន់លុយ បើកប្រាក់ខែមកឲ្យផ្ញើរអ្នកនេះ អ្នកនោះ ដល់អីចឹងគាត់លួចតែជឿបារីគេ មកនេះក៏អីចឹងដែរ ។

ដានី: គាត់និយាយថាទ្រាំមិនបាន?

ស៊ីវន: ទ្រាំមិនបាន ដល់ពេទ្យគេនិយាយអីចឹង យើងមើលទៅឃើញអីចឹង ថ្ងៃមួយកូនគេមករយៈស្គមហ្នឹង២ឆ្នាំ ហើយអត់អីទេ តាមដានគាត់ ថាឲ្យ ខ្វះខឹង ខ្វះអត់ជក់តិច ដល់បាត់ខឹងគាត់ជក់ទៀត អត់ទេ និយាយអត់ស្តាប់គ្នាទេ ដល់ហើយកូនគេមកថាម៉ែ ពុកដូចអត់សូវស្រួលខ្ញុំនៅនេះដាំពោត ដល់អីចឹងទៅទាំងថ្ងៃ ពីថ្ងៃអត់សូវអី ដល់ល្ងាចចាប់ផ្តើមស្ទុះទឹកនោម ចុកតែម្តងឡើងស្មេកមុខ យកទៅពេទ្យ ទៅដល់ពេទ្យគេបូមគាត់ធូរ ដល់ធូរខ្ញុំថាម៉េចគិតទៅផ្ទះវិញ គាត់ថាដេកមួយយប់ទៅឲ្យពេទ្យគេបានលុយ គេបូមអីចឹងអត់អស់លុយច្រើន គាត់ចង់ឲ្យគេបានលុយច្រើន ដេកមួយយប់ គាត់ថានៅមួយយប់ទៀត គេបញ្ចូលឈាម គេថាគាត់ខ្វះឈាម មកពីស្ទុះទឹកនោម គេចេះតែមើល យើងចេះតែឲ្យគេមើលបាន៣ថ្ងៃ ខ្ញុំទៅជួបអ៊ំសេង១គាត់ថា កុំទុកគាត់ហ្នឹងអី យកគាត់ទៅពេទ្យទាហាន ដល់អីចឹងមកពេទ្យព-២ ពេទ្យទាហាន ។

ដានី: ពេទ្យព-២ នៅណា?

ស៊ីវនៈ នៅបាត់ដំបង ។

ដានីៈ ពេទ្យយុទ្ធភូមិភាគ៥ហ្នឹង?

ស៊ីវនៈ ហ្នឹងហើយ គេហៅពេទ្យព-២ ភូមិភាគ៥ យកមកដាក់ហ្នឹងថ្ងៃទី១ពេទ្យគេមើលទៅវាធូច ធូរជាងមុន, ទី២ក៏វាធូរ, ទី៣-៤-៥ស្រាប់វាសន្លប់វង្វេងអត់ដឹងខ្លួន ហើយទឹកនោមហ្នឹង សុងរហូត ដាក់ទុយោរហូត ដល់វាងអត់ដឹងខ្លួន ខ្ញុំមើលទឹកនោមក៏វាងប្រែពណ៌ដូចឈាម អីចឹង គាត់ចាប់សន្លប់ ដល់សន្លប់ទៅចេះតែស្រែករវើរវាយអត់ដឹងអីទេ អីចឹងពេទ្យព-២ គេ សំរេចបញ្ជូនទៅភ្នំពេញ ពេទ្យកេតុមាលា ទៅដេកកន្លែងពេទ្យមិត្តភាពខ្មែរ-ចិន ដេកពេទ្យហ្នឹង ទៅដល់គេថតទាំងអស់ ស្កេនក្បាលទាំងអស់ ស្បែកឡើងគេលាងឈាម គេថាទឹកនោមផ្អែម គេ លាងឈាម លាងគេធ្វើកិច្ចសន្យាជាមួយយើងគេថាមិនទៀងទេ មាន២ បើជោគជ័យអាហ្នឹង វាអត់អី បើគ្រោះថ្នាក់មើលមិនឃើញ ។ យើងនឹកឃើញថាទៅ ដល់ហើយសំរេចឲ្យគេលាង ។ លាងថ្ងៃទី១ លាងថ្ងៃទី២ ខ្ញុំមើលទៅអត់ឃើញអន់ ក៏សំរេចសុំគេចង់មកថៃវិញ ការពិតគេចង់ បញ្ជូនយើងទៅវៀតណាម ពេទ្យហ្នឹងថា អ៊ឹងង គេបញ្ជូនទៅវៀតណាមម៉េចមិនទៅ ខ្ញុំថាអត់ ទេ ខ្ញុំសុំទៅថៃ គេក៏ប្រជុំគ្នា ឯកភាពឲ្យខ្ញុំមកថៃ ជួលឡានពេទ្យដឹកមកវិញ ។ មកដល់កូនធ្វើ សង្ស្រទានឲ្យគាត់នឹកឃើញអស់សង្ឃឹម ធ្វើសង្ស្រទានហើយ បងសេង ថា អត់កើតទេ យកបង ទៅថៃ បានទៅបាងកក ។ ទៅបាងកកបាន១០ថ្ងៃ គិតទៅសន្លប់១០ថ្ងៃ ។

ដានីៈ អីចឹងចេញពីព-២ទៅគាត់សន្លប់?

ស៊ីវនៈ ទៅនោះសន្លប់ ទៅដល់ភ្នំពេញក៏សន្លប់ ។

ដានីៈ លែងដឹងអី?

ស៊ីវនៈ លែងដឹងហើយ ត្រឡប់មកវិញនៅផ្ទះក៏លែងដឹងដែរ ដល់អីចឹងគាត់សំរេចយកទៅថៃ ម៉ោយប់ ទៅដល់ម៉ោង៣រសៀល ។

ដានីៈ ជិះអីទៅ?

ស៊ីវនៈ ឡាន ទៅពីនេះឡានសារ៉ែនគេជូនទៅដល់ប៉ោយប៉ែត ហើយទៅដល់អារញ្ញមានឡានពេទ្យ ទាហានគេដូរមួយទៀត បានទៅដល់បាងកកម៉ោង៣ ចេញពីអារញ្ញម៉ោង១២ ទៅដល់គេ មើលមួយយប់ហ្នឹង ស្បែកឡើងដឹងខ្លួន និយាយស្គាល់យើងច្បាស់លាស់ នឹកឃើញវាងអរដែរ តែគិតថាជំងឺបើវិវត្តន៍ទៅធ្ងន់វាមិនងាយជាទេ ព្រោះតំរងនោមខ្ញុំឃើញឈាមតែម្តងចេញមក ។ បាន៥ថ្ងៃគេចេញពីកន្លែងសង្គ្រោះបូលកន្លែងព្យាបាលធម្មតា គេថាព្យាបាលសាកល្បងមិនមែន ធម្មតាទេ ថ្ងៃសង្គ្រោះបូលជាន់ទី១៧ ដល់មកព្យាបាលធម្មតាជាន់ទី១៨ឡើងជាន់ ។ ដល់ហើយ

មើលចុះ មើលឡើង ពេទ្យគេនិយាយថា អាចមកស្រុកខ្មែរវិញបាន យើងគិតថាជំងឺនេះ ខ្ញុំ ចេះតែគិតទេ ព្រោះយើងធ្លាប់ចេះតិចតួច មិនដាទេ ខ្ញុំរាយការណ៍ឲ្យបងសេង១ គាត់ថា បង យកមកវិញក៏យកមក ។

ដានី៖ តែពេទ្យថៃគេមានប្រាប់ថាគាត់ជា មិនជាអីទេ?

ស៊ីវន៖ ពេទ្យអត់និយាយថាមិនជាអីទេ គ្រាន់តែនិយាយថា ជំងឺនេះទាមទារពេលវេលាវែង គេថា អីចឹង តែមិនដាទេ ខ្ញុំដឹងអីចឹង ដល់ពេលត្រឡប់មកវិញជិះឡានអត់មានអីទេនិយាយបានខ្លះ គាត់ថាអត់ឲ្យដាក់ផ្ទះទេ ដាក់ពេទ្យព-២ទៀតហើយ ពេទ្យភូមិភាគ៥ ។

ដានី៖ គាត់ដឹងខ្លួនគាត់ថាអត់សូវស្រួលក្នុងខ្លួន?

ស៊ីវន៖ គាត់ថាគាត់អត់ឈឺអី មានក្មេង១នៅជាមួយគាត់ មកពីភ្នំពេញមកលេងគាត់ ពុថាគាត់មកពី ថៃមកលេងគាត់ ។ ពូ១ឯងឈឺអីរាល់ថ្ងៃ? ដូចអត់ឈឺអីទេគ្នា ចេះតែពោលថាអត់ ឈឺអី ប៉ុន្តែហូបអីអត់មានកើតទេ ១០-១៥ថ្ងៃ បញ្ចូលអាហារតាមទុយយោ ថ្នាំបាញ់តាមទុយយោ ទាំងអស់ ។

ដានី៖ គាត់ប្រាប់ថាចេញមកពីថៃវិញ អត់ឲ្យមកផ្ទះទេ ទៅដេកពេទ្យ?

ស៊ីវន៖ បងសេង អត់ឲ្យមកទេ ឲ្យទៅសំរាកនៅពេទ្យទៀត ដើម្បីបន្តដាក់អុកស៊ីសែន ហើយឲ្យពេទ្យ គេមើល ។ ថ្ងៃមុនដែលគាត់ស្លាប់មួយថ្ងៃនិយាយច្បាស់ថែស ច្បាស់ហ្នឹងគឺសួរនាំទាំងអស់ សួរ តាំងពីកូនសួរតាំងពីចៅ អាណាគាត់ស្គាល់នៅជាមួយតាំងពីតូច ផ្តាំឲ្យមកលេង គ្រាន់តែផ្តាំ អីចេះ ទាំងអស់គ្នានាំគ្នានៅខំរកស៊ីឲ្យមានកុំឲ្យក្រ តែក្រវេទនាណាស់ក្មួយ តែប៉ុណ្ណឹង ។ មួយ យប់ហ្នឹងឃើញគាត់បែកញើសប្លែក ខ្ញុំនៅមើលរហូត ដូចប្លែកអត់មាត់ប្រាប់កូន ខ្លាចកូនវា ភ័យ ដល់ព្រឹកឡើងគាត់រាងប្រែចេះប្រែតាំងពីម៉ោង៩-១០ ។ ដល់១១ពុក្អកតែពីរដងលែង រើរ ក្អកតែពីរដងផុតតែម្តង ។

អ្នកជិតខាង៖ គិតទៅថ្នាំថៃពូកែណាស់?

ស៊ីវន៖ គេសុទ្ធតែម៉ាស៊ីនចូលដល់ ម៉ាស៊ីនគេនៅអីចឹងទាំងអស់ ម៉ាបន្ទប់ហ្នឹងដាក់តែគាត់មួយ ។

ដានី៖ អ៊ំពេលហ្នឹង ចាំមើលគាត់ស្លាប់ថ្ងៃណាដែរ?

ស៊ីវន៖ គាត់ស្លាប់ថ្ងៃទី១៨ ម៉ោង១១, ១៥នាទី ។

ដានី៖ ម៉ោង១១ម៉ោងយប់?

ស៊ីវន៖ ម៉ោង១១ថ្ងៃត្រង់ ។

ដានី៖ ថ្ងៃ១៨ ខែមិថុនា ឆ្នាំ២០១៣ ។

ស៊ីវន: ត្រូវហើយមរណៈភាព ដាក់៦៧ឆ្នាំ ។

ដានី: ចាំមើលគាត់ទៅសំរាននពេទ្យ មុនដំបូងពេទ្យនៅសំឡូតយើងទេ?

ស៊ីវន: អត់ទេ ។

ដានី: ពេទ្យណាគាត់ឈឺដំបូង?

ស៊ីវន: ពេទ្យសុវណ្ណ ។

ដានី: ពេទ្យសុវណ្ណនៅណា?

ស៊ីវន: នៅបាត់ដំបង ផ្ទះខ្ញុំនៅហ្នឹង ។

ដានី: ឥឡូវផ្ទះអ៊ំនៅណាខ្លះ?

ស៊ីវន: មានតែនៅបាត់ដំបងមួយ ហីចំការ បេះតែធ្វើរោងមួយៗ ។

ដានី: នៅបាត់ដំបងនៅម្តុំណាផ្ទះអ៊ំ?

ស៊ីវន: នៅជិតផ្ទះបងសេង, ជាប់ផ្ទះតាប៉ុល សារ៉ាន់ ។ ឡើងផ្កាយពីរឃើញថត មិនដឹងថតស្នានណា ខ្ញុំមិនដឹងផង ស្រាប់តែឃើញគេយក ។

ដានី: ផ្ទះអ៊ំអត់មាននៅស្ពោទេ?

ស៊ីវន: អត់ទេ អត់ធ្វើផងខ្ញុំ ។

ដានី: អត់ទេ មានតែនៅបាត់ដំបង ហើយនិងនៅកញ្ចាំង?

ស៊ីវន: ហ្នឹងចំការ ហ្នឹងកន្លែងផ្ទះចាស់ តែធ្វើរោងតូចៗ ។

ដានី: សព្វថ្ងៃអ៊ំមកនៅកញ្ចាំងនេះវិញ?

ស៊ីវន: អត់ទេ! នៅអត់ទៀង ទៅមកៗ ។

ដានី: តែអាស្រ័យដ្ឋានអ៊ំសព្វថ្ងៃនៅភូមិអី ឃុំអីដែរ?

ស៊ីវន: អាស្រ័យដ្ឋាននៅនេះ?

ដានី: អាស្រ័យដ្ឋានអ៊ំរស់នៅណា?

ស៊ីវន: នៅភូមិរំចេក៤ ។

ដានី: ឃុំអីហ្នឹង?

ស៊ីវន: មុនដំបូងក្រុមទី១ ភូមិរំចេក៤ ឃុំរតនៈ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

ដានី: បើនៅនេះ?

ស៊ីវន: មកនៅនេះ នៅភូមិកញ្ចាំង ឃុំស៊ុង ស្រុកសំឡូត ។

ដានី: តែពីរហ្នឹងទេ?

ស៊ីវន: ដល់ហើយផ្ទេរមកនៅនេះព្រៃរំចេក ។

ដានី: ចំការនេះហៅភូមិព្រៃរំចេក?

ស៊ីវន: ចា៎! ក្រុមទី១ ភូមិព្រៃរំចេក ឃុំតាសាញ ស្រុកសំឡូត មេភូមិលន់ នៅត្រង់នោះ ។

ដានី: អ៊ីចឹងនៅសំរាកពេទ្យសុវណ្ណបានប៉ុន្មានយប់?

ស៊ីវន: ៣យប់ ។

ដានី: បានផ្លាស់មកពេទ្យព-២?

ស៊ីវន: ចា៎!

ដានី: ព-២ បានប៉ុន្មានបានបញ្ជូនទៅភ្នំពេញ?

ស៊ីវន: ព-២ដូចបាន១អាទិត្យដែរ ។

ដានី: ទៅភ្នំពេញបានប៉ុន្មានថ្ងៃ?

ស៊ីវន: ទៅភ្នំពេញបាន៣ថ្ងៃទេ គេរកបញ្ជូនទៀតវិលមកវិញ ។

ដានី: ដល់ពេលបាន៣ថ្ងៃ ទៅថៃភ្លាម ឬមកចូលនៅបាត់ដំបងសិន?

ស៊ីវន: បញ្ជូនពីភ្នំពេញមកចូលផ្ទះបាត់ដំបងបានមួយយប់ ស្អែកឡើងបងសេង ដឹងគាត់យកទៅពេទ្យទៀត ពេទ្យបាន១យប់ទៀតបានទៅថៃ សរុបទាំងអស់៥អាទិត្យចាប់ឈឺមក ។

ដានី: ចាប់ឈឺមក៥អាទិត្យ?

ស៊ីវន: ចា៎!

ដានី: ទៅថៃបានតែមួយអាទិត្យទេ?

ស៊ីវន: បាន១០ថ្ងៃ យូរ ។

ដានី: ដល់ត្រឡប់ពីថៃមកប៉ុន្មានថ្ងៃបានគាត់ផុត?

ស៊ីវន: ប្រហែលជា៥ថ្ងៃទៀត ។

ដានី: នៅព-២ទៀត?

ស៊ីវន: នៅព-២ ។

ដានី: អ៊ីចឹងអ៊ំហ៊ីនឹងឧត្តមសេនីយ៍ឯកប៊ុន សេង ។ គ្រួសារអ៊ំឲ្យហើយនិងគាត់ស្រឡាញ់គ្នា?

ស៊ីវន: រាប់អានគ្នាដែរ ហើយម្យ៉ាងឋានៈការងារគាត់ជាប់គ្នាទៀត ។ គាត់ឈ្មោះឆ្នោតនៅស្រុកសំឡូតក៏ដោយសារគាត់ មានសំលេងឆ្នោតល្អ ។

ដានី: ប៊ុន សេង គាត់ជាមេបញ្ជាការយុទ្ធភូមិភាគទី៥ ហើយអ៊ំប្រុសគាត់មេបញ្ជាការរងយុទ្ធភូមិភាគ ៥ ហើយជាទីប្រឹក្សាអគ្គសេនាធិការ ។

ស៊ីវន:   ចា៎!  ហើយចុះដាប់ជួយការងារបក្សនៅស្រុកសំឡូត ។

ដានី:   គាត់ឡើងជា?

ស៊ីវន:   អនុក្រុមការងារស្រុកសំឡូត ។

ដានី:   គាត់ផ្ដាច់ខ្លួនដំបូង គាត់ឧត្ដមសេនីយ៍ត្រី ផ្កាយមួយ?

ស៊ីវន:   ចា៎!  គេឲ្យគាត់ផ្កាយមួយ ។

ដានី:   គាត់ផ្កាយមួយភ្លាម តែគាត់ធ្វើការនៅយុទ្ធភូមិភាគ៥ ទទួលទិសខាងសំឡូត?

ស៊ីវន:   ចា៎!  តែគាត់ជាទីប្រឹក្សារបស់អគ្គសេនាធិការតាំងពីមុន ។

ដានី:   បានន័យថាផ្ដាច់ខ្លួនឆ្នាំកៅប៉ុន្មាន?

ស៊ីវន:   ៩៦ ។

ដានី:   ខែណាដែរ?

ស៊ីវន:   ខែ១០ ។

ដានី:   ខែ១០ ឆ្នាំ៩៦ គាត់ផ្ដាច់ខ្លួនហើយគាត់ជាទីប្រឹក្សារបស់ក្រសួង ។

ស៊ីវន:   ក្រសួងការពារជាតិដំបូង ។

ដានី:   ដំបូងក្រសួងការពារជាតិ ហើយជាមេបញ្ជាការរងឲ្យយុទ្ធភូមិភាគទី៥?

ស៊ីវន:   ចា៎!

ដានី:   ហើយដល់ឆ្នាំណាគាត់ឡើងជាឧត្ដមសេនីយ៍ទោ?

ស៊ីវន:   វាភ្លេចខែហ្នឹងខ្ញុំអត់ចាំ ។

ដានី:   ឆ្នាំណា?

ស៊ីវន:   អត់ដឹង ស្រាប់តែលឺថាផ្កាយ២ ដូចជាទើបនឹងឡើងប្រហែលជា២-៣ឆ្នាំហ្នឹងទេ គេដាក់ក្នុងនេះ ដឹងខ្ញុំអត់ដឹង ។

ដានី:   អ៊ំធ្វើបុណ្យសពហ្នឹងធ្វើនៅណា?

ស៊ីវន:   ធ្វើនៅភូមិភាគ៥ ។

ដានី:   ធ្វើនៅក្នុងមន្ទីរ?

ស៊ីវន:   ក្នុងភូមិភាគហ្នឹងតែម្ដង ។

ដានី:   អត់ទៅធ្វើនៅផ្ទះទេ?

ស៊ីវ៉ន: គេអត់ឲ្យយកទៅ ។ ការពិតគាត់ត្រូវធ្វើនៅកន្លែងអគ្គសេនាធិការភ្នំពេញ ពេលសពអ៊ីចឹងគេត្រូវយកទៅ តែបងសេង គាត់សុំធ្វើនៅភូមិភាគ៥ គេអត់ឲ្យយើងធ្វើនៅផ្ទះទេ មប៉ាងទីធ្លារផ្ទះវាតូច ។

ដានី: សពគាត់តំកលពីថ្ងៃទី១៤-១៧?

ស៊ីវ៉ន: ចា៎! ហែរយកទៅបូជា ។

ដានី: បូជានៅណាទៅ?

ស៊ីវ៉ន: នៅអាស្រមតាបុតសាវង្ស ។

ដានី: អាស្រមបុតសាវង្ស?

ស៊ីវ៉ន: នៅបាត់ដំបងហ្នឹង ។

ដានី: នៅក្នុងក្រុងបាត់ដំបងតែម្តង?

ស៊ីវ៉ន: នៅជាយតិចដែរ នៅជិតព្រលានហ្នឹង ។

ដានី: នៅជិតព្រលានហ្នឹងអាស្រមលោកតាបុតសាវង្ស?

ស៊ីវ៉ន: ចា៎! ស្អាតណាស់វត្តហ្នឹង ។

ដានី: ដល់ពេលបូជាហើយធាតុគាត់យកមក?

ស៊ីវ៉ន: ដាក់នៅហ្នឹងដែរ ។

ដានី: ដាក់នៅកន្លែងតាបុតសាវង្សដែរ?

ស៊ីវ៉ន: ចា៎! យើងមានចេតិយដាក់ក្នុងចេតិយហ្នឹង ហើយគេមានអ្នកយាមអីត្រឹមត្រូវណាស់ ។

ដានី: រាល់ការចំណាយព្យាបាលអីខាង?

ស៊ីវ៉ន: ខាងរដ្ឋចេញទាំងអស់ ។

ដានី: អ៊ីចឹងអ៊ំអត់អស់ចំណាយអីទេ?

ស៊ីវ៉ន: ចា៎! ចំណាយដែលតែវាអស់តិច ។

ដានី: តាំងពីព្យាបាលគាត់ តាំងពីធ្វើបុណ្យសព?

ស៊ីវ៉ន: ព្យាបាលដូចពេទ្យទាហានគេអត់យកលុយទេ ។

ដានី: ទៅពេទ្យភ្នំពេញ?

ស៊ីវ៉ន: ពេទ្យភ្នំពេញក៏អត់ដែរ ។

ដានី: ទៅថៃ?

ស៊ីវ៉ន: គេយក ។

ដានីៈ តែខាង?

ស៊ីវនៈ រដ្ឋាភិបាលគិតគូរ អ៊ំសេង គាត់គិត ។

ដានីៈ ដល់គាត់ខូចទៅធ្វើបុណ្យក៏គាត់ចេញ?

ស៊ីវនៈ ខាងអគ្គសេនាធិការគេចុះមកធ្វើ ។ បុណ្យហ្នឹងគេរៀបរួច មានតាមួយនោះគេនាំធ្វើរហូត ។

ដានីៈ តាណា? ឈ្មោះអីគេ?

ស៊ីវនៈ ឈ្មោះស្អីទេ គេចាំតែខ្ញុំអត់សូវចាំ ។ កម្មវិធីគោរពវិញ្ញាណក្ខន្ធ តាហ្នឹងមាឌធំ គាត់ថាគាត់ដើរធ្វើច្រើនកន្លែងណាស់ ឲ្យតែថាចាប់ពីផ្កាយមួយគាត់ធ្វើទាំងអស់ ។

ដានីៈ អីចឹងគាត់ខូចទៅដូចជាប្រាក់ខែ បៀវត្សគាត់នៅមានទៀត?

ស៊ីវនៈ អត់ទេ! គេផ្តាច់ដែរ ព្រោះគេជូនថ្ងៃធ្វើបុណ្យហ្នឹង ឃើញគេឲ្យ៧លាន ហើយបងសេង គាត់ឲ្យ៣លានទៀត វាត្រូវជា១០លាន ហើយបុណ្យហ្នឹងគេធ្វើមិនដឹងជាអស់ប៉ុន្មានទេ តែគេអាចទូទាត់លុយចូលបុណ្យ គេបង្វិលអីចឹង ដូចថាគេអ្នកទទួលធ្វើ ខ្ញុំថាយកចុះអត់អីទេ ខ្ញុំអត់ថាឲ្យតែរួចពិធីបុណ្យគេសប្បាយចិត្តហើយ ។

ដានីៈ អ៊ំម៉េចដែរ ដូចថាមានអារម្មណ៍យ៉ាងម៉េចដែរ?

ស៊ីវនៈ ខ្ញុំតាំងពីខ្ញុំមើលគាត់រហូត និយាយរួមតាំងពីផ្តាច់ខ្លួនចូលរដ្ឋាភិបាល ខ្ញុំមានអារម្មណ៍កក់ក្តៅ ទីមួយការរៀបចំមានប្រាក់ខែ យើងនៅខាងនេះអត់ដែលមានទេ ។ ទី២ឋានៈរបស់គាត់ក៏យើងយល់បានថាខាងលើរាជរដ្ឋាភិបាលបានរៀបចំគិតគូរ សមរម្យនឹងការងាររបស់គាត់ ។ ហើយទី៣កូនចៅបានទៅរស់នៅក្រុង បានរៀនសូត្រនឹងគេ ហើយទី៤យើងសុំថាដីធ្លី ដែលយើងមានទាំងប៉ុន្មាន កាលយើងធ្វើកិច្ចសន្យា សម្តេចហ៊ុនសែន គាត់រៀបចំឲ្យយើងគ្រប់គ្រងដីយើងវិញទាំងអស់ អីចឹងយើងអត់មានអីដែលលំបាកចិត្ត តូចចិត្ត តូចថ្លើមអី អត់ទេ មានតែការសប្បាយរីករាយ ហ្នឹងមួយផ្នែក ។ ហើយមួយផ្នែកទៀតពេលធ្វើបុណ្យ ពេលឈឺនេះ ខ្ញុំមិននឹកស្មានថាការរៀបចំរបស់រដ្ឋាភិបាលបានស្រួលអីចឹង ដល់ឃើញរៀបចំស្រួលសប្បាយចិត្ត ទៅកន្លែងណាក៏អត់មានទើសដែរ ឧទាហរណ៍ថាបញ្ជូនទៅត្រង់នេះក៏មិនទើស ទៅត្រង់ណាក៏មិនទើស ហើយសំរាប់ខ្ញុំតែម្តងនិយាយឲ្យត្រង់ យើងមិនអ្នកទៅផ្សារ ទៅក្រុងប៉ុន្មានដល់ឃើញគេរៀបចំស្រួលសប្បាយចិត្តណាស់ទី១ ។ ហើយពេលឈឺអីចឹងដែរ ពេទ្យគ្រប់កន្លែងគេយកចិត្តទុកដាក់ ទៅដល់ភ្លាមគឺគេគិតភ្លាម ហើយលុយកាក់គេអត់មានសួរនាំយើងទេ ព្រោះខាងលើគេគិតអស់ ។ ទី២នៅក្នុងពេទ្យក៏គេរៀបចំកន្លែងឲ្យយើងស្អាតបាតមានម៉ាស៊ីនត្រជាក់ ។ ទី៣ពេលដែលគាត់ខូចហើយធ្វើបុណ្យ គ្រាន់តែខូចហើយរាយការណ៍ភ្លាមគេរៀបចំកន្លែងនៅ

ភូមិភាគស្រេច ពេលដែលគេរៀបចំហើយ ថ្ងៃហ្នឹងភ្លៀងជាប់ទៀត គេយកឡានដឹក ដឹកហើយទៅដល់កន្លែងពេទ្យគេឈរតំរៀបចាំគោរពវិញ្ញាណក្ខន្ធលើកដាក់ក្នុងមឈ្ឈូស គេមានធ្វើពិធីតាំងពីហ្នឹងរហូត។ ដល់ថ្ងៃទី១ យើងយកពីល្ងាចទៅយប់ គេមានយាយជីសូត្រ លោកសូត្រ អាចារ្យគ្រប់គ្រាន់របស់គេណាស់ គេធ្វើត្រឹមត្រូវ គេរៀបកន្លែងហូប អាស្រ័យនៅ អ្នកយាមកាម ដល់ថ្ងៃទី១ គេថាធ្វើតាមប្រពៃណី គេឲ្យយើងសូត្រលោកទេសហូរហែរ មានប្រគេនចង្ហាន់លោក។ ថ្ងៃទី២បន្ទាប់ហ្នឹង គេថាកម្មវិធីគោរពវិញ្ញាណក្ខន្ធគេធ្វើមួយថ្ងៃ ហ្នឹងបានកូនខ្ញុំថា គិតរកថតទុកគ្រាន់ឲ្យចៅមើលតៗទៅទៀត។ កម្មវិធីទី៣ ហែរថ្ងៃទី១៧ ហែរទៅបូជាសពនៅអាស្រមតាបុតសាវង្សហ្នឹងចប់។ ដល់ចប់ហើយគ្រប់មួយអាទិត្យក៏យើងធ្វើឲ្យគំរប់មួយអាទិត្យហ្នឹង ក៏មានបងប្អូនព្រមទាំងប្រពន្ធ តាប៊ុន សេង គាត់អញ្ជើញទៅ អីចឹងបានថា ខ្ញុំសរុបមួយម៉ាត់ខ្ញុំកក់ក្ដៅ ខ្ញុំសប្បាយរីករាយ រហូតដល់ធ្វើពិធីនេះហើយ គេឲ្យខ្ញុំឡើងថ្លែងអំណរគុណគេទៀត ហើយយើងក៏ឡើងនិយាយតាមទឹកចិត្ត ដែលយើងអស់ចិត្តអស់ថ្លើមសប្បាយរីករាយនឹងរដ្ឋាភិបាល។

ដានី: បើសិនជាអ៊ំប្រៀបធៀបវិញ ដោយសារអ៊ំប្រុសជាកម្មាភិបាលជាន់ខ្ពស់ម្នាក់ដែរក្នុងសម័យ ៣ឆ្នាំ កាលហ្នឹងការរស់នៅការប្រាស្រ័យទាក់ទងពីមេៗ អ៊ំៗមក បើយើងប្រៀបធៀបពីហ្នុងដល់ពេលអ៊ំធ្វើសមាហរណកម្មផ្ដាច់ខ្លួនចូលធ្វើការជាមួយរដ្ឋាភិបាលវិញ។ វាយ៉ាងម៉េចដែរធ្លាប់ឆ្លងកាត់មកវាខុសគ្នាយ៉ាងម៉េច?

ស៊ីវន: ខុសគ្នាតិច ខ្ញុំឃើញចេះ កាលសម័យយើងនៅគេហៅខ្មែរក្រហម វាតឹងរឹងណាស់ មិនងាយឃើញ មិនងាយជួប មិនបាននិយាយជាមួយមេណាច្បាស់លាស់ទេ និយាយរួម បើថាការងារប្ដី ដឹងតែប្ដី ប្រពន្ធអត់ត្រូវដឹង។ ដល់មកក្នុងរដ្ឋាភិបាលខ្ញុំឃើញ តែគេស្គាល់ប្ដី គេស្គាល់ប្រពន្ធ មានកម្មវិធីដូចជាពិធីការ បុណ្យ ជប់លាង ឡើងផ្ទះ គេមកអញ្ជើញ យើងទាំងអស់គ្នាៗ ទៅគ្រាន់តែទៅសន្និបាតនៅភ្នំពេញហ្នឹង ក៏ត្រូវហៅទៅ ទៅដល់គេចែកបន្ទប់ឲ្យយើងមានបាយមានទឹកគេរៀបចំឲ្យយើង ម្នាក់នោះគាត់ថាហ្នឹងហើយកន្លែងទេវតា។ ដល់ម៉ោងគេអញ្ជើញយើងទៅហូប យើងកម្ម៉ង់អីក៏បានដែរ នៅកន្លែងជិតស្ដាត សណ្ឋាគារបុរីថ្មី។

ដានី: ឆ្នាំណា?

ស៊ីវន: ឆ្នាំត្រូវគ្នាដំបូង ៩៦ត្រូវគ្នា ៩៧ទៅសន្និបាតគាត់ហៅកូនទៅទាំងអស់ថ្ងៃហ្នឹង ទាំងកងការពារទៀត គិតទៅ៥ឡាន ទៅដល់គេរៀបចំ គេសួរថាយកប៉ុន្មានបន្ទប់ ដល់អីចឹងខ្ញុំយកអ្នកភ្នំពេញម្នាក់ អ្នកស្គាល់គ្នា យើងអត់ស្គាល់ភ្នំពេញ។

ដានីៈ តែក្នុងចិត្តរបស់អ៊ីវិញ ធ្លាប់ឆ្លងកាត់ រស់នៅពីរបបផ្សេងគ្នា ពី៧៥-៧៩ ហើយអ៊ីក៏មានតួនាទីដែរកាលហ្នុងណា ដល់ក្រោយមកពេលអ៊ីផ្ដាច់ខ្លួនក៏អ៊ីនៅមានតួនាទី ៗ តាមចិត្តអ៊ីផ្ទាល់អ៊ីចូលចិត្តមួយណាជាង?

ស៊ីវនៈ ម្យ៉ាងម្នាក់ ៗ

ដានីៈ ម្យ៉ាងម៉េចខ្លះ?

ស៊ីវនៈ ម្យ៉ាងទី១ចង់និយាយខាងនេះ រស់នៅរបៀបស្ងាត់ស្ងៀម របៀបមិនដឹង មិនឮ យើងការងារប៉ុន្មានធ្វើប៉ុណ្ណឹង របបគេឲ្យហូបប៉ុណ្ណា ហូបប៉ុណ្ណឹង ។

ដានីៈ ហ្នឹងកាលពីជំនាន់៣ឆ្នាំ?

ស៊ីវនៈ ជំនាន់៣ឆ្នាំ ជំនាន់ឥឡូវក៏អីចឹងដែរ មុនផ្ដាច់ខ្លួនចូលបន្តិចហ្នឹង ប៉ុណ្ណាប៉ុណ្ណឹង បើអីចឹងខ្ញុំយកច្រើនបានហើយ មកពីយើងធ្វើឡើងអីចឹង កាលណាយើងយកច្រើនហួសពេកក៏មិនបាន យើងមានច្រើនជាងគេពេកក៏មិនបាន សុទ្ធតែខុស បើនិយាយពីលោភខុសរហូត ៗ ដល់មករបបយើងខាងនេះវិញ មានកាន់តែច្រើនកាន់តែល្អ មានកាន់តែច្រើនកាន់តែសប្បាយស្រួលវាម្យ៉ាងម្នាក់ ៗ តែសំរាប់ខ្ញុំ ជាទស្សនៈ ជាគោលជំហរខ្លួនខ្ញុំ អត់បញ្ហាទេ នៅបានទាំងអស់ ។

ដានីៈ មួយណាក៏បាន?

ស៊ីវនៈ បាន! ព្រោះយើងធ្វើតំរូវសភាពការណ៍ ដូចថារបបខាងនេះវាអីចេះ របបខាងណុះវាចុះ នៅបានដូចគ្នា ។

ដានីៈ តែចិត្តអ៊ីផ្ទាល់តែម្ដងចូលចិត្តមួយណាជាង?

ស៊ីវនៈ សេរីវាស្រួលជាង ចង់ទៅខាងណាក៏បាន អានេះគេហៅរបបសេរី មូលធនសេរី ឯខាងនេះកុំមុយនីស្ដម៉េចទៅបាន យើងចង់ទៅណាក៏ដោយទាល់តែមានច្បាប់ បើអត់ច្បាប់ចេញមិនបានទេ ។

ដានីៈ អីចឹងអ៊ីសំនួរចុងក្រោយរបស់ខ្ញុំ ខ្ញុំសួរអ៊ីច្រើន យូរហើយ ។

ស៊ីវនៈ អត់អីទេក្មួយ សួរមក ។

ដានីៈ ទី១ទាក់ទងពីរឿងតុលាការវិញ ពីព្រោះខ្ញុំឮព័ត៌មានខាងតុលាការគេ ដូចថាមានព័ត៌មានថា គេចោទប្រកាន់អ៊ីប្រុសយ៉ាងម៉េចៗ កាលហ្នឹងអ៊ីដឹងរឿងហ្នឹងយ៉ាងម៉េចដែរ?

ស៊ីវនៈ គេចោទប្រកាន់ហ្នឹងដឹងថា គាត់ហ្នឹងជាប់ក្នុង០៣,០៤ មានឈ្មោះ ប៉ុន្តែអ៊ីគិតថាចេះ០៣, ០៤ ឮសម្ដេចហ៊ុនសែន គាត់និយាយដែរ គាត់ថាមិនឲ្យមានទេ ដូចថាគាត់ទោសម្ដោធន៍នៅ

បន្ទាយមានជ័យទោសម្ដោធន៍ហ្នឹងគាត់ឲ្យ តាហ៊ីន ប៊ុនហៀង ជួបគាត់អី ដូចនៅរតនៈមណ្ឌល អីហ្នឹង ។ បងឯងកុំភ័យមិនឲ្យមានកាត់ទោសដល់បងឯងទេ តែប៉ុណ្ណឹង ។

ដានី៖ ប៉ុន្តែបើតាមទស្សនៈអ៊ីផ្ទាល់ គេចោទគាត់ គាត់ក្នុងករណី០៣, ០៤ បើតាមអ៊ីផ្ទាល់ថា គេចោទគាត់ហ្នឹងយ៉ាងម៉េចដែរ? ខុស, ត្រូវ, យុត្តិធម៌, មិនយុត្តធម៌ម៉េចដែរ?

ស៊ីវ៉ន៖ បើតាមខ្ញុំគិត ហ្នឹងការយល់ផ្ទាល់ខ្លួនទេ ធម្មតាយើងធ្វើការងាររកន្លែងណាក៏ដោយវាតែងតែអីចឹង យើងនៅខាងក្រោមគេចោទបន្តៗអីចឹងមក យើងគេចមិនផុត ចង់គេចម៉េចក៏មិនផុត ចង់គេចម៉េចក៏មិនផុតដែរ ។ គ្រាន់តែថាចិត្តរបស់ខ្ញុំ ខ្ញុំគិតថាធ្វើម៉េចឲ្យចំរើន ដូចថាធ្វើ ទៅវាចំរើនដល់ក្មេងជំនាន់ក្រោយ ដឹងពូ ឬក៏ថាចំរើនក្នុងការរៀបចំប្រទេសជាតិ អត់ទាស់អីទេធ្វើចុះ ។

ដានី៖ អ៊ីមានប្រសាសន៍ហ្នឹង បើសិនជាតុលាការគេចោទអីចឹង គេចាប់គាត់មែន ក៏អ៊ីអត់ជំទាស់?

ស៊ីវ៉ន៖ អត់អី ខ្ញុំគិតចេះទៀត បើសិនខ្ញុំទៅជំនួសបាន ខ្ញុំទៅជំនួសក៏បាន ។

ដានី៖ ម៉េចអីចឹងអ៊ី?

ស៊ីវ៉ន៖ បានជាខ្ញុំថាទៅជំនួស ខ្ញុំគិតថាចេះ ធម្មតាគេសួរគេនាំ គេអីរឿង ព្រោះយើងធ្វើកន្លងមក យើងធ្វើតាមគេដែរទេ យើងមិនអាចប្រកែកប្រណាំងទេ អាហ្នឹងស្រេចតែរដ្ឋាភិបាលគិតគូរ ឬក៏សាលាក្ដី ហ្នឹងពិនិត្យពិចារណាមើលណា តែបើតាមជាក់ស្ដែងតែម្ដង ពួកខាងខ្ញុំមិនទេ មិនទាំគ្នាឃោរឃៅអីចឹង តែបើចោទហើយធ្វើម៉េច ពាក្យចោទប្រកាន់មួលបង្កាច់ ។

ដានី៖ ប៉ុន្តែកាលជំនាន់ហ្នឹងពេលដែលអ៊ីប្រុសនៅរស់ ពេលដែលគាត់ពូអីចឹង គាត់មានប្រតិកម្មយ៉ាងម៉េច? គាត់មាននិយាយប្រាប់អ៊ីរឿងអីទេ?

ស៊ីវ៉ន៖ អត់ទេ! គាត់អត់ថាអីទេ គាត់ថាអាហ្នឹងជាគោលការណ៍ត្រូវតែអីចឹង គាត់និយាយអីចឹង ។

ដានី៖ ជាគោលការណ៍ត្រូវតែអីចឹងម៉េច?

ស៊ីវ៉ន៖ គោលការណ៍របស់ខាងសាលាក្ដីខ្មែរក្រហម វាត្រូវតែធ្វើ មានទី២ មានទី៣ មានទី៤ ហ្នឹងជាលំដាប់លំដោយរបស់គេ ជាក់ស្ដែងធ្វើបាន មិនបានអាហ្នឹងជារឿងគេទៅ ។

ដានី៖ គាត់ថាអីចឹង?

ស៊ីវ៉ន៖ គាត់និយាយអីចឹង មិនមែនរឿងយើងទេ រឿងរដ្ឋាភិបាល ។

ដានី៖ តែកាលហ្នឹងគាត់មានខឹង ឬគាត់ព្រួយបារម្ភ?

ស៊ីវ៉ន៖ អត់ទេ! ធម្មតាតែប៉ុណ្ណឹង អាហ្នឹងជំងឺគាត់តែម្ដង គាត់មិនងាយខឹង មិនងាយភ័យផ្ដាសទេ ។

ដានី៖ កាលមុនមកគេមានដែលធ្លាប់មកជួបគាត់ទេ?

ស៊ីវន: ធ្លាប់មកជួប ហើយគេចង់ជួប តែបងសេង គាត់ណែនាំ គាត់ថាកន្លែងខ្លះ ចុះគាត់ធ្វើការនោះ ជួបបានក៏ជួប បើជួបមិនបានក៏មិនអីដែរបង ព្រោះគាត់រវល់ ជួនកាលគេមកដល់ផ្ទះអត់ឃើញគាត់ ។

ដានី: មានពីណាខ្លះដែលធ្លាប់មកជួបគាត់ពីមុនមក?

ស៊ីវន: ខេមរា ធ្លាប់មក ។ សុខ ខេមរា ។

ដានី: ខេមរា រីអូរ ។ អីចឹងគេជួបប៉ុន្មានដង បើតាមខ្ញុំដឹង លក្ខិណា នូ មកជួបម្តង?

ស៊ីវន: ហ្នឹងហើយ! ជួប២ដង ។

ដានី: សុខ ខេមរា មកជួបគាត់!

ស៊ីវន: ប៉ុណ្ណឹង!

អ្នកជិតខាង: អឺគាត់កម្រឲ្យអ្នកណាជួបណាស់!

ស៊ីវន: ហ្នឹងហើយ!

ដានី: គាត់អត់ឲ្យជួប?

ស៊ីវន: វាដូចថាអត់មានពេល គាត់ធ្វើការ ប៉ុន្តែ នូ លក្ខិណា បានជួបរបស់គាត់ ។

ដានី: ជួបបានសួរនាំគាត់ទេ?

ស៊ីវន: សួរ! តែគាត់ហាមអត់ឲ្យថត ។

ដានី: ហាមអត់ឲ្យថត?

ស៊ីវន: គាត់អត់ឲ្យថត ។

ដានី: ចុះ សុខ ខេមរា?

ស៊ីវន: សុខ ខេមរា អត់ទេ! ជួបកូនហើយសុំលេខទូរស័ព្ទកូន ដល់ពេលស្លាប់ហ្នឹងគាត់គេសួរមកដែរ ដល់អីចឹងកូនខ្ញុំគេទៅវិញ ។

ដានី: គេទៅថាម៉េច?

ស៊ីវន: គាត់ស្លាប់ពិតប្រាកដមែន ។ ហើយសួរថាស្លាប់ដោយជំងឺអី? កូនខ្ញុំក៏រៀបរាប់តាមហ្នឹង ។

ដានី: ជំងឺដែលគាត់ខូចហ្នឹងមានជំងឺទឹកនោមផ្អែម ។

ស៊ីវន: ទី១ទឹកនោមផ្អែម, ទី២លើសឈាម, ទី៣តំរងនោម, ទី៤ថ្លើម, ទី៥គ្រួសក្នុងប្រមាត់ ។

ដានី: ច្រើនមុខ?

ស៊ីវន: ដល់វាមានអីចឹងទៅធ្វើឲ្យវិបត្តិក្នុងខួរក្បាល មានជាតិពុលពេញក្បាល ។

ដានី: អឺ, អឺប្រុសមាននៅសេសសល់ដូចជាឯកសារ?

ស៊ីវន: អត់មានទេ ។

ដានី: ជារូបថតដែលយើងធ្លាប់ថតពីមុនៗ?

ស៊ីវន: អត់ទេ! អត់មាន មិនដឹងយកទៅណា មិនឃើញតែម្តង មិនដែលមាន ។

ដានី: អ៊ំកាលនៅពោធិ៍ចិនតុងអត់ដែលថតទេ? ថតរូបអនុស្សាវរីយ៍?

ស៊ីវន: ខ្ញុំអត់ទេ! មិនទេ គេច្បាស់លាស់ណាស់ លោកក្មួយ ច្បាស់ត្រង់ថា ប្រពន្ធធ្វើការងារត្រឹមប៉ុណ្ណោះទទួលប៉ុណ្ណឹង ដឹងប៉ុណ្ណឹង ឯប្តីធ្វើប៉ុណ្ណោ ដឹងប៉ុណ្ណោ ប៉ុណ្ណុង លាក់ការណ៍ ។ គេថាលាក់ការណ៍បានល្អរស់ លាក់ការណ៍មិនបានល្អស្លាប់ ។

ដានី: ខាងសាលាក្តីគេមិនដែលមកជួបគាត់ទេ?

ស៊ីវន: ឃើញមេធាវីឈ្មោះស្អីមកបានម្តង ធីរិទ្ធិ ។

ដានី: មកបានជួបគាត់ដែរ?

ស៊ីវន: ជួប គេថ្ងៃហ្នឹងគេយកការដូមកឲ្យគាត់ដូចជាចូលឆ្នាំ ។

ដានី: មេធាវីមកជួបហើយមានបាននិយាយអី?

ស៊ីវន: គាត់និយាយដែរ មេធាវីហ្នឹងជាមេធាវីរបស់ប្រពន្ធអ៊ំអៀង សារី ។

ដានី: អាង ឧត្តម អីចឹង? ផាត់ ពៅសៀង?

ស៊ីវន: ធារី, សេង ធារី ។

ដានី: ប៉ុន្តែគាត់ធ្លាប់ធ្វើមេធាវីឲ្យ ។

ស៊ីវន: ឮថាចេះគាត់ហ្នឹងមេធាវី គាត់ចង់មកជួបក្រែងដល់០៣, ០៤ បើមានបញ្ហាអីឲ្យទាក់ទងគាត់ទុកលេខទូរស័ព្ទឲ្យដែរ តែមិនដឹងទៅណាអស់ ។

ដានី: តែគាត់ហ្នឹងធ្លាប់ធ្វើមេធាវីឲ្យអ៊ំអៀង ធារិទ្ធិ?

ស៊ីវន: ឮគាត់និយាយអីចឹង ត្រង់មែនមិនមែនអត់ដឹងទេ គាត់អ្នកនិយាយយើងចេះតែស្តាប់ ។

ដានី: តែបានជួបអ៊ំប្រុសផ្ទាល់?

ស៊ីវន: ជួប! មកជួបនៅហ្នឹង ហើយគេយកការដូដាក់កញ្ច្រែងហ្នឹង ឲ្យគាត់មួយកញ្ច្រែងដែរ ។

ដានី: កាលហ្នឹងគាត់ហើយនិងតាមុត គេចោទដូចគ្នា ដល់គាត់មានដែលជួបគ្នា? ជុំគ្នា?

ស៊ីវន: អត់ទេ! អត់ជំនុំទេ រឿងផ្សេងគ្នាតែម្តង ព្រោះនិន្នាការនយោបាយ បើនិយាយឲ្យចំ គាត់តែចូលៗហើយ គាត់អត់មានទៅធ្វើចេះហើយទៅធ្វើចុះវិញអត់ទេ វាខុសគ្នា ។ តាមុត គាត់ចូលដែរតែគាត់ទៅធ្វើណុះទៀត ។

ដានី៖ អ៊ុំខ្ញុំអរគុណអ៊ុំច្រើនដែលផ្ដល់វេលានេះច្រើនដែរជាងពីរម៉ោង និយាយទៅពីបទពិសោធន៍ អ៊ុំធ្លាប់ឆ្លងកាត់មក ទាំងអ៊ុំ ទាំងអ៊ុំប្រុស ខ្ញុំអរគុណអ៊ុំច្រើន។

ស៊ីវន៖ ចា៎!